**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍វាយតម្លៃលើការអនុវត្តផែនការសកម្មភាព ៣ឆ្នាំ (២០១៨-២០២០)

## នៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥

អាជ្ញាធរមីន

C.M.A.A

# មាតិកា


**អារម្ភកថា** ..................................................................................................................................... ៤

**អក្សរបំព្រួញ**៦

**សេចក្តីសង្ខេប**.......................................................................................................................................... ៧

**ជំពូកទី១៖ សាវតារ** ...................................................................................................................................... ១២

**ជំពូកទី២៖ វិធីសាស្ត្រនិងដំណើរការសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ** ............................................ ១៦

២.១ វិធីសាស្ត្រ និងប្រភពព័ត៌មាន.................................................................................................................... ១៦

២.២ ដំណើរការនៃការរៀបចំរបាយការណ៍ ........................................................................................................ ១៦

**ជំពូកទី៣៖ ការរំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់ នៅត្រឹមឆ្នាំ២០២៥** ...................................................... ១៧

៣.១ បញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិនៅតាមស្រុកដែលនៅសល់ ត្រឹមឆ្នាំ២០២០ ............................................ ១៨

៣.២ ការអនុវត្តការរំដោះផ្ទៃដី តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្ទ្រាន យកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងធ្វើការស្រាវជ្រាវឡើងវិញ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យដីដែលមានមីន ......................................................................២០

៣.៣ ការរំដោះភូមិអាទិភាពដែលដឹងថាមានមីន នៅត្រឹមឆ្នាំ២០២១ និងភូមិដែលនៅសល់នៅត្រឹមឆ្នាំ២០២៥..............................២១

៣.៤ ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដែលមានស្រាប់ ...................................................... ២៣

**ជំពូកទី៤៖ ការរំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹម ឆ្នាំ២០២៥** ...........................២៧

៤.១ រៀបចំផែនការ និងចាត់អាទិភាពតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម ..........................................................................២៨

៤.២ ធ្វើការស្រាវជ្រាវ និងរំដោះផ្ទៃដីដែលត្រូវបានបញ្ជាក់ថាមានគ្រាប់បែកចង្កោម................................................................២៨

**ជំពូកទី៥៖ ការដោះស្រាយការគំរាមកំហែងពីសំណល់ជាតិផ្ទុះពីសង្គ្រាម**(**ស.ផ.ស.**) ............................................៣០

៥.១ ការស្រាវជ្រាវ និងរំដោះផ្ទៃដីដែលដឹងថាមាន ស.ផ.ស. ....................................................................................៣១

៥.២ ផ្តល់ការឆ្លើយតបអោយទាន់ពេលវេលាចំពោះសំណើរសុំជំនួយអន្តរាគមន៍ផ្នែកប្រតិបត្តិការកំទេចគ្រឿងផ្ទុះពីសហគមន៍ ឬអាជ្ញាធរ ..........................................................................................................................................................៣១

**ជំពូកទី៦៖ ការកាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ឱ្យនៅកម្រិតអប្បបរមា ព្រមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់របស់អ្នកនៅរស់រានមានជីវិត និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារមីន និងស.ផ.ស**................................................................................................................ ៣៣

៦.១ ការផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ប្រកបដោយប្រសិទ្ធភាពដល់ប្រជាជនដែលរស់នៅតាមតំបន់មានហានិភ័យខ្ពស់នាពេលបច្ចុប្បន្ន និងតំបន់ដែលមានហានិភ័យទើបកើតឡើងថ្មី សមស្របទៅនឹងភេទ និងអាយុ និងការពង្រឹងការផ្តួចផ្តើមបណ្តាញមូលដ្ឋាន.........................................................................................................................៣៤

៦.២ ការផ្តល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោលដើម្បីទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្តឱ្យបានគ្រប់គ្រាន់សមស្របទៅនឹងយេនឌ័រ និងការស្តារលទ្ធភាពពលកម្មកាយ សម្បទា ....... ៣៩

៦.៣ លើកកម្ពស់សមត្ថភាពប្រកបរបរចញ្ចឹមជីវិតរបស់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ពីមីន និងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោល ដើម្បីជំរុញការចូលរួមយ៉ាងពេញលេញរបស់ពួកគាត់នៅក្នុងសង្គម ....... ៤១

**ជំពូកទី៧៖ ការរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ** ....... ៤២

៧.១ គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍមូលដ្ឋាននៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ពីមីន គ្រាប់បែកចង្កោម និងស.ផ.ស. ផ្សេងទៀត ....... ៤២

៧.២ គាំទ្រអាទិភាពនៃការអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ....... ៤៣

**ជំពូកទី៨៖ ការជំរុញនិសព្វាវុធការក្នុងតំបន់ និងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពមីន** ....... ៤៦

៨.១ ជំរុញការអនុវត្តកាតព្វកិច្ច នៃអ.ហ.ផ.ម ....... ៤៦

៨.២ ជំរុញការអនុវត្តកាតព្វកិច្ចក្នុងអនុសញ្ញាធម្មតាមួចំនួន (CCW) និងគាំទ្រដល់វឌ្ឍនភាពឆ្ពោះទៅរកការចូលរួមក្នុងពិធីសារទី៥ ....... ៤៧

៨.៣ គាំទ្រដល់ការចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម (CCM) ត្រឹមឆ្នាំ ២០២០ ....... ៤៨

៨.៤ គាំទ្រដល់ប្រតិបត្តិការបោសសម្អាតមីន ក្នុងក្របខណ្ឌនៃប្រតិបត្តិការរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ ....... ៤៨

៨.៥ ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិសកម្មភាពមីន រាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ....... ៤៩

**ជំពូកទី៩៖ ការបង្កើតសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥** ....... ៥២

៩.១. ពង្រឹងសមត្ថភាពជាតិដើម្បីគ្រប់គ្រង និងអនុវត្តកម្មវិធីសកម្មភាពមីន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ....... ៥២

៩.២ ថែរក្សា កែលម្អ និងចែករំលែកចំណេះដឹងអំពីសកម្មភាពមីន នៅក្នុងវិស័យនេះទៅដល់វិស័យផ្សេងទៀត ....... ៥៣

៩.៣ ធ្វើការពិនិត្យមើលឡើងវិញត្រឹមឆ្នាំ២០២០ នូវក្របខណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំងយុទ្ធសាស្ត្រ និងសមត្ថភាព ដែលចាំបាច់ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ ....... ៥៤

៩.៤ ពង្រឹង និងថែរក្សាសមត្ថភាពជាតិប្រកបដោយនិរន្តភាពដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ ២០២៥ ឱ្យមានប្រសិទ្ធភាព (ចាប់ផ្តើមឆ្នាំ២០២០) ....... ៥៤

**ជំពូកទី១០៖ ការធានារាល់សកម្មភាពមីនទាំងអស់ត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាពដែលមានភាពល្អប្រសើរ ការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ការយកចិត្តទុកដាក់ខ្ពស់ អំពីយេនឌ័រ និងការការពារបរិស្ថាន** ....... ៥៥

១០.១ ពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាព ....... ៥៥

១០.២ ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិសម្រាប់សកម្មភាពមីន ....... ៥៦

១០.៣ ជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពមីន ....... ៥៩

១០.៤ បញ្ជ្រាបកិច្ចការការពារបរិស្ថានក្នុងសកម្មភាពមីន ....... ៦២

១០.៥ អនុវត្តប្រព័ន្ធគ្រួតពិនិត្យសកម្មភាពវិស័យមីន(PMS) ........ ៦២

**ជំពូកទី១១៖ បញ្ហាប្រឈម និងតម្រូវការ**........ ៦៣

១០.១ ការគាំទ្រខាងផ្នែកសម្ភារដល់កងទ័ពជើងគោក និងបោសសម្អាតមីនតាមព្រំដែន........ ៦៣

១០.២ ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងអាជ្ញាធរមីន និងក្រសួងពាក់ព័ន្ធ ........ ៦៣

១០.៣ ការកៀរគរនិងតម្រូវការធនធាន........ ៦៣

**ជំពូកទី១២៖ សេចក្តីសន្និដ្ឋាន** ........ ៦៥

**ឧបសម្ព័ន្ធក**........ ៦៦

**ឧបសម្ព័ន្ធខ**........ ៦៧

# អារម្ភកថា

ដោយសារជម្លោះក្នុងតំបន់ និងជម្លោះផ្ទៃក្នុងដែលបានអូសបន្លាយក្នុងអតីតកាល កម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសមួយក្នុងចំណោមប្រទេសដែលរងផលប៉ះពាល់ដោយសារមីនធ្ងន់ធ្ងរជាងគេលើពិភពលោក។ មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.) រាប់លានគ្រាប់ នៅរាយប៉ាយក្នុងដី លើដីក្រោមផ្ទៃទឹក ពេញផ្ទៃប្រទេស ជាពិសេសតាមបណ្ដាខេត្តភាគខាងលិចនិងភាគពាយព្យប្រទេស ដោយពុំមានការកត់ត្រាក្នុងផែនទីច្បាស់លាស់នោះឡើយ។ លើសពីនេះ កម្ពុជាក៏រងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារគ្រាប់បែកចង្កោមនិង ស.ផ.ស. ផ្សេងទៀតផងដែរ នៅភាគខាងកើតប្រទេស។ មរតកពីសង្គ្រាមទាំងនេះ មិនគ្រាន់តែធ្វើឱ្យប្រជាពលរដ្ឋកម្ពុជារស់នៅតំបន់ជាប់ស្រយាលស្លាប់ របួស និងពិការតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឧបសគ្គដល់ការអភិវឌ្ឍប្រទេសជាតិផងដែរ។

ក្នុងនាមជារដ្ឋភាគីមួយនៃអនុសញ្ញាអូតាវ៉ាចាប់ពីឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើវិស័យមីន ហើយក៏បាននិងកំពុងបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងអនុសញ្ញានេះយ៉ាងសស្រាក់សស្រាំ ដោយបានដាក់បញ្ចូលវិស័យមីនទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ ដើម្បីគាំទ្រដល់ការសម្រេចបាននូវអាទិភាព និងផែនការយុទ្ធសាស្ត្រជាតិទាំងនេះរាជរដ្ឋាភិបាលបានបង្កើតផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ដែលជាផែនទីតម្រង់ទិសសម្រាប់ការអនុវត្ត។ កម្ពុជាក៏បានរៀបចំសំណើសុំពន្យារពេលបោសសម្អាតមីនលើកទី២ឆ្នាំ២០២០-២០២៥ ដោយទទួលបានការឯកភាពទាំងស្រុងក្នុងកិច្ចប្រជុំពិនិត្យឡើងវិញលើកទី៤ (Fourth Review Conference) នៃអនុសញ្ញាអូតាវ៉ា នៅចុងឆ្នាំ២០១៩ នៅទីក្រុងអូស្លូ ប្រទេសន័រវែស។

របាយការណ៍នេះបង្ហាញអំពីសមិទ្ធផលសម្រេចបានទាំងផ្នែកគ្រប់គ្រង និងផ្នែកប្រតិបត្តិការនៃការអនុវត្តផែនការសកម្មភាព៣ឆ្នាំ ពីឆ្នាំ២០១៨ ដល់២០២០ នៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥។

ទោះបីមានកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលជាច្រើនត្រូវបានសម្រេច ក៏វិសាលភាពនៃបញ្ហាមីននៅតែជាការលំបាកមួយដើម្បីសម្រេចបានតាមផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន។ ចាប់ពីឆ្នាំ ២០២១-២០២៥ កម្ពុជានៅត្រូវការថវិកាប្រមាណ ៣៣៣,២៥លានដុល្លារ ដើម្បីធ្វើការបោសសម្អាតផ្ទៃដីដែលមានគ្រាប់មីនប្រឆាំងមនុស្ស ៨០៦គីឡូម៉ែត្រការ៉េ គ្រាប់មីនប្រឆាំងរថក្រោះ ៤៦គីឡូម៉ែត្រការ៉េ

ផ្ទៃដីមានគ្រាប់បែកចង្កោម ៦៣៤គីឡូម៉ែត្រការ៉េ និងផ្ទៃដីមានសំណល់ជាតិផ្ទុះពីសង្គ្រាម ៤៦៨គីឡូម៉ែត្រការ៉េ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងនូវអំណរអរគុណដល់បណ្តាប្រទេសផ្តល់ជំនួយ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធចំពោះការគាំទ្រនាពេលកន្លងមក។ យើងខ្ញុំសង្ឃឹមថា កម្រិតនៃការគាំទ្រនេះនឹងនៅតែបន្ត និងបង្កើនថែមទៀត ដើម្បីបង្កលទ្ធភាពឱ្យរាជរដ្ឋាភិបាលកម្ពុជា អាចបោសសម្អាតមីនដើម្បីគាំទ្រការអភិវឌ្ឍប្រទេសកម្ពុជា ព្រមទាំងអាចបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងអនុសញ្ញាអូតាវ៉ា។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានទី១ អាជ្ញាធរមីន**

**លី ធុជ**

# អក្សរបំព្រួញ

| | |
|---|---|
| អ.ហ.ផ.ម. | អនុសញ្ញាអន្តរជាតិស្តីពីការហាមការប្រើប្រាស់ ការលុបបំបាត់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីនចោល |
| ស.ក.ម.ក. | ស្តង់ដារកម្ចាត់មីនកម្ពុជា |
| ក.ប.ម. | ក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍លើវិស័យមីន |
| ស.ផ.ស. | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| ហ.ត. | ហិចតា |
| គម២ | គីឡូម៉ែត្រការ៉េ |
| ម២ | ម៉ែត្រការ៉េ |
| អ.ធ.ម | អាជ្ញាធរមីន |
| អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ប.ព.ជ.ម.ក. | ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីននិងស.ផ.ស.នៅកម្ពុជា |
| ផ.យ.ជ.ម. | ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |

# សេចក្តីសង្ខេប

របាយការណ៍វាយតម្លៃលើផែនការសកម្មភាព៣ឆ្នាំ ២០១៨-២០២០ ត្រូវបានរៀបចំដោយអាជ្ញាធរមីន រួមសហការជាមួយនឹងប្រតិបត្តិករសកម្មភាពមីនទាំងអស់ ក្នុងគោលបំណងផ្សព្វផ្សាយសមិទ្ធផលធំៗ ដែលសម្រេចបានជូនរាជរដ្ឋាភិបាលកម្ពុជា ប្រទេសផ្តល់ជំនួយ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានាបានជ្រួតជ្រាបអំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាលើវិស័យនេះ និងលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធទាំងអស់បន្តចូលរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ដើម្បីសម្រេចឱ្យបាន «កម្ពុជាមួយគ្មានមីនឆ្នាំ២០២៥»។

សម្រាប់រយៈពេល៣ឆ្នាំ គិតចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ វិស័យមីននៅកម្ពុជាទទួលបានថវិកាប្រមាណ **៩១លានដុល្លារសហរដ្ឋអាមេរិក** ប្រៀបធៀបទៅនឹងតម្រូវការថវិកាសរុបស្មើនឹង៦០%ប៉ុណ្ណោះ។ ជាសមិទ្ធផល ផ្ទៃដីដែលសង្ស័យមានមីននិងស.ផ.ស.ទំហំ **៤២០.៦៩៥.១៤៥ម$^{២}$** (ប្រៀបធៀបទៅនឹងផែនការស្មើនឹង**៦៦%**) ត្រូវបានរំដោះដោយប្រតិបត្តិករ ក្នុងនោះរួមមាន កងយោធពលខេមរភូមិន្ទ RCAF(NPMEC) មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(CMAC) អង្គការ MAG អង្គការ HALO Trust អង្គការ NPA អង្គការដោះមីនកម្ពុជា(CSHD) និងអង្គការ APOPO ដើម្បីគាំទ្រការអភិវឌ្ឍនិងផ្តល់សុវត្ថិភាពដល់សហគមន៍ ព្រមទាំងបានរកឃើញ និងកម្ទេចចោលនូវមីនប្រឆាំងមនុស្សចំនួន **៤៩.២៥៦គ្រាប់** មីនប្រឆាំងរថក្រោះចំនួន**៩៥៦គ្រាប់** និងសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន **២២១.៣៧២គ្រាប់** ។ សម្រាប់ រយៈពេល៣ឆ្នាំនេះ ជាមធ្យម៨៧%នៃផ្ទៃដីដែលបានបោសសម្អាតរួច ត្រូវបានប្រើប្រាស់សម្រាប់វិស័យកសិកម្ម ដែលមានអ្នកទទួលផលចំនួន **៥៨៣.៥២៧គ្រួសារ** ស្មើនឹងប្រជាជនសរុបចំនួន **២.១២០.៤៩៧នាក់** ស្ត្រីចំនួន **១.០៣៤.១៩០នាក់**។ សមិទ្ធផលសំខាន់សរុបសម្រាប់រយៈពេល ៣ឆ្នាំនេះ មានពិពណ៌នាលម្អិតដូចខាងក្រោម៖

| | |
|---|---|
| ផ្ទៃដីសង្ស័យមានមីនត្រូវបានរំដោះ | ២៨០.៣៥៣.៩០៩ម$^{២}$ |
| ផ្ទៃដីដែលសង្ស័យមានគ្រាប់បែកចង្កោមត្រូវបានរំដោះ | ៩៩.៥០៩.៨៦៦ម$^{២}$ |
| ផ្ទៃដីដែលសង្ស័យមានស.ផ.ស.ផ្សេងទៀតត្រូវបានរំដោះ | ៤០.៨៣១.៣៧០ម$^{២}$ |
| រកឃើញនិងកម្ទេចចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន | ៤៩.២៥៦គ្រាប់ |
| រកឃើញនិងកម្ទេចចោលគ្រាប់មីនប្រឆាំងរថក្រោះចំនួន | ៩៥៦គ្រាប់ |
| រកឃើញនិងកម្ទេចចោលសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន | ២២១.៣៧២គ្រាប់ |
| អ្នកទទួលផលចំនួន | ២.១២០.៤៩៧នាក់ |

ជាមួយគ្នានេះ ដើម្បីធានាថា ប្រតិបត្តិការបោសសម្អាតមីនមានភាពស្របច្បាប់ មានប្រសិទ្ធភាព ប្រសិទ្ធផល និងសុវត្ថិភាព ស្របទៅតាមស្តង់ដារកំចាត់មីនកម្ពុជា (CMAS) ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ក្រុមត្រួតពិនិត្យអាជ្ញាធរមីន(QM Team) បានចុះត្រួតពិនិត្យគុណភាពការងារបោសសម្អាតមីន និង ស.ផ.ស.របស់ប្រតិបត្តិករបានចំនួន **៤.៨៨៣លើក** លើការស្រាវជ្រាវព័ត៌មានគ្រាប់មីននិងស.ផ.ស. ការបោសសម្អាតមីនដោយដៃ ការប្រើគ្រឿងចក្រ ការបោសសម្អាតមីនដោយសុនខនិងកណ្តុរ ព្រមទាំងកិច្ច ប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះ និងការរក្សាទុកគ្រឿងផ្ទុះផងដែរ។

ការគ្រប់គ្រងព័ត៌មានបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការរៀបចំផែនការ និងចាត់អាទិភាព ការអនុវត្ត ការត្រួតពិនិត្យនិងវាយតម្លៃ និងការធ្វើរបាយការណ៍ក្នុងវិស័យសកម្មភាពមីន។ ប្រព័ន្ធគ្រប់គ្រង ទិន្នន័យវិស័យសកម្មភាពមីនថ្នាក់ជាតិ ហៅកាត់ថា IMSMA ត្រូវបានដាក់ឱ្យដំណើរការដោយអាជ្ញាធរមីន ហើយមានទិន្នន័យចំនួន២១ប្រភេទដែលបានរក្សាទុកក្នុងប្រព័ន្ធទិន្នន័យថ្នាក់ជាតិ។

ក្រៅពីការបោសសម្អាតមីន និងស.ផ.ស. ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និង ស.ផ.ស. នៅតែជាសកម្មភាពចាំបាច់ក្នុងការរួមចំណែកទប់ស្កាត់ការកើនឡើងនៃអត្រាគ្រោះថ្នាក់។ គិត ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ប្រជាពលរដ្ឋចំនួន **២.៨៤០.៦១២នាក់** បានទទួលសារអប់រំកាត់បន្ថយ គ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ពីប្រតិបត្តិករ និងអាជ្ញាធរមានសមត្ថកិច្ច។ ជាមួយគ្នានេះ អាជ្ញាធរមីន បានសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការបញ្ជ្រាប ការអប់រំកាត់បន្ថយគ្រោះថ្នាក់ ដោយសារមីន និងស.ផ.ស. ទៅក្នុងកម្មវិធីសិក្សាថ្នាក់ទី៧ និងថ្នាក់ទី៨ និងបន្តពិភាក្សាពីលទ្ធភាពដាក់ បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ទី៩បន្ថែមទៀត។ លើសពីនេះ ការអប់រំដោយមន្ត្រីនគរបាលជាតិក្នុងការអនុ វត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការអប់រំដោយបណ្តាញតាមសហគមន៍ គឺជាវិធីសាស្ត្រដ៏ មានប្រសិទ្ធភាពក្នុងការធានានិរន្តរភាពការងារ។ តាមរបាយការណ៍របស់ CMVIS ជនរងគ្រោះថ្នាក់ ដោយសារមីន និងស.ផ.ស.មានចំនួន**៥៨នាក់** នៅក្នុងឆ្នាំ២០១៨ ហើយបានកើនឡើងដល់ **៧៧នាក់** ក្នុងឆ្នាំ២០១៩ ប៉ុន្តែតួលេខនេះបានធ្លាក់ចុះមកវិញមកត្រឹម **៦៥នាក់** ក្នុងឆ្នាំ២០២០ ដែលនេះជាសមិទ្ធ ផលមួយគួរឱ្យកត់សម្គាល់។

តាមផែនការអាជ្ញាធរមីនគ្រោងធ្វើការសិក្សាគុណភាពជីវិត (QLS) លើជនរងគ្រោះដោយសារមីន និងស.ផ.ស. ចំនួន**២៤.០០០នាក់** ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។ ជាក់ស្តែង ជនរងគ្រោះចំនួន **៧.២៧៣នាក់**ប៉ុណ្ណោះ ដែលត្រូវបានសម្ភាសន៍ដោយសារកង្វះខាតថវិកា និងការរាតត្បាតនៃជំងឺកូវីដ-១៩។ ក្នុងរយៈពេល៣ឆ្នាំ អាជ្ញាធរមីនបានរៀបចំវេទិកាពិភាក្សាដើម្បីសិក្សាអំពីតម្រូវការជនពិការតាម ស្រុកគោលដៅបានចំនួន៤លើក ដែលមានការចូលរួមពីជនពិការចំនួន **៤៥៥នាក់** ក្នុងខេត្តបាត់ដំបង ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ។ ទន្ទឹមគ្នានេះ តាមរយៈថវិកាគាំទ្រដោយ The Sir Bobby Charlton Foundation អាជ្ញាធរមីនក៏បានរៀបចំពិធីសំណេះសំណាលសាកសួរសុខទុក្ខ និងចែកគ្រឿងឧបភោគ

បរិភោគដល់ជនរងគ្រោះដោយសារមីនដែលមានជីវភាពក្រីក្រចំនួន ៦លើក នៅខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តស្វាយរៀង ដោយមានអ្នកចូលរួមសរុបចំនួន **១.៣៥៨នាក់**។

សម្រាប់កិច្ចសហប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិ (UN Peacekeeping Operations) កងយោធពលខេមរភូមិន្ទបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការរក្សាសន្តិភាព ក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។ បណ្តាប្រទេសដែលកងយោធពលខេមរភូមិន្ទបានចូលរួមបេសកកម្ម រួមមានស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ អាហ្វ្រិកកណ្តាល ម៉ាលី លីបង់ ស៊ីប ស៊ីរី និងយេម៉ែន ដែលគិតពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២០ មានកងកម្លាំងមួកខៀវកម្ពុជាសរុបចំនួន **៦.៥៥៧នាក់** ក្នុងនោះមានស្ត្រីចំនួន **៣៣៨នាក់** លើជំនាញបោសសម្អាតមីន វិស្វកម្ម សំណង់ផ្តេក-បញ្ឈរ អាវុធហត្ថ មន្ទីរពេទ្យកម្រិត២ វិស្វកម្មព្រលាន យន្តហោះកម្ទេចគ្រឿងផ្ទុះ នាយទាហានសេនាធិការ និងសង្កេតការណ៍យោធា។

ដើម្បីធានាឱ្យមានការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវគោលដៅ និងសូចនាករជាក់លាក់ និងបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន (NMAS) ២០១៨-២០២៥ ដោយមានអាជ្ញាធរមីន បាននិងកំពុងខិតខំប្រឹងប្រែងក្នុងការជំរុញឱ្យប្រតិបត្តិករ ភីម៉ាក់/ម៉ាពូ និងភាគីពាក់ព័ន្ធទាំងអស់ គិតគូរអំពីសមភាពយេនឌ័រក្នុងសសរស្តម្ភសំខាន់ៗរបស់វិស័យសកម្មភាពមីន។ ជាលទ្ធផល ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ បានធ្វើឱ្យចំនួននៃការចូលរួមរបស់ស្ត្រីក្នុងរាល់សកម្មភាពរមីនមានការកើនឡើងប្រមាណ**១០%** ទោះបីមានការធ្លាក់ចុះខ្លះក្នុងឆ្នាំ២០១៩ យ៉ាងណាក៏ដោយ។ ជាក់ស្តែងចំនួនស្ត្រីគិតជាភាគរយនៃចំនួនបុគ្គលិកបម្រើការងារសរុបក្នុងវិស័យសកម្មភាពមីន បានកើនឡើងពី**២២,៤៦%** ក្នុងឆ្នាំ២០១៨ មក **២៣,១៧%** ក្នុងឆ្នាំ២០១៩ និងកើនដល់ **២៣,៧៥%** ក្នុងឆ្នាំ២០២០ រួមទាំងមានការកើនឡើងផងដែរនូវចំនួនស្ត្រីក្នុងតួនាទីជាអ្នកសម្រេចចិត្ត ជាថ្នាក់ដឹកនាំ ទាំងនៅក្នុងអាជ្ញាធរមីន ភីម៉ាក់/ម៉ាពូ និងប្រតិបត្តិករផ្សេងទៀត។

កម្ពុជាបានរៀបចំសំណើសុំពន្យារពេលបោសសម្អាតមីនលើកទី២ ឆ្នាំ២០២០-២០២៥ ដោយទទួលបានការឯកភាពទាំងស្រុងក្នុងកិច្ចប្រជុំអន្តរជាតិស្តីពីមីននៅទីក្រុងអូស្លូ ប្រទេសន័រវេស កាលពីឆ្នាំ២០១៩។ កម្ពុជាក៏បានបញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិចំនួន ៧៣ស្រុក ដែលនៅសេសសល់ផងដែរ។ ក្នុងក្របខ័ណ្ឌប្រតិបត្តិការ ស្តង់ដារកម្ចាត់មីនកម្ពុជាមួយចំនួនត្រូវបានពិនិត្យឡើងវិញ និងបង្កើតថ្មីដោយមានការចូលរួមពីប្រតិបត្តិករជាតិ អន្តរជាតិ និងភាគីពាក់ព័ន្ធ។ ដោយឡែក ការងារពិនិត្យឡើងវិញ និងវាយតម្លៃក្របខ័ណ្ឌស្ថាប័ន មិនទាន់បានអនុវត្តនៅឡើយ ដោយសារភាគីពាក់ព័ន្ធក្នុងវិស័យមីនយល់ឃើញថា មិនទាន់មានតម្រូវការក្នុងការអនុវត្តនៅឡើយ។ កម្ពុជាបានសិក្សាអំពីលទ្ធភាពនៃការចូលរួមរបស់កងយោធពលខេមរភូមិន្ទចំនួន ២.០០០នាក់ ក្នុងកិច្ចប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌ផងដែរ ដែលការងារនេះតម្រូវឱ្យមានការពិភាក្សាលំអិតបន្ថែមទៀត។ ជារួម ចំពោះលទ្ធផលនៃការអនុវត្តផែនការ

សកម្មភាពរយៈពេល៣ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ គឺយើងបានសម្រេចគោលដៅមួយចំនួនដូចមានរៀបរាប់ក្នុងតារាងខាងក្រោម៖

| គោលបំណង | គោលដៅ | ការអនុវត្ត* |
|---|---|---|
| ១. រំដោះផ្ទៃដីដែលដឹងថាមានមីនឱ្យអស់នៅត្រឹមឆ្នាំ២០២៥ | ១.១ បញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិ សម្រាប់បណ្ដាស្រុកដែលនៅសេសសល់ទាំងអស់ត្រឹមឆ្នាំ២០២០ | សម្រេចបាន |
| | ១.២ អនុវត្តការរំដោះផ្ទៃដី តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងធ្វើការស្រាវជ្រាវឡើងវិញ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យដីដែលមានមីន | មិនទាន់សម្រេចបាន |
| | ១.៣ កាត់បន្ថយភូមិអាទិភាពដែលដឹងថាមានមីន នៅត្រឹមឆ្នាំ២០២១ និងភូមិដែលនៅសល់នៅត្រឹមឆ្នាំ២០២៥ | ហៀបនឹងសម្រេចបាន |
| | ១.៤ ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដែលមានស្រាប់ | ហៀបនឹងសម្រេចបាន |
| ២. រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹមឆ្នាំ២០២៥ | ២.១ រៀបចំផែនការ និងចាត់អាទិភាពតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម | សម្រេចបាន |
| | ២.២ ធ្វើការស្រាវជ្រាវ និងរំដោះផ្ទៃដីដែលត្រូវបានបញ្ជាក់ថាមានគ្រាប់បែកចង្កោម | មិនទាន់សម្រេចបាន |
| ៣. ដោះស្រាយការគំរាមកំហែងពី ស.ផ.ស. | ៣.១ ស្រាវជ្រាវ និងកាត់បន្ថយផ្ទៃដីដែលដឹងថាមាន ស.ផ.ស | មិនទាន់មានតម្រូវការក្នុងការអនុវត្ត |
| | ៣.២ ផ្ដល់ការឆ្លើយតបឱ្យទាន់ពេលវេលាចំពោះសំណើសុំជំនួយអន្តរាគមន៍ ផ្នែកប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះពីសហគមន៍ ឬអាជ្ញាធរ | ហៀបនឹងសម្រេចបាន |
| ៤. កាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ឱ្យនៅកម្រិតអប្បបរមា ព្រមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់អ្នករស់រានមានជីវិត និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារមីន និងស.ផ.ស. | ៤.១ ផ្ដល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ប្រកបដោយប្រសិទ្ធភាពដល់ប្រជាជនដែលរស់នៅតាមតំបន់មានហានិភ័យខ្ពស់ នាពេលបច្ចុប្បន្ន និងតំបន់ដែលមានហានិភ័យទើបកើតឡើងថ្មី សមស្របទៅនឹងភេទនិងអាយុ និងការពង្រឹងការផ្ដួចផ្ដើមបណ្ដាញមូលដ្ឋាន | សម្រេចបាន |
| | ៤.២ ផ្ដល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោលដើម្បីទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្តឱ្យបានគ្រប់គ្រាន់សមស្របទៅនឹងយេនឌ័រ និងការស្តារលទ្ធភាពពលកម្មកាយសម្បទា | មិនទាន់សម្រេចបាន |
| | ៤.៣ លើកកម្ពស់សមត្ថភាពប្រកបរបរចញ្ចឹមជីវិតរបស់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ពីមីន និងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោល ដើម្បីជំរុញការចូលរួមយ៉ាងពេញលេញរបស់ពួកគាត់នៅក្នុងសង្គម | មិនទាន់សម្រេចបាន |
| ៥. រួមចំណែកដល់កំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ | ៥.១ គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍមូលដ្ឋាននៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ពីមីន គ្រាប់បែកចង្កោម និងស.ផ.ស. ផ្សេងទៀត | សម្រេចបាន |
| | ៥.២ គាំទ្រអាទិភាពនៃការអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ហៀបនឹងសម្រេចបាន |
| ៦. ជំរុញនិសញ្ញវុធការក្នុងតំបន់ និងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពមីន | ៦.១ ជំរុញការអនុវត្តកាតព្វកិច្ច នៃអ.ហ.ផ.ម | សម្រេចបាន |
| | ៦.២ ជំរុញការអនុវត្តកាតព្វកិច្ចក្នុងអនុសញ្ញាធម្មតាមួយចំនួន (CCW) និងគាំទ្រដល់វឌ្ឍនភាពឆ្ពោះទៅរកការចូលរួមក្នុងពិធីសារទី៥ | ហៀបនឹងសម្រេចបាន |
| | ៦.៣ គាំទ្រដល់ការចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម (CCM) ត្រឹមឆ្នាំ ២០២០ | ហៀបនឹងសម្រេចបាន |

| | | |
|---|---|---|
| | ៦.៤ គាំទ្រដល់ប្រតិបត្តិការបោសសម្អាតមីន ក្នុងក្របខណ្ឌនៃប្រតិបត្តិការរក្សាសន្តិភាព នៃអង្គការសហប្រជាជាតិ | សម្រេចបាន |
| | ៦.៥ លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិសកម្មភាពមីន រាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង | ហៀបនឹងសម្រេចបាន |
| ៧. បង្កើតសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥ | ៧.១ ពង្រឹងសមត្ថភាពជាតិដើម្បីគ្រប់គ្រង និងអនុវត្តកម្មវិធីសកម្មភាពមីន ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល | ហៀបនឹងសម្រេចបាន |
| | ៧.២ ថែរក្សា កែលម្អ និងចែករំលែកចំណេះដឹងអំពីសកម្មភាពមីន នៅក្នុងវិស័យនេះ និងទៅដល់វិស័យផ្សេងទៀត | មិនទាន់សម្រេចបាន |
| | ៧.៣ ធ្វើការពិនិត្យមើលឡើងវិញត្រឹមឆ្នាំ២០២០ នូវក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំងយុទ្ធសាស្ត្រ និងសមត្ថភាព ដែលចាំបាច់ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ | មិនទាន់សម្រេចបាន |
| | ៧.៤ ពង្រឹង និងថែរក្សាសមត្ថភាពជាតិប្រកបដោយនិរន្តភាពដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥ ឱ្យមានប្រសិទ្ធភាព ចាប់ផ្តើមឆ្នាំ២០២០ | មិនទាន់មានតម្រូវការក្នុងការអនុវត្ត |
| ៨. ធានារាល់សកម្មភាពមីនទាំងអស់ត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាពដែលមានភាពល្អប្រសើរ ការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ការយកចិត្តទុកដាក់ខ្ពស់ អំពីយេនឌ័រ និងការការពារបរិស្ថាន | ៨.១ ពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាព | សម្រេចបាន |
| | ៨.២ ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិសម្រាប់សកម្មភាពមីន | មិនទាន់សម្រេចបាន |
| | ៨.៣ ជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពមីន | សម្រេចបាន |
| | ៨.៤ បញ្ជ្រាបកិច្ចការការពារបរិស្ថានក្នុងសកម្មភាពមីន | មិនទាន់សម្រេចបាន |
| | ៨.៥ អនុវត្តប្រព័ន្ធត្រួតពិនិត្យសកម្មភាពវិស័យមីន(PMS) | ហៀបនឹងសម្រេចបាន |

*កំណត់សម្គាល់

- ក្រោម ៧០% មិនទាន់សម្រេច
- ចន្លោះពី៧០% ទៅ ៩៥% ហៀបនឹងសម្រេច
- លើស៩៥% សម្រេចបាន
- មិនទាន់មានតម្រូវការក្នុងការអនុវត្ត

សមិទ្ធផលធំធេងដូចបានរៀបរាប់ខាងលើនេះ បានប្រសូត្រចេញពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់រាជរដ្ឋាភិបាលកម្ពុជា ប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ និងប្រតិបត្តិករជាតិ និងអន្តរជាតិក្នុងការរំដោះផ្ទៃដីជូនប្រជាពលរដ្ឋប្រើប្រាស់បង្កបង្កើនផលធ្វើស្រែចម្ការ កសាងភូមិដ្ឋាន កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ កាត់បន្ថយចំនួនជនរងគ្រោះ និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។ ទោះជាយ៉ាងនេះក្តី គ្រាប់មីន គ្រាប់បែកចង្កោម និងស.ផ.ស.ផ្សេងទៀត នៅតែបន្តគំរាមកំហែងចំពោះប្រជាពលរដ្ឋ និងជាឧបសគ្គដល់ការអភិវឌ្ឍ។ សម្រាប់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២១ ដល់២០២៥ កម្ពុជានៅត្រូវការថវិកាប្រមាណ ៣៣៣,២៥លានដុល្លារ ដើម្បីធ្វើការបោសសម្អាតផ្ទៃដីដែលមានគ្រាប់មីនចំនួន ៨០៦ គីឡូម៉ែត្រការ៉េ ផ្ទៃដីដែលមានគ្រាប់បែកចង្កោម ៦៣៤ គីឡូម៉ែត្រការ៉េ និងឆ្លើយតបទៅនឹងស.ផ.ស. ផ្សេងទៀត។

# ជំពូកទី១

## សាវតារ

ប្រទេសកម្ពុជាបានរងគ្រោះដោយសារសង្គ្រាមក្នុងប្រទេសនិងក្នុងតំបន់ ដែលបានអូសបន្លាយចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ចុងឆ្នាំ១៩៩៨។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅខែមករា ឆ្នាំ១៩៧៩ ជម្លោះប្រដាប់អាវុធផ្ទៃក្នុងបានបន្តរហូតដល់ចុងឆ្នាំ១៩៩៨។ ក្នុងអំឡុងពេលសង្គ្រាម ភាគីជម្លោះទាំងអស់សុទ្ធតែបានដាក់ពង្រាយគ្រាប់មីន ជាពិសេសនៅខេត្តភាគខាងលិច និងភាគពាយព្យដែលតាមការប៉ាន់ស្មានគ្រាប់មីនប្រមាណពី ៤ ទៅ ៦លានគ្រាប់ ត្រូវបានគេដាក់ពង្រាយលើផ្ទៃប្រទេស។ ចំណែកនៅខេត្តភាគខាងកើតនៃប្រទេសកម្ពុជា មានគ្រាប់បែកចង្កោម និងស.ផ.ស.ផ្សេងទៀត ដែលជាលទ្ធផលនៃការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់ ក្នុងអំឡុងពេលសង្គ្រាមវៀតណាម។ យោងតាមព័ត៌មានពីក្រសួងការបរទេសសហរដ្ឋអាមេរិកបានឱ្យដឹងថា ចាប់ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧៣ អាមេរិកបានទម្លាក់គ្រាប់បែកចំនួន ២,៧៥លានតោន ក្នុងនោះមានគ្រាប់បែកចង្កោមផងដែរ។

ការស្រាវជ្រាវអំពីមីន និងស.ផ.ស.កម្រិត១ (Level1 Survey-L1S) ដែលបានចាប់ផ្តើមពីខែតុលា ឆ្នាំ ២០០០ ដល់ខែមេសា ឆ្នាំ២០០២ បានបង្ហាញថាភូមិចំនួន ៦.៤១៦ ត្រូវជា ៤៦% នៃចំនួនភូមិសរុបក្នុងប្រទេសកម្ពុជា ទទួលរងផលប៉ះពាល់ដោយសារគ្រាប់មីននិងស.ផ.ស.។ ចាប់តាំងពីឆ្នាំ១៩៧៩មក គ្រាប់មីន និង ស.ផ.ស.បានធ្វើឱ្យមនុស្សរងគ្រោះស្លាប់ និងរងរបួសរាប់ម៉ឺននាក់ បង្កនូវសោកនាដកម្មដ៏ឈឺចាប់ និងធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍប្រទេសជាតិ។ ផ្អែកលើរបាយការណ៍ CMVIS គិតចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ ២០២០ មនុស្សចំនួន ៦៤.៩២០នាក់ បានស្លាប់ រងរបួស និងពិការដោយសារគ្រាប់មីន និងស.ផ.ស.។

កម្មវិធីបោសសម្អាតមីនមនុស្សធម៌នៅប្រទេសកម្ពុជាបានចាប់បដិសន្ធិ នៅឆ្នាំ១៩៩២។ នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩៧ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអូតាវ៉ា ដែលមានប្រទេសចំនួន១៣០ បានចុះហត្ថលេខានាពេលនោះ ហើយក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះនៅថ្ងៃទី១ ខែមករា ឆ្នាំ២០០០។ ប្រទេសកម្ពុជា ក៏បានចូលរួមក្នុងបណ្តាសន្ធិសញ្ញាមនុស្សធម៌ និងនិសញ្ញាវុធការអន្តរជាតិផ្សេងទៀត ផងដែររួមមាន អនុសញ្ញាសព្វាវុធធម្មតាមួយចំនួន



*អ្នកដោះមីនស្ត្រីរបស់CMAC ក្រោមគម្រោងបោសសម្អាតមីនដើម្បីលទ្ធផលកំពុងប្រើដំបងដែកដោយប្រយ័ត្នប្រយែងដើម្បីរកមីនក្នុងចំការមីនខេត្តបន្ទាយមានជ័យ*

(CCW)ពិធីសារ I, II, III និង IV[1] អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) ក៏ដូចជាគំនិតផ្តួចផ្តើមសហប្រតិបត្តិការផ្សេងៗទៀតទាក់ទងនឹងសកម្មភាពមីន។

ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព នៃវិស័យសកម្មភាពមីន នៅឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន(អាជ្ញាធរមីន) ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធាន។ រចនាសម្ព័ន្ធនៃវិស័យសកម្មភាពមីន មានអាជ្ញាធរមីនដែលមានតួនាទីធ្វើនិយ័តកម្ម សម្របសម្រួល និងតាមដានត្រួតពិនិត្យការអនុវត្តសកម្មភាពមីននៅទូទាំងប្រទេស និងមានប្រតិបត្តិករជាតិចំនួនពីរ គឺមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាពបោសសម្អាតមីន និងកាកសំណល់សង្គ្រាម (RCAF/NPMEC) និង មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា (CMAC) និងប្រតិបត្តិករអន្តរជាតិ រួមមាន អង្គការ MAG អង្គការ HALO Trust អង្គការ NPA និង អង្គការ APOPO ព្រមទាំង ប្រតិបត្តិករបោសសម្អាតមីនក្នុងស្រុក អង្គការដោះមីនកម្ពុជា (CSHD)។ បន្ថែមលើនេះ មានអង្គការមិនមែនរាជរដ្ឋាភិបាលអន្តរជាតិ JMAS និងក្រុមហ៊ុនបោសសម្អាតមីនឯកជនដទៃទៀត បានចូលរួមគាំទ្រសកម្មភាពមីន រួមជាមួយបណ្តាស្ថាប័នដែលផ្តល់សារអប់រំពីគ្រោះថ្នាក់ដោយសារគ្រាប់មីន និងស.ផ.ស. និងជួយគាំទ្រដល់ជនរងគ្រោះដោយសារមីន និងស.ផ.ស.។ ប្រទេសកម្ពុជាក៏បានបញ្ជូនអ្នកជំនាញបោសសម្អាតមីន និង ស.ផ.ស. របស់ខ្លួនទៅកាន់បណ្តាប្រទេសដែលរងគ្រោះដោយសារមីន ក្នុងក្របខ័ណ្ឌប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងបានចូលរួមចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់បណ្តាប្រទេសផ្សេងៗទៀត ផងដែរ។



*ការជីករុករករបស់អ្នកដោះមីន អង្គការHALO Trust បង្ហាញពីមីនប្រភេទ ៧២A*

ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០២០ ផ្ទៃដីប្រមាណ ២.១៤៩គម² ត្រូវបានរំដោះ ព្រមទាំងរកឃើញនិងកម្ទេចចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន ១.០៩៥.៧៤២គ្រាប់ មីនប្រឆាំងរថក្រោះចំនួន ២៥.៤៨៨គ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន ២.៩១៤.៩៤៦គ្រាប់។ ទោះបីកម្ពុជាទទួលបាននូវសមិទ្ធផលដ៏ធំធេងលើការបោសសម្អាតមីន និងស.ផ.ស.ក៏ដោយ ក៏កម្ពុជានៅតែប្រឈមនឹងបញ្ហាជាច្រើនពាក់ព័ន្ធនឹងគ្រាប់មីន និង ស.ផ.ស. ដែលនៅតែមានលក្ខណៈស្មុគស្មាញ។ ខេត្តភាគពាយព្យនៅតែបន្តទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារមីន និងស.ផ.ស. ខេត្តភាគកណ្តាលទទួលរងផលប៉ះពាល់ក្នុងកម្រិតមធ្យមដោយសារមីន និង ស.ផ.ស. ចំណែកខេត្តភាគខាងកើតទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារគ្រាប់បែកចង្កោម រួមទាំង

[1] ពិធីសារ I៖ Non-detectable fragments; ពិធីសារ II៖ មីន booby-traps, ឧបករណ៍ផ្សេងៗទៀត ពិធីសារ III៖ Incendiary weapons; ពិធីសារ IV៖ Blinding Laser Weapons.

ស.ផ.ស.ផ្សេងទៀត។ លទ្ធផលនៃការស្រាវជ្រាវចម្ការមីនមូលដ្ឋានបានបង្ហាញថា ផ្ទៃដីចំនួន ២.០៥៧គីឡូម៉ែត្រការ៉េ នៅមានការគំរាមដោយសារមីន និងស.ផ.ស.។




ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួន រាជរដ្ឋាភិបាលបានបង្កើតគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមួយទៀតរបស់កម្ពុជា គឺគោលដៅទី១៨ ស្តីពីការបញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់គ្រាប់មីន និង ស.ផ.ស. និងជំរុញការសង្គ្រោះជនរងគ្រោះ (CSDG18)។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលក៏មានចក្ខុវិស័យច្បាស់លាស់ក្នុងការប្រែក្លាយប្រទេសកម្ពុជាជាប្រទេសដែលគ្មានគ្រាប់មីននៅត្រឹមឆ្នាំ២០២៥ ហើយការគំរាមកំហែងពីស.ផ.ស.ត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ការអភិវឌ្ឍមនុស្សនិងសេដ្ឋកិច្ចសង្គមប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព។ ដើម្បីសម្រេចបាននៅចក្ខុវិស័យនេះ កម្ពុជាត្រូវរំដោះតំបន់ទាំងអស់ដែលដឹងថាមានមីន និងគ្រាប់បែកចង្កោមជាអាទិភាព និងកាត់បន្ថយហានិភ័យដែលនៅសេសសល់បណ្តាលមកពីស.ផ.ស.ផ្សេងទៀតនៅកម្ពុជា និងធ្វើការតស៊ូមតិលើសិទ្ធិនិងផ្តល់សេវាកម្មសម្រាប់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ក៏ដូចជាជនរងគ្រោះដោយប្រយោល។

បន្ទាប់ពីមានការពិនិត្យមើលឡើងវិញផ្នែកបច្ចេកទេស និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ អាជ្ញាធរមីនបានបង្កើតផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥ ស្របតាមផែនការ

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនប្រកបដោយប្រសិទ្ធភាព នៅដើមឆ្នាំ២០១៨ អាជ្ញាធរមីនបានសម្របសម្រួលជាមួយប្រតិបត្តិករ និងភាគីពាក់ព័ន្ធ រៀបចំផែនការសកម្មភាព ៣ឆ្នាំ ២០១៨-២០២០ ដែលរៀបរាប់ពីផែនការសកម្មភាពសម្រាប់សម្រេចបាននូវយុទ្ធសាស្ត្រនីមួយៗ។ ឯកសាររបាយការណ៍នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិពណ៌នាអំពីសមិទ្ធផលដែលសម្រេចបានក្នុងវិស័យមីន ដោយផ្ទៀងផ្ទាត់ជាមួយផែនការសកម្មភាព៣ឆ្នាំ ព្រមទាំងបង្ហាញពីបញ្ហាប្រឈមដែលបានជួបប្រទះក្នុងពេលអនុវត្ត និងលើកជាទិសដៅសម្រាប់បន្តដោះស្រាយនាពេលខាងមុខ។

# ជំពូកទី២

## វិធីសាស្ត្រនិងដំណើរការសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ជំពូកទី២នេះ រៀបរាប់ពីវិធីសាស្ត្ររៀបចំរបាយការណ៍វាយតម្លៃលើផែនការសកម្មភាពរយៈពេល ៣ឆ្នាំ ២០១៨-២០២០ នៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥។ ជំពូកនេះមានពីរផ្នែក ដែលផ្នែកទី១រៀបរាប់ពីវិធីសាស្ត្រនៃការប្រមូល និងវិភាគទិន្នន័យនិងព័ត៌មាន និងផ្នែកទី២ រៀបរាប់ពីការរៀបចំសេចក្ដីព្រាងរបាយការណ៍។

### ២.១ វិធីសាស្ត្រនៃការប្រមូល និងវិភាគទិន្នន័យនិងព័ត៌មាន

ទិន្នន័យដែលយកមកវិភាគសម្រាប់ធ្វើរបាយការណ៍នេះ គឺបានមកពីទិន្នន័យដែលមានស្រាប់នៅក្នុងប្រព័ន្ធទិន្នន័យថ្នាក់ជាតិអាជ្ញាធរមីន ទិន្នន័យដែលបានពីប្រតិបត្តិករ និងឯកសាររបាយការណ៍ផ្សេងៗ។ អាជ្ញាធរមីនបានសហការជាមួយអង្គការ UNDP និងអង្គការ NPA ពិនិត្យមើលសូចនាករដែលមាននៅក្នុងផែនការសកម្មភាពរយៈពេល៣ឆ្នាំ ២០១៨-២០២០ ដើម្បីឈានទៅកំណត់តម្រូវការទិន្នន័យពីភាគីពាក់ព័ន្ធ និងរៀបចំជាទម្រង់ស្នើសុំទិន្នន័យប្រតិបត្តិការ និងឯកសារពាក់ព័ន្ធផ្សេងៗពីប្រតិបត្តិករ ក្នុងគោលបំណងធ្វើការផ្ទៀងផ្ទាត់ និងវិភាគធៀបទៅនឹងសូចនាករ។ ជាមួយគ្នានេះ ទិន្នន័យមានស្រាប់ដែលរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យថ្នាក់ជាតិអាជ្ញាធរមីន គឺអាចយកមកប្រើប្រាស់ក្នុងការវាយតម្លៃសូចនាករមួយចំនួនបាន។ បន្ថែមលើនេះ ឯកសាររបាយការណ៍នៃការអនុវត្តជាក់ស្ដែងរបស់នាយកដ្ឋានអាជ្ញាធរមីនក៏ជាឯកសារសំខាន់ដែលអាចយកមកប្រើប្រាស់ក្នុងការវាយតម្លៃនូវលទ្ធផលដែលសម្រេចបាននៃផែនការសកម្មភាពនេះ។

### ២.២ ដំណើរការនៃការរៀបចំរបាយការណ៍

បន្ទាប់ពីទទួលបានទិន្នន័យពីភាគីពាក់ព័ន្ធ នាយកដ្ឋានជំនាញដែលទទួលបន្ទុកការងារនីមួយៗធ្វើការពិនិត្យគុណភាព និងផ្ទៀងផ្ទាត់ទិន្នន័យជាមួយភាគីពាក់ព័ន្ធ ហើយធ្វើការរៀបចំជាសេចក្ដីព្រាងរបាយការណ៍តាមផ្នែកជំនាញ។ បន្ទាប់មក នាយកដ្ឋានជំនាញនីមួយៗផ្ញើសេចក្ដីព្រាងរបាយការណ៍ទៅនាយកដ្ឋានទំនាក់ទំនងសារជារណៈនៃអាជ្ញាធរមីន ដើម្បីរៀបចំខ្លឹមសាររបាយការណ៍វាយតម្លៃនេះទាំងមូល។ សូមបញ្ជាក់ថា របាយការណ៍នេះនឹងរៀបរាប់តែសូចនាករសំខាន់ៗ ចំណែកឯឧបសម្ព័ន្ធ ខ សមិទ្ធផលនៃការអនុវត្តផែនការសកម្មភាព៣ឆ្នាំ(២០១៨-២០២០)នឹងរៀបរាប់លម្អិតរាល់សូចនាករទាំងអស់។

## ជំពូកទី៣

## ការរំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់ នៅត្រឹមឆ្នាំ២០២៥

រាជរដ្ឋាភិបាលបានចាត់ទុកអភិបាលកិច្ចល្អ ជាគោលដៅមួយនៃយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ជាពិសេសផ្តោតសំខាន់លើការប្រើប្រាស់ធនធានក្រៅប្រទេសឱ្យមានប្រសិទ្ធភាពខ្ពស់ ស្របទៅនឹងស្ថានភាពសេដ្ឋកិច្ចសកល និងតាមការស្នើសុំរបស់ប្រទេសម្ចាស់ជំនួយដែលតម្រូវឱ្យវិស័យមីនវិះរកមធ្យោបាយវិធីសាស្រ្តណាមួយក្នុងការពន្លឿននិងពង្រឹងគុណភាពនៃការបោសសម្អាតមីន។ គោលនយោបាយនិងស្តង់ដារស្តីពីការរំដោះផ្ទៃដីត្រូវបានរៀបចំឡើងដោយមានការចូលរួមពីប្រតិបត្តិករ និងដៃគូពាក់ព័ន្ធផ្សេងទៀត។ ជាមួយគ្នានេះ ប្រតិបត្តិករបោសសម្អាតមីន អាជ្ញាធរមូលដ្ឋាន សហគមន៍ អ្នកប្រើប្រាស់ដី ព្រមទាំងតួអង្គដៃគូអភិវឌ្ឍន៍ផ្សេងទៀត បានចូលរួមក្នុងដំណើការរំដោះផ្ទៃដី ក្នុងនោះមានដូចជាការស្រាវជ្រាវចម្ការមីនមូលដ្ឋាន ការធ្វើផែនការ និងចាត់អាទិភាព ការរំដោះផ្ទៃដី និងការផ្ទេរប្រគល់ផ្ទៃដីជូនម្ចាស់ដីផងដែរ។

ការរំដោះផ្ទៃដី គឺដំណើរការនៃការអនុវត្តគ្រប់មធ្យោបាយដែលសមស្របក្នុងការប្រែក្លាយផ្ទៃដីដែលសង្ស័យ ឬផ្ទៃដីដែលមានការគំរាម ទៅជាផ្ទៃដីដែលអស់ការគំរាម ហើយប្រជាពលរដ្ឋឬអាជ្ញាធរមូលដ្ឋានជឿជាក់ថាអាចប្រើប្រាស់ផ្ទៃដីទាំងនោះបាន ដោយគ្មានការបារម្ភពីគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស.។ គោលនយោបាយរំដោះផ្ទៃដីត្រូវបានតាក់តែងឡើង ដើម្បីកំណត់គោលដៅនៃការប្រើប្រាស់ធនធានដែលសំដៅទៅតំបន់ដែលមានតម្រូវការខ្លាំង តាមរយៈការកំណត់ឱ្យបានច្បាស់នូវស្ថានភាពជាក់ស្តែងនៃវត្តមានមីននិងស.ផ.ស.។

| គោលបំណង | គោលដៅ | ការអនុវត្ត |
| --- | --- | --- |
| ១. រំដោះផ្ទៃដីដែលដឹងថាមានមីនឱ្យអស់ត្រឹមឆ្នាំ២០២៥ | ១.១ បញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិ សម្រាប់បណ្តាស្រុកដែលនៅសេសសល់ទាំងអស់ត្រឹមឆ្នាំ២០២០ | សម្រេចបាន |
| | ១.២ អនុវត្តការរំដោះផ្ទៃដី តាមរយៈការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងធ្វើការស្រាវជ្រាវឡើងវិញ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យដីដែលមានមីន | មិនទាន់សម្រេចបាន |
| | ១.៣ កាត់បន្ថយភូមិអាទិភាពដែលដឹងថាមានមីន នៅត្រឹមឆ្នាំ២០២១ និងភូមិដែលនៅសល់នៅត្រឹមឆ្នាំ២០២៥ | ហៀបនឹងសម្រេចបាន |
| | ១.៤ ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដែលមានស្រាប់ | ហៀបនឹងសម្រេចបាន |

វិធីសាស្រ្តរំដោះផ្ទៃដីអាចជួយឱ្យសន្សំសំចៃធនធាន និងពេលវេលា ដោយផ្តោតលើសកម្មភាពទាំងឡាយណាដែលប្រើប្រាស់ចំណាយទាបនិងទទួលបានទិន្នផលខ្ពស់ ដើម្បីឈានទៅបញ្ចប់ការរំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់នៅត្រឹមឆ្នាំ២០២៥ ដែលនេះជាគោលបំណងទី១ នៅក្នុងផែនការយុទ្ធសាស្រ្តជាតិសកម្មភាពមីន ២០១៨-២០២៥។ ជាលទ្ធផលនៃការអនុវត្តផែនការសកម្មភាពមីនរយៈពេល៣ឆ្នាំ

យើងសម្រេចបាននូវគោលដៅទី១ ក្នុងការបញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិ ចំណែកគោលដៅទី២ គោលដៅទី៣ និងគោលដៅទី៤ គឺមិនទាន់សម្រេចបាននៅឡើយ។

### ៣.១ ការបញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិនៅតាមស្រុកដែលនៅសល់ត្រឹមឆ្នាំ២០២០

ការស្រាវជ្រាវចម្ការមីនមូលដ្ឋានជាសកម្មភាពស្រាវជ្រាវមួយ ដើម្បីប្រមូល និងវិភាគព័ត៌មានពីសហគមន៍ក្នុងមូលដ្ឋានតាមរយៈការប្រជុំភូមិ ដែលមានការចូលរួមពីប្រតិបត្តិករបោសសម្អាតមីន អាជ្ញាធរដែនដី និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងការកំណត់ទំហំនិងចាត់ថ្នាក់លើតំបន់សង្ស័យថាមានមីន។ ដើម្បីកំណត់តំបន់សង្ស័យថាមានមីនឱ្យបានច្បាស់លាស់ ការស្រាវជ្រាវចម្ការមីនមូលដ្ឋានត្រូវបានអនុវត្តនៅក្នុងឆ្នាំ២០០៩ ឈានទៅធ្វើការរំដោះផ្ទៃដីប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ការស្រាវជ្រាវមូលដ្ឋាននាំទៅដល់ការប្រើចំណាត់ថ្នាក់ប្រភេទដីសម្រាប់តំបន់ដែលសង្ស័យថាមានមីន និងស.ផ.ស. រួមមានចំណាត់ថ្នាក់ A ជាតំបន់ដែលមានមីន និងចំណាត់ថ្នាក់ B ជាតំបន់ដែលមានស.ផ.ស.។ ចំណែកប្រភេទដីដែលមានចំណាត់ថ្នាក់ C ជាដីដែលត្រូវបានបោសសម្អាតរួចរាល់ *(សូមមើលលម្អិតក្នុងតារាងចំណាត់ថ្នាក់ផ្ទៃដីក្នុងឧបសម្ព័ន្ធ ក)*។

នៅក្នុងឆ្នាំ២០២០ ការកៀរគរធនធាន និងការស្រាវជ្រាវចម្ការមីនមូលដ្ឋាននៅស្រុកចំនួន ៧៣ ត្រូវបានបញ្ចប់ជាស្ថាពរ ដោយមានការចូលរួមពីប្រតិបត្តិករបោសសម្អាតមីន CMAC អង្គការ HALO Trust អង្គការ MAG និងអង្គការ NPA។ ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនបានកំណត់ ៣៦ស្រុក ដែលនៅសល់ដែលមិនទាន់ធ្វើការស្រាវជ្រាវនៅឡើយ និងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២០ ប៉ុន្តែជាក់ស្តែងនៅសល់ ៣៧ស្រុកទៀត ដែលត្រូវបានស្រាវជ្រាវបានខ្លះតែមិនទាន់ចប់ ដូច្នេះសរុបមាន ៧៣ស្រុក ដែលត្រូវបញ្ចប់។ ស្រុកទាំង៧៣នេះ ត្រូវបានបែងចែកទៅតាមប្រតិបត្តិករនីមួយៗដូចខាងក្រោមផ្អែកលើទីតាំងនៃកម្លាំងនិងធនធានជាក់ស្តែងដូចខាងក្រោម៖

| ប្រតិបត្តិករ | ចំនួនស្រុក | ខេត្ត/ស្រុកបែងចែក |
|---|---|---|
| អង្គការ HALO Trust | ១៤ស្រុក | • ខេត្តកំពង់ឆ្នាំង (ស្រុកបរិបូណ៌ ស្រុកកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច ស្រុករលាប្អៀរ)<br>• ខេត្តកំពង់ស្ពឺ (ច្បារមន)<br>• ខេត្តកណ្តាល (ស្រុកគៀនស្វាយ ស្រុកល្វាឯម ស្រុកមុខកំពូល ស្រុកស្អាង ស្រុកលើកដែក ក្រុងតាខ្មៅ ស្រុកកណ្តាលស្ទឹង)<br>• ខេត្តកោះកុង (ក្រុងខេមរភូមិន្ទ)<br>• ខេត្តពោធិ៍សាត់ (ស្រុកពោធិ៍សាត់) |
| អង្គការ MAG | ១២ស្រុក | • ខេត្តកំពត (ស្រុកកំពត)<br>• ខេត្តព្រះសីហនុ (ក្រុងព្រះសីហនុ ស្រុកស្ទឹងហាវ)<br>• ខេត្តតាកែវ (ស្រុកគីរីវង្ស ស្រុកទ្រាំង ស្រុកសំរោង ស្រុកព្រៃកប្បាស ស្រុកដូនកែវ ស្រុកបាទី ស្រុកកោះអណ្តែត ស្រុកអង្គបូរី ស្រុកបូរីជលសារ) |
| អង្គការ NPA | ៨ស្រុក | • ខេត្តរតនគីរី (ស្រុកអណ្តូងមាស ស្រុកបានលុង ស្រុកបរកែវ ស្រុកកូនមុំ ស្រុកលំផាត់ ស្រុកអូរជុំ ស្រុកតាវែង ស្រុកវើនសៃ) |

| | | |
|---|---|---|
| CMAC/ អង្គការ NPA | ២៧ស្រុក | • ខេត្តកំពង់ចាម (ស្រុកស្ទឹងត្រង់)<br>• ខេត្តក្រចេះ (ស្រុកចិត្របុរី ស្រុកឆ្លូង ស្រុកសំបូរ)<br>• ខេត្តមណ្ឌលគិរី (ស្រុកកែវសីម៉ា ស្រុកអូររាំង ក្រុងសែនមនោរម្យ)<br>• ខេត្តព្រៃវែង (ស្រុកបាភ្នំ ស្រុកកំចាយមារ ស្រុកកំពង់ត្របែក ស្រុកកញ្ជ្រៀច ស្រុកមេសាង ស្រុកពារាំង ស្រុកពាមជរ ស្រុកពាមរ ស្រុកព្រៃវែង ស្រុកពោធិ៍រៀង ស្រុកស៊ីធរកណ្តាល ស្រុកស្វាយអន្ទរ)<br>• ខេត្តស្ទឹងត្រែង (ស្រុកសេសាន ស្រុកស្ទឹងត្រែង)<br>• ខេត្តស្វាយរៀង (ស្រុករមាសហែក ស្រុកស្វាយជ្រំ ស្រុកស្វាយរៀង ស្រុកបាវិត)<br>• ខេត្តត្បូងឃ្មុំ (ស្រុកអូររាំងឪ ស្រុកសួង) |
| CMAC | ១២ខណ្ឌ | រាជធានីភ្នំពេញ (ខណ្ឌពោធិ៍សែនជ័យ ... ) |

លទ្ធផលការស្រាវជ្រាវចម្ការមីនមូលដ្ឋានទៅលើស្រុកចំនួន៧៣ បានរកឃើញថា មានចម្ការមីន និងស.ផ.ស. ចំនួន **១.៩៧៥ ចម្ការ** ដែលមានផ្ទៃដីសរុប **២៨៥គម**$^{២}$។ ការស្រាវជ្រាវចម្ការមីនមូលដ្ឋាននៅស្រុកទាំង៧៣ដែលនៅសេសសល់ ត្រូវបានចប់សព្វគ្រប់នៅទូទាំងប្រទេសនៅឆ្នាំ២០២០ ស្របតាមផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន។ គិតត្រឹមបំណាច់ឆ្នាំ២០២០ លទ្ធផលពីការស្រាវជ្រាវចម្ការមីនមូលដ្ឋានបានបង្ហាញថា ផ្ទៃដីសរុបទំហំ **២.០៥៧គម**$^{២}$ នៅតែស្ថិតក្នុងបញ្ជីផ្ទៃដីដែលសង្ស័យមានមីនគ្រាប់បែកចង្កោម និងស.ផ.ស.ផ្សេងទៀត។ នេះគឺជាលទ្ធផលនៃការសម្រេចបាននូវគោលដៅទី១ នៃគោលបំណងទី១ នៅក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន។



## ៣.២ ការអនុវត្តការរំដោះផ្ទៃដីតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្រ្ទាន ប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងធ្វើការស្រាវជ្រាវឡើងវិញ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យដីដែលមានមីន

អនុលោមតាមសេចក្តីថ្លែងការណ៍ Maputo+១៥ ក្នុងសន្និបាតពិនិត្យឡើងវិញលើកទី៣ នៃអនុសញ្ញាអូតាវ៉ា នៅទីក្រុងម៉ាពុយតូ ប្រទេសម៉ូសំប៊ិក (Mozambique) កម្ពុជាបានប្តេជ្ញាចិត្តថានឹងធ្វើការបោសសម្អាតតំបន់ទាំងអស់ដែលដឹងថាមានមីននៅត្រឹមឆ្នាំ២០២៥។ ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តនេះ នៅក្នុងរយៈពេល ៨ឆ្នាំ កម្ពុជានឹងត្រូវបង្កើនផលិតភាពនៃការរំដោះផ្ទៃដីមានមីនក្នុងមួយឆ្នាំឱ្យបាន ១៧% មានន័យថា ត្រូវរំដោះផ្ទៃដីដែលដឹងថាមានមីនទំហំ ១១០គម² ក្នុងមួយឆ្នាំ។

ដើម្បីសម្រេចបាននូវការរំដោះផ្ទៃដីដែលសង្ស័យមានមីនដែលបានកំណត់ខាងលើ ការស្រាវជ្រាវមិនបច្ចេកទេសគឺជាចំណុចសំខាន់នៃការរំដោះផ្ទៃដី។ ផ្អែកលើបទពិសោធន៍នៃការអនុវត្តការរំដោះផ្ទៃដីកន្លងមក និងការវិភាគទិន្នន័យពីមូលដ្ឋានក្នុងទិន្នន័យថ្នាក់ជាតិអាជ្ញាធរមីន បានបង្ហាញថានៅក្នុងតំបន់ដែលសង្ស័យថាមានមីន គឺយើងអាចរំដោះផ្ទៃដីដែលសង្ស័យបានប្រមាណ **៤០%** តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស នៅលើដី ដែលបានកំណត់ថាជាដីទន្រ្ទានប្រើប្រាស់ និងលុបចោលជាតំបន់សង្ស័យដែលបានបញ្ជាក់ថាគ្មានវត្ថុមានមីន (C1) និង **៦០%** តាមរយៈការស្រាវជ្រាវបច្ចេកទេស (C2) និងបោសសម្អាតទាំងស្រុង (C3)។ ការកំណត់នេះគឺប្រហាក់ប្រហែលទៅនឹងសមិទ្ធផលដែលយើងបានសម្រេចសម្រាប់រយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០១៨-២០២០ កន្លងទៅនេះ។

ជាមួយគ្នានេះ ដោយសារចម្ការមីនមួយចំនួនមានអាយុកាលច្រើនឆ្នាំ និងត្រូវបានប្រជាជនទន្រ្ទានប្រើប្រាស់ ដូច្នេះអាជ្ញាធរមីន និងប្រតិបត្តិករបានសហការធ្វើការស្រាវជ្រាវមិនបច្ចេកទេស ដើម្បីកំណត់ចម្ការមីនដែលត្រូវបានទន្រ្ទានប្រើប្រាស់ ក្នុងគោលបំណងពង្រឹងសុវត្ថិភាពដីជូនប្រជាជន និងលុបចេញនូវទិន្នន័យផ្ទៃដីសង្ស័យទាំងនេះចេញពីប្រព័ន្ធទិន្នន័យមីននិងស.ផ.ស.ថ្នាក់ជាតិ។ ជាលទ្ធផល គិតចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ២០២០ ចម្ការមីនចំនួន **៣.៥៥៨** ស្មើនឹងផ្ទៃដី **៩២.៣៩៤.៧០៤ម²** ត្រូវបានរំដោះតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ដែលស្មើនឹង**៣៣%** នៃផ្ទៃដីដែលសង្ស័យថាមានមីនដែលបានរំដោះសរុប។

**លទ្ធផលនៃការរំដោះផ្ទៃដីដែលសង្ស័យថាមានមីនបែងចែកទៅតាមនីតិវិធីប្រតិបត្តិការ**

| ឆ្នាំ | ការស្រាវជ្រាវមិនបច្ចេកទេស (C1) (ម៉ែត្រការ៉េ) | | ការស្រាវជ្រាវបច្ចេកទេសនិងបោសសម្អាតទាំងស្រុង (C2+C3) (ម៉ែត្រការ៉េ) | | សរុបផ្ទៃដីមីនដែលបានរំដោះ (ម៉ែត្រការ៉េ) |
|---|---|---|---|---|---|
| ២០១៨ | ៣៣.៣៦៩.៦៨៧ | ៣៥% | ៦០.៨២៦.២០០ | ៦៥% | ៩៤.១៩៥.៨៨៧ |
| ២០១៩ | ៣៤.១៤៩.១៥៨ | ៣៧% | ៥៧.២២១.០៣២ | ៦៣% | ៩១.៣៧០.១៩០ |
| ២០២០ | ២៤.៨៧៥.៨៥៩ | ២៦% | ៦៩.៩១១.៩៧៣ | ៧៤% | ៩៤.៧៨៧.៨៣២ |
| សរុប (ម៉ែត្រការ៉េ) | ៩២.៣៩៤.៧០៤ | ៣៣% | ១៨៧.៩៥៩.២០៥ | ៦៧% | ២៨០.៣៥៣.៩០៩ |




ដើម្បីបង្កើនផលិតភាពឆ្ពោះទៅសម្រេចបាននូវទិសដៅដែលបានកំណត់ កម្ពុជានឹងពន្លឿនការបោសសម្អាតមីន ដោយប្រើប្រាស់វិធីសាស្ត្រដែលបានកែលម្អ បច្ចេកវិទ្យានវានុវត្ត និងសត្វហិតរកគ្រឿងផ្ទុះ សម្រាប់ការរំដោះផ្ទៃដីប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ប្រព័ន្ធគ្រប់គ្រងគុណភាពដ៏រឹងមាំមួយក៏ត្រូវបានរក្សា និងពង្រឹងផងដែរ ដើម្បីឱ្យអ្នកទទួលផល ប្រតិបត្តិករ និងអាជ្ញាធរមីនមានទំនុកចិត្តថា លក្ខខណ្ឌតម្រូវនៃគុណភាព និងការបោសសម្អាតត្រូវបានបំពេញ ហើយផ្ទៃដីដែលបានរំដោះតាមរយៈការស្រាវជ្រាវមិនបច្ចេកទេសនេះមានសុវត្ថិភាពគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់។ ទោះបីយើងហៀបនឹងសម្រេចបាននៅក្នុងក្របខ័ណ្ឌបច្ចេកទេស ប៉ុន្តែការអនុវត្តសកម្មភាពរំដោះផ្ទៃដីតាមរយៈការស្រាវជ្រាវមិនបច្ចេកទេសនេះ ដែលជាគោលដៅទី២នៃគោលបំណងទី១ នៅក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន មិនទាន់សម្រេចបាននៅឡើយ ដែលតម្រូវឱ្យមានការកៀរគរធនធានហិរញ្ញវត្ថុ សម្ភារបរិក្ខារ និងការចូលរួមយ៉ាងពេញលេញពីប្រតិបត្តិករដែលមានសមត្ថភាពបន្ថែមទៀត។

## ៣.៣ ការរំដោះភូមិអាទិភាពដែលដឹងថាមានមីន នៅត្រឹមឆ្នាំ២០២១ និងភូមិដែលនៅសល់នៅត្រឹមឆ្នាំ ២០២៥

ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ផ្តោតទៅលើការសម្រេចឱ្យបាននូវគោលដៅកម្ពុជាមួយដែលគ្មានមីននៅត្រឹមឆ្នាំ២០២៥។ គោលដៅទី៣នៃគោលបំណងទី១ នៅក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនបានបញ្ជាក់ថា វិស័យមីននឹងរំដោះភូមិអាទិភាពដែលដឹងថាមានមីនទាំងអស់ត្រឹមឆ្នាំ២០២១ និងភូមិនៅសេសសល់ផ្សេងៗទៀតនៅត្រឹមឆ្នាំ២០២៥។ ដើម្បីសម្រេចបាននូវការងារនេះប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល អាជ្ញាធរមីនបានរៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធដើម្បីរៀបចំផែនការក៏ដូចជាបញ្ជីភូមិអាទិភាពដែលមានមីន សម្រាប់ពង្រាយកម្លាំងបោសសម្អាតមីន។ ជាមួយគ្នានេះ អាជ្ញាធរមីនក៏បានសម្រេចរៀបចំជាសេចក្តីណែនាំ ដើម្បីឈានទៅសម្រេចបាននូវភូមិដែលអស់ការគំរាម។ ពាក្យថា **«ភូមិអស់ការគំរាម»** មានន័យថា ភូមិដែលមានដីរងការគំរាមដោយសារមីន ទាំង

អស់ដែលយើងបានដឹងត្រូវបានបោសសម្អាត ដោយមិនគិតថាដីនោះត្រូវបានប្រើប្រាស់ក្នុងគោលបំណង អ្វីមួយ ឬដីនោះនឹងប្រែក្លាយទៅជាកម្មសិទ្ធិជនណាក្រោយពេលបោសសម្អាតរួច។ នេះមានន័យថា នៅពេលដែលក្រុមបោសសម្អាតមីនបានបញ្ជូនទៅក្នុងភូមិណាមួយ ក្រុមនោះនឹងបំពេញការងារបោសសម្អាតមីននៅក្នុងភូមិនោះរហូតទាល់តែផ្ទៃដី ដែលយើងបានដឹងថាមានការគំរាមត្រូវបានបោសសម្អាតរួចរាលជាស្ថាពរ។

អាជ្ញាធរមីនបានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកស្រាវជ្រាវនិងបោសសម្អាតមីន និង ស.ផ.ស. កាលពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ នៅទីរួមខេត្តបាត់ដំបង ក្នុងគោលបំណងពិភាក្សា និងផ្ទៀងផ្ទាត់ទិន្នន័យភូមិដែលអស់មីនដែលសម្រេចបាននាពេលកន្លងមក ព្រមទាំងបានរៀបចំគោលការណ៍ណែនាំពាក់ព័ន្ធភូមិអស់ការគំរាម (Mine Free Village)។

ក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ផ្ទៃដីដែលសង្ស័យថាមានមីនសរុបប្រមាណ **២៨០.៣៥៣.៩០៩ម²** ត្រូវបានរំដោះដោយប្រតិបត្តិករទាំងអស់ ដើម្បីគាំទ្រការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សេដ្ឋកិច្ចសង្គមក៏ដូចជាការកាត់បន្ថយគ្រោះថ្នាក់ ប្រសិនបើប្រៀបធៀបសមិទ្ធផលនេះទៅនឹងផែនការសរុបសម្រាប់រយៈពេល៣ឆ្នាំ ដែលគ្រោងនឹងសម្រេចឱ្យបានទំហំ **៣២៨.០០០.០០០ម²** គឺកម្ពុជាសម្រេចបានស្មើនឹង **៨៥%** នៃផែនការដែលបានគ្រោងទុក។

**សមិទ្ធផលនៃការរំដោះផ្ទៃដីដែលសង្ស័យមានមីនធៀបនឹងផែនការ**

| | ផ្ទៃដីដែលសង្ស័យថាមានមីន ត្រូវបានរំដោះ(ម៉ែត្រការ៉េ) | ផ្ទៃដីដែលសង្ស័យថាមានមីន កំណត់ក្នុងផែនការ(ម៉ែត្រការ៉េ) | ភាគរយសមិទ្ធផល ដែលសម្រេចបាន |
|---|---|---|---|
| ២០១៨ | ៩៤.១៩៥.៨៨៧ | ១០៩.៦០០.០០០ | ៨៦% |
| ២០១៩ | ៩១.៣៧០.១៩០ | ១០៩.៦០០.០០០ | ៨៣% |
| ២០២០ | ៩៤.៧៨៧.៨៣២ | ១០៩.៦០០.០០០ | ៨៦% |
| សរុប | ២៨០.៣៥៣.៩០៩ | ៣២៨.៨០០.០០០ | ៨៥% |




ការកាត់បន្ថយភូមិអាទិភាពដែលដឹងថាមានមីននៅត្រឹមឆ្នាំ២០២១ និងភូមិដែលនៅសេសសល់ត្រឹមឆ្នាំ២០២៥ គឺជាគោលដៅទី៣នៃគោលបំណងទី១ ដែលជាគោលដៅសំខាន់នៃការរំដោះផ្ទៃដី ជារួមយើងសម្រេចបានប្រមាណ៨៥% មានន័យថាយើងហៀបនឹងសម្រេចបាន។ ទោះបីសមិទ្ធផលដែលសម្រេចបាននៅមានការខ្វះខាតខ្លះ បើប្រៀបធៀបនឹងផែនការនេះក៏ដោយសារកង្វះខាតថវិកាប្រមាណប្រហែល៤០%។ ការធ្វើផែនការនិងការចាត់អាទិភាព ដោយហ្មត់ចត់ និងការអនុវត្តវិធីសាស្ត្ររំដោះផ្ទៃដីប្រកបដោយប្រសិទ្ធភាព ជាពិសេសតាមរយៈការស្រាវជ្រាវមិនបច្ចេកទេសបានរួមចំណែកក្នុងការសម្រេចបានសមិទ្ធផលនេះ។

## ៣.៤ ការពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដែលមានស្រាប់

និយ័តកម្ម និងការតាមដានត្រួតពិនិត្យ គឺជាផ្នែកដ៏សំខាន់នៃការគ្រប់គ្រងគុណភាពប្រតិបត្តិការសកម្មភាពមីនដែលប្រកបដោយប្រសិទ្ធភាព ហើយគឺជាអាណត្តិរបស់អាជ្ញាធរមីនដែលត្រូវលើកស្ទួយ និងថែរក្សាឱ្យមាននិរន្តរភាព។ និយ័តកម្មនិងការតាមដានត្រួតពិនិត្យមានគោលបំណងពង្រឹងអនុលោមភាពស្របតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីស្តង់ដារ ដែលបានដាក់ចេញដោយអាជ្ញាធរមីន ដើម្បីធានាថាប្រតិបត្តិការសកម្មភាពមីនមានភាពស្របច្បាប់ ប្រសិទ្ធភាព ប្រសិទ្ធផល និងសុវត្ថិភាព ក៏ដូចជាបំពេញបន្ថែមលើគោលនយោបាយ យុទ្ធសាស្ត្រ និងអាទិភាពជាតិ។ នេះជាគោលដៅទី៤ នៃគោលបំណងទី១ ដែលមានក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ដែលការងារនេះជារួមយើងហៀបនឹងសម្រេចបាន។ ការពង្រឹងការធ្វើនិយ័តកម្ម និងការតាមដានត្រួតពិនិត្យជាប់ជាប្រចាំ ធ្វើឱ្យការអនុវត្តវិធីសាស្ត្ររំដោះផ្ទៃដីកាន់តែមានប្រសិទ្ធភាពក្នុងការគាំទ្រដល់ការសម្រេចបាននូវគោលដៅ និងគោលបំណងនៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីននេះ។

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ គណៈកម្មាធិការត្រួតពិនិត្យនិងកែលម្អស្តង់ដារកំចាត់មីនកម្ពុជា បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ក្នុងគោលបំណងពង្រឹងសុវត្ថិភាព និងពន្លឿនការងារបោសសម្អាតមីន ដោយបានពិនិត្យនិងកែសម្រួលស្តង់ដារកំចាត់មីនកម្ពុជាជំពូកទី០២ ស្តីពីការផ្តល់ប័ណ្ណទទួលស្គាល់ប្រតិបត្តិករដោះមីន និងការផ្តល់អាជ្ញាប័ណ្ណសម្រាប់កិច្ចប្រតិបត្តិការ និងជំពូកទី១៥ ស្តីពីការកាត់បន្ថយផ្ទៃដីចម្ការមីន ព្រមទាំងបានបង្កើតស្តង់ដារកំចាត់មីនកម្ពុជាជំពូកថ្មីចំនួន៣គឺ ជំពូកទី១៦ ជំពូកទី១៧ និងជំពូកទី១៩។ ជាមួយគ្នានេះ ស្តង់ដារកំចាត់មីនកម្ពុជាជំពូកថ្មីចំនួន ៣ទៀត ដែលបាននិងកំពុងរៀបចំក្នុងនោះមានជំពូកទី១២ ជំពូកទី១៨ និងជំពូកទី២០។

| ស្តង់ដារកំចាត់មីនកម្ពុជា | បរិយាយ | វឌ្ឍនភាព |
|---|---|---|
| ជំពូកទី២ | ស្តីពីប័ណ្ណទទួលស្គាល់ប្រតិបត្តិករដោះមីន និងការផ្តល់អាជ្ញាប័ណ្ណសម្រាប់កិច្ចប្រតិបត្តិការ | បានពិនិត្យ និងកែសម្រួលឡើងវិញ |
| ជំពូកទី១២ | ស្តីពីគ្រឿងចក្របោសសម្អាតមីន | បង្កើតថ្មី នៅជាសេចក្តីព្រាង |
| ជំពូកទី១៥ | ស្តីពីការកាត់បន្ថយផ្ទៃដីចម្ការមីន | បានពិនិត្យ និងកែសម្រួលឡើងវិញ |
| ជំពូកទី១៦ | ស្តីពីការស្រាវជ្រាវគ្រាប់បែកចង្កោម | ត្រូវបានបញ្ចប់ និងអនុម័ត |
| ជំពូកទី១៧ | ស្តីពីការគ្រប់គ្រងព័ត៌មាន | ត្រូវបានបញ្ចប់ និងអនុម័ត |
| ជំពូកទី១៨ | ស្តីពីសត្វហិតរកគ្រឿងផ្ទុះ | បង្កើតថ្មី នៅជាសេចក្តីព្រាង |
| ជំពូកទី១៩ | ស្តីពីការគ្រប់គ្រងគុណភាពក្នុងសកម្មភាពមីន | ត្រូវបានបញ្ចប់ និងអនុម័ត |
| ជំពូកទី២០ | ស្តីពីការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន | បង្កើតថ្មី នៅជាសេចក្តីព្រាង |




*គ្រឿងចក្រជួយពន្លឿនដល់ការបោសសម្អាតមីនរបស់ CMAC សម្រាប់ការអភិវឌ្ឍសហគមន៍*

ក្រៅពីការត្រួតពិនិត្យ និងកែសម្រួលស្តង់ដារសកម្មភាពកំចាត់មីន ដើម្បីបង្កើនប្រសិទ្ធភាពការងារស្រាវជ្រាវ និងបោសសម្អាតមីន/ស.ផ.ស. ប្រតិបត្តិករជាតិ និងអន្តរជាតិបានខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវ និងបង្កើតបច្ចេកវិទ្យាថ្មីៗ តាមរយៈការសហការផ្លាស់ប្តូរបទពិសោធន៍ និងចូលរួមវគ្គហ្វឹកហ្វឺននានាទាំងក្នុងតំបន់ និងឆាកអន្តរជាតិ។ បច្ចេកវិទ្យាថ្មីៗក្នុងដំណើរការស្រាវជ្រាវ និងបោសសម្អាតមីន រួមមាន ការប្រើប្រាស់ដ្រូន (Drone) ការប្រើប្រាស់សុនខបំពាក់ដោយប្រព័ន្ធបញ្ជា (Remote Sensor) ការប្រើប្រាស់គ្រឿងចក្រដោយបញ្ជាពីចម្ងាយ (Remote Control) ដែលបច្ចេកវិទ្យាទាំងនេះសុទ្ធតែបានជួយពន្លឿន និងបង្កើនប្រសិទ្ធភាពការងារស្រាវជ្រាវ និងបោសសម្អាតមីន និងស.ផ.ស.។

CMAC បានសហការជាមួយសាកលវិទ្យាល័យ Tohohu នៅប្រទេសជប៉ុន បន្តធ្វើការស្រាវជ្រាវលើឧបករណ៍រាវរក និងផ្តិតយក រូបភាពគ្រាប់មីន (Dual sensors detector – Advanced Landmine Imaging System ហៅកាត់ថា ALIS) ដែលការស្រាវជ្រាវនេះស្ថិតនៅដំណាក់កាលសាកល្បង ដោយបានធ្វើឡើងនៅកងឯកភាពកំចាត់មីនទី១ និងទី២ របស់ CMAC។ ជាមួយគ្នានេះ CMAC បានសហការជាមួយក្រុមហ៊ុនជប៉ុន Innovative Operations System (IOS) ធ្វើការស្រាវជ្រាវលើសមត្ថភាពមនុស្សយន្តដោះមីន (Demining Robot) ក្នុងការជីកកកាយរកគ្រាប់មីនប្រឆាំងមនុស្ស។ ដើម្បីពន្លឿនកិច្ចប្រតិបត្តិការស្រាវជ្រាវ CMAC បានសហការជាមួយប្រតិបត្តិករអន្តរជាតិ APOPO ធ្វើការស្រាវជ្រាវបច្ចេកទេសដោយប្រើប្រាស់សុនខ (Technical Survey Dog) បំពាក់ដោយកាំម៉េរ៉ា និងGPS រួមទាំងប្រព័ន្ធបញ្ជាស្វ័យប្រវត្តិ ព្រមទាំងប្រើប្រាស់សត្វកណ្តុរហិតមីនផងដែរ។ ការសាកល្បងប្រតិបត្តិការនេះបានប្រព្រឹត្តទៅនៅខេត្តព្រះវិហារ។



*ការប្រើប្រាស់សត្វកណ្តុរក្នុងការបោសសម្អាតមីនមនុស្សធម៌នៅខេត្តសៀមរាប គម្រោងកិច្ចសហប្រតិបត្តិការរវាងអង្គការ APOPO និង CMAC*

អង្គការ MAG បានសហការជាមួយក្រសួងការពារជាតិនៃសហរដ្ឋអាមេរិក ដើម្បីពន្លឿនការបោសសម្អាតមីន ដោយប្រើគ្រឿងចក្រជាជំនួយក្នុងការរៀបចំផ្ទៃដីចម្ការមីនសម្រាប់ធ្វើការបោសសម្អាត។ បន្ថែមលើនេះ អង្គការ MAG បានដាក់ឱ្យប្រើប្រាស់នូវម៉ាស៊ីនរាវមីន (HSTAMIDS dual sensor detectors) ទៅក្នុងការបោសសម្អាតមីនដោយដៃ។ ចំណែកនៅភាគខាងកើតប្រទេស អង្គការ MAG បានសាកល្បងកែសម្រួលបច្ចេកវិទ្យាចាស់នៃការរាវរកគ្រាប់បែកចង្កោម ដោយមានការដាក់បញ្ចូលឧបករណ៍ចាប់សញ្ញាសម្លេងចំនួនពីរកម្រិតខ្ពស់ដែលមានសមត្ថភាពច្រានចោលសញ្ញាសម្លេង



*ប្រតិបត្តិករជាតិ CMAC ប្រើសុនខដើម្បីជាជំនួយក្នុងការស្វែងរកមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម*

រំខាននៃសារធាតុលោហៈ ដែលនៅក្នុងដីប្រសើរជាងមុន។ ជាមួយគ្នានេះ អង្គការ MAG នៅតែបន្តសាកល្បងដាក់បញ្ចូល ឱ្យប្រើប្រាស់នូវឧបករណ៍រាវរកគ្រាប់មីន/ស.ផ.ស. មានដូចជា Scorpion និង Vallon VMX 10 ក្នុងប្រតិបត្តិការ។

តាមរយៈភាពជាដៃគូរវាងអង្គការ MAG, NPA, HALO Trust និងអាជ្ញាធរមីន អង្គការ HALO Trust បានគាំទ្រការផ្តួចផ្តើមក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញ សម្រាប់ក្រុមការងាររៀបចំផែនការបោសសម្អាតមីន(MAPU) ជាជំនួយក្នុងការចាត់អាទិភាព ដើម្បី កសាងផែនការប្រចាំឆ្នាំ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពបោសសម្អាតមីន និងស.ផ.ស. នៅកម្ពុជា។ ជាមួយគ្នានេះ ដើម្បីសម្រួលដល់ការបោសសម្អាតចម្ការមីនដែលមានស្ថានភាពពិបាក ជាពិសេសក្នុងតំបន់ភ្នំដែលមានលក្ខណៈពិបាកសម្រាប់បុគ្គលិកដោះមីនចូលទៅដល់ អង្គការ HALO Trust បានធ្វើការសាកល្បងប្រើប្រាស់គ្រឿងចក្រជីកកកាយដែលមានរូបរាងដូចជាសត្វពីងពាង ដើម្បីពន្លឿនការងារបោសសម្អាតមីននៅតំបន់ភ្នំ។

# ជំពូកទី៤

## ការរំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹម ឆ្នាំ២០២៥

ក្រៅពីការប្តេជ្ញាចិត្តដើម្បីរំដោះផ្ទៃដីទាំងអស់ដែលដឹងថាមានមីននៅត្រឹមឆ្នាំ២០២៥ កម្ពុជានឹងបន្តដោះស្រាយបញ្ហាគ្រាប់បែកចង្កោម ដែលភាគច្រើននៅភាគខាងកើតប្រទេស។ ផ្ទៃដីសរុបដែលមានគ្រាប់បែកចង្កោមត្រូវធ្វើការរំដោះមានទំហំ ៦៤៥គម២។ ផ្អែកតាមសកម្មភាពអភិវឌ្ឍន៍និងយោបល់របស់អ្នកជំនាញ កម្ពុជាប្តេជ្ញាបោសសម្អាតផ្ទៃដីដែលមានគ្រាប់បែកចង្កោមឱ្យបាន៨០% ឬស្មើនឹង ៤៩៩គម២ នៅត្រឹមឆ្នាំ២០២៥ ហើយផ្ទៃដីដែលនៅសល់ ២០% ត្រូវចាត់ទុកជាការគំរាមគំហែងដែលនៅសេសសល់ (Residual Threat)។

ដើម្បីសម្រេចបានគោលដៅ ក្នុងការរំដោះផ្ទៃដីដែលមានគ្រាប់បែកចង្កោមជាអាទិភាព វិស័យសកម្មភាពមីននឹងត្រូវពន្លឿនដំណើរការ តាមរយៈការប្រើប្រាស់វិធីសាស្ត្រដែលត្រូវបានកែលម្អរួច ដូចជាការស្រាវជ្រាវគ្រាប់បែកចង្កោម តាមរយៈការរួមបញ្ចូលគ្នានូវវិធីសាស្ត្រស្រាវជ្រាវមិនបច្ចេកទេស និងវិធីសាស្ត្រស្រាវជ្រាវបច្ចេកទេស ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវតំបន់ ដែលមានគ្រោះថ្នាក់ ក៏ដូចជាការប្រើប្រាស់បច្ចេកវិទ្យាច្នៃប្រឌិតថ្មីនិងប្រព័ន្ធរាវគ្រាប់ដោយប្រើសត្វសម្រាប់ការរំដោះផ្ទៃដីប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។



*ក្រុមបោសសម្អាតរបស់អង្គការ MAG កំពុងប្រើឧបករណ៍ស្វែងរកគ្រាប់បែកចង្កោមនៅក្នុងតំបន់សង្ស័យ*

សម្រាប់គោលបំណងទី២ ក្នុងការរំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹមឆ្នាំ២០២៥ គឺយើងសម្រេចបាននូវគោលដៅទី១ ក្នុងការរៀបចំផែនការនិងចាត់អាទិភាពតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម។ ចំពោះគោលដៅទី២ ដែលពាក់ព័ន្ធនឹងការស្រាវជ្រាវនិងរំដោះផ្ទៃដីដែលត្រូវបានបញ្ជាក់ថាមានគ្រាប់បែកចង្កោម នៅមិនទាន់សម្រេចបាននៅឡើយ។

| គោលបំណង | គោលដៅ | ការអនុវត្ត |
|---|---|---|
| ២. រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពត្រឹមឆ្នាំ២០២៥ | ២.១ រៀបចំផែនការ និងចាត់អាទិភាពតំបន់ដែលដឹងថាមានគ្រាប់បែកសង្កោម | សម្រេចបាន |
| | ២.២ ធ្វើការស្រាវជ្រាវ និងរំដោះផ្ទៃដីដែលត្រូវបានបញ្ជាក់ថាមានគ្រាប់បែកចង្កោម | មិនទាន់សម្រេចបាន |

## ៤.១ ការរៀបចំផែនការ និងចាត់អាទិភាពតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម

ដើម្បីរៀបចំផែនការ និងចាត់អាទិភាពតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម កិច្ចប្រជុំពិគ្រោះយោបល់នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើងជាមួយប្រតិបត្តិករជាតិ-អន្តរជាតិ មន្ត្រីម៉ាពូ អាជ្ញាធរមូលដ្ឋាន និងក្រសួងស្ថាប័នដែលពាក់ព័ន្ធ ហើយជាលទ្ធផលកិច្ចប្រជុំបានកំណត់នូវឃុំអាទិភាព និងចម្ការគ្រាប់បែកចង្កោមសម្រាប់ធ្វើការបោសសម្អាត។ នេះគឺជាគោលដៅទី១ នៃគោលបំណងទី២ នៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥ ។

## ៤.២ ការធ្វើការស្រាវជ្រាវ និងរំដោះផ្ទៃដីដែលត្រូវបានបញ្ជាក់ថាមានគ្រាប់បែកចង្កោម

ដើម្បីអាចរៀបចំផែនការមួយបានច្បាស់លាស់ ចំគោលដៅ ឈានទៅប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព គណៈកម្មាធិការត្រួតពិនិត្យនិងកែលម្អស្តង់ដារកំចាត់មីន បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ដើម្បីរៀបចំស្តង់ដារជាតិជំពូកទី១៦ ស្តីពីការធ្វើការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម ហើយស្តង់ដារនេះក៏ត្រូវបានអនុម័តក្នុងឆ្នាំ ២០១៩។



*រូបភាពគ្រាប់បែកចង្កោមដែលត្រូវបានរកឃើញនៅភាគខាងកើតប្រទេសកម្ពុជា*

ស្តង់ដារជំពូកទី១៦នេះ ផ្តល់ការណែនាំពីវិធីសាស្ត្រ ដែលជាការរួមបញ្ចូលគ្នារវាងការស្រាវជ្រាវមិនបច្ចេកទេស និងបច្ចេកទេសលើតំបន់សង្ស័យថាមានគ្រាប់បែកចង្កោម (Suspected Hazard Area – SHA) ដើម្បីឈានទៅ ដល់ការកំណត់តំបន់ដែលមានគ្រាប់បែកចង្កោមពិត (Confirmed Hazard Area-CHA) ។ បន្ទាប់ពីស្តង់ដារនេះត្រូវបានអនុម័ត អាជ្ញាធរមីនបានរៀបចំកិច្ចប្រជុំវាយតម្លៃសមត្ថភាព ដោយផ្តល់ឱកាសឱ្យប្រតិបត្តិករបញ្ជាក់ពីធនធាន និងសមត្ថភាពអនុវត្តការងារស្រាវជ្រាវនិងបោសសម្អាតគ្រាប់បែកចង្កោម និងការហ្វឹកហ្វឺនសមត្ថភាពអំពីការស្រាវជ្រាវដល់ក្រុមជំនាញរបស់ពួកគាត់ ក៏ដូចជាគម្រោងស្រាវជ្រាវនិងបោសសម្អាតគ្រាប់បែកចង្កោមនានា ដែលបាននិងកំពុងត្រូវបានអនុវត្តផងដែរ។

**លទ្ធផលនៃការរំដោះផ្ទៃដីដែលសង្ស័យថាមានគ្រាប់បែកចង្កោមបែងចែកទៅតាមនីតិវិធីប្រតិបត្តិការ**

| | តាមរយៈការស្រាវជ្រាវ (C1+C2) (ម៉ែត្រការ៉េ) | តាមរយៈការបោសសម្អាតទាំងស្រុង (C3) (ម៉ែត្រការ៉េ) | ផ្ទៃដីសរុបដែលបានរំដោះ (ម៉ែត្រការ៉េ) | ភាគរយធៀបនឹងផែនការ |
|---|---|---|---|---|
| ២០១៨ | ៩.០៨៦.០០៧ | ២៩.០៨០.៤២៧ | ៣៨.១៦៦.៤៣៤ | ៦២% |
| ២០១៩ | ៤.២៤២.៨៤៨ | ២៥.៤២៣.១៩៦ | ២៩.៦៦៦.០៤៤ | ៤៧% |
| ២០២០ | ៦.៤៩៩.១៧៥ | ២៥.១៧៨.២១៣ | ៣១.៦៧៧.៣៨៨ | ៥១% |
| **សរុប** | **១៩.៨២៨.០៣០** | **៧៩.៦៨១.៨៣៦** | **៩៩.៥០៩.៨៦៦** | **៥៤%** |




សម្រាប់រយៈពេល៣ឆ្នាំ ជាមធ្យមក្នុងមួយឆ្នាំ កម្ពុជារំដោះបានផ្ទៃដីគ្រាប់បែកចង្កោមចំនួន **៣៣.១៦៩.៩៥៥ម**² ប្រសិនបើគិតជាផ្ទៃដីសរុបគឺ **៩៩.៥០៩.៨៦៦ម**² គឺសម្រេចបានតែ **៥៤%** ប៉ុណ្ណោះបើប្រៀបធៀបទៅនឹងផែនការដែលបានកំណត់។ ជារួម ការងារបោសសម្អាតគ្រាប់បែកចង្កោមដែលជាគោលដៅទី២ នៃគោលបំណងទី២ នៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២០ គឺមិនទាន់សម្រេចបាននៅឡើយ។ បច្ចុប្បន្នមានតែប្រតិបត្តិករចំនួន ៣ តែប៉ុណ្ណោះ រួមមាន CMAC អង្គការ MAG និងអង្គការ NPA ដែលបាននិងកំពុងបោសសម្អាតគ្រាប់បែកចង្កោម។ ប្រសិនបើពិនិត្យអំពីថវិកាដែលទទួលបានសម្រាប់ការងាររំដោះផ្ទៃដីគ្រាប់បែកចង្កោម ជាមធ្យមក្នុងមួយឆ្នាំកម្ពុជាទទួលបានតែ**៣លានដុល្លារ**តែប៉ុណ្ណោះខណៈដែលតម្រូវការថវិកាក្នុងផែនការ គឺ**១៥លានដុល្លារក្នុងមួយឆ្នាំ** ពេលគឺកម្ពុជាទទួលបានតែ**២០%**នៃតម្រូវការ។ ទោះបីជាមានកង្វះខាតថវិកាយ៉ាងណាក៏ដោយ ក៏សមិទ្ធកម្មនៃការរំដោះផ្ទៃដីដែលសង្ស័យថា មានគ្រាប់បែកចង្កោមនៅតែមានកំរិតខ្ពស់បើយើងធ្វើការប្រៀបធៀបធនធានដែលទទួលបាន និងសមិទ្ធផលដែលសម្រេចបាន។ កត្តាបច្ចេកទេសដែលអាចប៉ះពាល់ដល់សមិទ្ធកម្មប្រតិបត្តិការ គឺការអនុវត្តស្តង់ដារកំចាត់មីនកម្ពុជាជំពូកទី១៦ ស្តីពីការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម នៅមិនទាន់ពេញលេញនៅឡើយដោយសារស្តង់ដារនេះទើបបានដាក់ឱ្យអនុវត្តនៅពាក់កណ្តាលឆ្នាំ២០១៩ ។



*ក្រុមបោសសម្អាតគ្រាប់បែកចង្កោមរបស់អង្គការ NPA កំពុងរាវរកគ្រាប់បែកចង្កោម នៅខេត្តរតនគីរី*

## ជំពូកទី៥

## ការដោះស្រាយការគំរាមកំហែងពីសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.)

ផ្ទៃដីដែលមានវត្តមានស.ផ.ស. (មិនរាប់បញ្ចូលគ្រាប់បែកចង្កោម) គឺមានទំហំធំ ហើយស.ផ.ស.មានលក្ខណៈរាយប៉ាយពិបាកក្នុងការបោសសម្អាតនិងកំណត់តំបន់រងផលប៉ះពាល់ ដែលតម្រូវឱ្យមានការស្រាវជ្រាវជាក់លាក់បន្ថែម និងមានលក្ខណៈស៊ីជម្រៅ។ ផ្អែកលើការសិក្សានិងកិច្ចពិភាក្សារវាងភាគីពាក់ព័ន្ធយល់ថា ការស្រាវជ្រាវនិងរំដោះផ្ទៃដីដែលដឹងថាមាន ស.ផ.ស. ដែលជាគោលដៅទី១ នៃគោលបំណងទី៣នេះ គឺមិនទាន់មានតម្រូវការអនុវត្តនៅឡើយ។ ដោយឡែក ការឆ្លើយតបឱ្យទាន់ពេលវេលាចំពោះសំណើសុំជំនួយអន្តរាគមន៍ផ្នែកប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះ ដែលជាគោលដៅទី២ នៃគោលបំណងនេះ គឺយើងហៀបនឹងសម្រេចបាន។

| គោលបំណង | គោលដៅ | ការអនុវត្ត |
|---|---|---|
| ៣. ដោះស្រាយការគំរាមកំហែងពីសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) | ៣.១ ស្រាវជ្រាវ និងកាត់បន្ថយផ្ទៃដីដែលដឹងថាមានស.ផ.ស. | មិនទាន់មានតម្រូវការក្នុងការអនុវត្ត |
| | ៣.២ ផ្តល់ការឆ្លើយតបឱ្យទាន់ពេលវេលាចំពោះសំណើសុំជំនួយអន្តរាគមន៍ផ្នែកប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះពីសហគមន៍ឬអាជ្ញាធរ | ហៀបនឹងសម្រេចបាន |

### ៥.១ ការស្រាវជ្រាវ និងរំដោះផ្ទៃដីដែលដឹងថាមាន ស.ផ.ស.

តំបន់ដែលមានស.ផ.ស. មានភាពរាយប៉ាយនៅគ្រប់ទីកន្លែង ហើយការអនុវត្តការងារស្រាវជ្រាវនិងបោសសម្អាតស.ផ.ស. ត្រូវប្រើប្រាស់នីតិវិធីបោសសម្អាតទាំងស្រុង ត្រូវការប្រើប្រាស់ធនធានថវិកានិងកម្លាំងមនុស្សច្រើន។ អាជ្ញាធរមីនបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយប្រតិបត្តិករ និងភាគីពាក់ព័ន្ធ ដើម្បីពិនិត្យឡើងវិញលើស្តង់ដារសកម្មភាពកំចាត់មីន ពាក់ព័ន្ធនឹងការស្រាវជ្រាវ និងការរំដោះផ្ទៃដីដែលមានស.ផ.ស.។ ជាលទ្ធផល អង្គប្រជុំបានសម្រេចជាឯកច្ឆ័ន្ទ តម្រូវឱ្យឆ្លើយតបតាមនីតិវិធីប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះ (EOD) និងមិនអាចប្រើប្រាស់នីតិវិធីបោសសម្អាតទាំងស្រុងបានឡើយ លើកលែងតែតំបន់នោះជាតំបន់បន្ទាយទាហានចាស់ ឬមានការអភិវឌ្ឍដែលតម្រូវឱ្យមានសកម្មភាពជីកកាយជម្រៅជ្រៅ។ ចំណុចនេះ គឺជាការផ្លាស់ប្តូរមួយគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ក្នុងការឆ្លើយតបទៅនឹងស.ផ.ស. ដែលជាគោលដៅទី១ នៃគោលបំណងទី៣ ដែលការងារនេះជារួមមិនទាន់មានតម្រូវការក្នុងការអនុវត្តនៅឡើយ ពីព្រោះថវិកាសម្រាប់វិស័យមីននាពេលបច្ចុប្បន្ននៅមានកម្រិត ហើយកម្ពុជាចង់បង្វែរថវិកាបោសសម្អាតផ្ទៃដីស.ផ.ស.ទាំងនោះ ទៅប្រើប្រាស់សម្រាប់ដោះ

ស្រាយបញ្ហាមីន និងគ្រាប់ បែកចង្កោមដែលមានហានិភ័យខ្ពស់ ដើម្បីឈានទៅសម្រេចឱ្យបាននូវចក្ខុវិស័យឆ្នាំ២០២៥ ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសដែលគ្មានគ្រាប់មីន។

### ៥.២ ការផ្តល់ការឆ្លើយតបឱ្យទាន់ពេលវេលាចំពោះសំណើសុំជំនួយអន្តរាគមន៍ផ្នែកប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះពីសហគមន៍ ឬអាជ្ញាធរ

ប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះ គឺជាការរាវរក ការកំណត់អត្តសញ្ញាណ ការវាយតម្លៃនៅនឹងកន្លែង ការធ្វើឱ្យមានសុវត្ថិភាព ការកកាយយក និងការកម្ទេចគ្រាប់ប្រកបដោយសុវត្ថិភាព ក្នុងគោលបំណងការពារសុវត្ថិភាពប្រជាជន និងគាំទ្រការអភិវឌ្ឍ។

ប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះអាចពាក់ព័ន្ធនឹងគ្រាប់តែមួយ ឬគ្រាប់ច្រើនដែលរកឃើញនៅទីកន្លែងជាក់លាក់ណាមួយ ដូចជាទីតាំងកាំភ្លើងត្បាល់ ឬទីតាំងកាំភ្លើងផ្លោងជាដើម។ ប្រតិបត្តិការនេះក៏អាចពាក់ព័ន្ធនឹងគំនរគ្រាប់រំសេវ ដែលគេបោះបង់ចោលតាមលំនៅដ្ឋាន ឬនៅតាមចំណុចដែលគេទុកគ្រាប់រំសេវ។

**លទ្ធផលប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះ(EOD)**

| ឆ្នាំ | ចំនួនក្រុម EOD | ចំនួនប្រតិបត្តិការឆ្លើយតប(ដង) | ភាគរយធៀបទៅនឹងផែនការ(%) | មីនរកឃើញនិងកម្ទេចចោល(គ្រាប់) | ស.ផ.ស.រកឃើញនិងកម្ទេចចោល (គ្រាប់) |
|---|---|---|---|---|---|
| ២០១៨ | ៤០ | ៨.៦៣៤ | ៧១% | ៤.៣៤១ | ៣៧.៦២៧ |
| ២០១៩ | ៣៨ | ៨.៨០៣ | ៧៣% | ៤.៣០៧ | ៣៨.១៣៧ |
| ២០២០ | ៤៣ | ៩.៥៩៥ | ៨០% | ៥.៨៦៧ | ៣១.៦៤២ |
| សរុប | | ២៦.៨៩៩ | ៧៥% | ១៤.៥១៥ | ១០៧.៤០៦ |

សរុបលទ្ធផលប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះ (EOD) ពីឆ្នាំ ២០១៨ ដល់ ឆ្នាំ ២០២០




២៦.៨៩៩ ដង
បានឆ្លើយតប




៧៥% ធៀបផែនការ



មីនដែលបានរកឃើញ
និងកម្ទេចចោល
១៤.៥១៥ គ្រាប់



ស.ផ.ស.ដែលបានរកឃើញនិង កម្ទេចចោល
១០៧.៤០៦ គ្រាប់

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ មានសំណើសុំកម្ទេចគ្រឿងផ្ទុះពីសហគមន៍ និងអាជ្ញាធរមូលដ្ឋានចំនួន **២៦.៨៩៩សំណើ** ដែលសំណើទាំងនេះត្រូវបានឆ្លើយតបដោយក្រុមជំនាញកម្ទេចគ្រឿងផ្ទុះរបស់ប្រតិបត្តិករ ព្រមទាំងបានរកឃើញ និងកម្ទេចចោលគ្រាប់មីន **១៤.០៧៥គ្រាប់** និងស.ផ.ស.ចំនួន **១០៥.០៤៦គ្រាប់**។ ចំនួនសំណើទាំងនេះ គឺមានចំនួនតិចជាងចំនួនសំណើដែលបានគ្រោងទុកក្នុងផែនការ៣ឆ្នាំ ដែលជាក់ស្តែងយើងសម្រេចបានត្រឹមតែ ៧៥% ប៉ុណ្ណោះ។ ការងារផ្តល់អន្តរាគមន៍កម្ទេចគ្រឿងផ្ទុះ ចំពោះសំណើសុំរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាននេះ គឺជាគោលដៅទី១ នៃគោលបំណងទី៣ នៃផែនការយុទ្ធសាស្រ្តជាតិសកម្មភាពមីន ២០១៨-២០២៥ ហើយកម្ពុជាហៀបនឹងសម្រេចបានគោលដៅនេះ។ បទពិសោធន៍ជាសាកលបង្ហាញថាការគំរាមកំហែងពីស.ផ.ស. នឹងត្រូវដោះស្រាយយូរអង្វែងបន្តទៀតបន្ទាប់ពីអន្តរាគមន៍ដំបូងត្រូវបានបញ្ចប់ត្រឹមឆ្នាំ២០២៥។ ដូច្នេះកម្ពុជាត្រូវពង្រឹងសមត្ថភាពថ្នាក់ជាតិផ្នែកប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះប្រកបដោយនិរន្តរភាព ដើម្បីឆ្លើយតបចំពោះហានិភ័យដែលនៅសេសសល់។



*ក្រុម EOD របស់អង្គការ HALO Trust បានរកឃើញគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះជាច្រើនគ្រាប់ ក្នុងចម្ការរបស់ប្រជាពលរដ្ឋ ក្នុងខេត្តឧត្តរមានជ័យ។*

# ជំពូកទី៦

# ការកាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ឱ្យនៅកម្រិតអប្បបរមា ព្រមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់អ្នករស់រានមានជីវិត និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារមីន និងស.ផ.ស.

អាជ្ញាធរមីនមានតួនាទីសម្របសម្រួល ការងារអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. របស់ប្រតិបត្តិករ ដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សារអប់រំដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋរស់នៅតាមតំបន់ដែលមានហានិភ័យ ស្របតាមភេទនិងអាយុ។ ការងារនេះដើរតួយ៉ាងសំខាន់ក្នុងវិស័យសកម្មភាពមីនក្នុងការទប់ស្កាត់អត្រាគ្រោះថ្នាក់បង្កឡើងដោយសារមីន គ្រាប់បែកចង្កោមនិង ស.ផ.ស. ផ្សេងទៀត តាមរយៈការអប់រំដោយផ្ទាល់នៅតាមសហគមន៍ កន្លែងលេងកីឡា ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ប្រព័ន្ធបណ្តាញសង្គម ផ្ទាំងប៉ាណូ ខិត្តប័ណ្ណ និងរហូតដល់ការបញ្ចូលសារអប់រំ ក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គោលនយោ បាយភូមិឃុំមានសុវត្ថិភាព និងវិធានការរដ្ឋបាលនានាថែមទៀត។




*បុគ្គលិកអង្គការ HALO Trust កំពុងផ្សព្វផ្សាយអំពីស្លាកសញ្ញាសម្គាល់ចម្ការមីនដល់សិស្សានុសិស្សនៅសាលាបឋមសិក្សាមួយនៅស្រុកសំឡូត ខេត្តបាត់ដំបង*

ជាមួយគ្នានេះ កិច្ចគាំទ្រដល់ជនរងគ្រោះដោយសារមីន និងស.ផ.ស. គឺជាផ្នែកមួយនៃវិស័យពិការភាពនិងស្តារនីតិសម្បទាទូទៅ ដែលស្ថិតនៅក្រោមការសម្របសម្រួលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីផ្តល់សេវាស្តារ នីតិសម្បទា និងធ្វើសមាហរណកម្មជនមានពិការភាពចូលក្នុងសង្គមឡើងវិញ។ នៅក្នុងក្របខ័ណ្ឌអន្តរជាតិ កម្ពុជាជារដ្ឋភាគីអនុសញ្ញាអូតាវ៉ា ហើយក្នុងក្របខ័ណ្ឌអនុសញ្ញានេះ កិច្ចជួយសង្គ្រោះជនរងគ្រោះដោយសារមីន និងស.ផ.ស. គឺជាសកម្មភាពដ៏សំខាន់ដែលតម្រូវឱ្យកម្ពុជាត្រូវផ្តល់របាយការណ៍បច្ចុប្បន្នភាព និងវឌ្ឍនភាពការងារគាំទ្រដល់ជនរងគ្រោះដោយសារមីន ជូនរដ្ឋភាគីនៃអនុសញ្ញាជាទៀងទាត់ដែលការងារនេះសម្របសម្រួលដោយអាជ្ញាធរមីន។ ជាមួយគ្នានេះ កម្ពុជាក៏ជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការផងដែរ ដែលការងារនេះសម្របសម្រួលដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នៅក្នុងកម្រិតថ្នាក់ជាតិ កម្ពុជាមានក្របខ័ណ្ឌច្បាប់និងគោលនយោបាយទូលំទូលាយ ដើម្បីធានាសិទ្ធិនិងដំណោះស្រាយជូនសេចក្តីត្រូវការរបស់ជនមានពិការភាព។ ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ជនមានពិការភាពនៅក្នុងសហគមន៍ ក៏ជាសកម្មភាពស្នូលដ៏សំខាន់នៃកម្មវិធីផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះតាមសហគមន៍ ហើយក៏ត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំង លើការប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះថ្នាក់ដោយសារមីន

និងស.ផ.ស. និងជនពិការផ្សេងៗទៀតដោយការគោរព ព្រមទាំងលើកកម្ពស់សិទ្ធិនិងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ពួកគេ។

| គោលបំណង | គោលដៅ | ការអនុវត្ត |
|---|---|---|
| ៤. កាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ឱ្យនៅកម្រិតអប្បបរមា ព្រមទាំងលើកម្ពស់ជីវភាពរស់នៅរបស់របស់អ្នកនៅរស់រានមានជីវិត និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារមីន និងស.ផ.ស. | ៤.១ ផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ប្រកបដោយប្រសិទ្ធភាពដល់ប្រជាជនដែលរស់នៅតាមតំបន់មានហានិភ័យខ្ពស់នាពេលបច្ចុប្បន្ន និងតំបន់ដែលមានហានិភ័យទើបកើតឡើងថ្មី សមស្របនឹងភេទនិងអាយុ និងការពង្រឹងការផ្តួចផ្តើមបណ្តាញមូលដ្ឋាន | សម្រេចបាន |
| | ៤.២ ផ្តល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោលដើម្បីទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្តឱ្យបានគ្រប់គ្រាន់សមស្របទៅនឹងយេនឌ័រ និងការស្តារលទ្ធភាពពលកម្មកាយសម្បទា | មិនទាន់សម្រេចបាន |
| | ៤.៣ លើកកម្ពស់សមត្ថភាពប្រកបរបរចញ្ចឹមជីវិតរបស់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ពីមីននិងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោល ដើម្បីជំរុញការចូលរួមយ៉ាងពេញលេញរបស់ពួកគាត់នៅក្នុងសង្គម | មិនទាន់សម្រេចបាន |

## ៦.១ ការផ្តល់ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ប្រកបដោយប្រសិទ្ធភាពដល់ប្រជាជនដែលរស់នៅតាមតំបន់មានហានិភ័យខ្ពស់នាពេលបច្ចុប្បន្ន និងតំបន់ដែលមានហានិភ័យទើបកើតឡើងថ្មី សមស្របនឹងភេទនិងអាយុ និងការពង្រឹងការផ្តួចផ្តើមបណ្តាញមូលដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជា បានដាក់បញ្ចូលការងារអប់រំយល់ដឹងអំពីមីនទៅក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ព្រមទាំងបានកំណត់ចំនួនភូមិដែលប្រឈមនឹងគ្រោះថ្នាក់ដោយសារមីនគ្រាប់បែកចង្កោម និងស.ផ.ស.ផ្សេងទៀត ដែលត្រូវទទួលសារអប់រំដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០។ ក្នុងផ្នែកអប់រំយល់ដឹងអំពីមីន អាជ្ញាធរមីនមានតួនាទីសម្របសម្រួល និងធានាប្រសិទ្ធភាពការងារអប់រំដែលអនុវត្តដោយប្រតិបត្តិករជាតិនិងអន្តរជាតិ។ ប្រតិបត្តិករជាតិនិងប្រតិបត្តិករអន្តរជាតិដែលបាននិងកំពុងអនុវត្តការងារអប់រំយល់ដឹងអំពីមីន រួមមាន ក្រសួងអប់រំ យុវជន និងកីឡា (ក.យ.ក.) កាកបាទក្រហមកម្ពុជា(CRC) នគរបាលជាតិ(ERW-MoI) មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាពបោសសម្អាតមីន និងកាកសំណល់សង្គ្រាម (RCAF/NPMEC) មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា(CMAC) អង្គការ HALO Trust អង្គការ MAG អង្គការ NPA អង្គការស្មារតីនៃអ្នកកីឡា(SOS) និងអង្គការ CSHD។ ការអប់រំយល់ដឹងអំពីមីន នៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់ការកើនឡើងនៃអត្រាគ្រោះថ្នាក់។ គិតចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ប្រជាពលរដ្ឋចំនួន ២.៨៤០.៦១២នាក់ ក្នុងនោះមានស្ត្រីចំនួន ៩៦៧.៣៥១នាក់ និងកុមារីចំនួន ៣៦៥.៥៦៦នាក់ បានទទួល

សារអប់រំយល់ដឹងអំពីមីនពីប្រតិបត្តិករជាតិនិងអន្តរជាតិ។ តាមរបាយការណ៍ CMVIS នៅក្នុងឆ្នាំ២០១៨ ចំនួនគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. មានចំនួន ៥៨នាក់ ហើយបានកើនដល់៧៧នាក់ ក្នុងឆ្នាំ ២០១៩ ប៉ុន្តែតួលេខនេះបានធ្លាក់ចុះមកវិញក្នុងឆ្នាំ២០២០ មកត្រឹម៦៥នាក់។

ស្តង់ដារជាតិស្តីពីការងារអប់រំយល់ដឹងអំពីមីន ត្រូវបានបង្កើតឡើងដើម្បីជានាការផ្តល់សារអប់រំយល់ដឹងអំពីមីន ប្រកបដោយប្រសិទ្ធភាព។ ដើម្បីពង្រឹងការអនុវត្តស្តង់ដារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ អាជ្ញាធរមីនតម្រូវឱ្យរាល់ប្រតិបត្តិករដែលធ្វើការអប់រំយល់ដឹងអំពីមីន ត្រូវមានស្តង់ដារប្រតិបត្តិការ (SOP) ដែលអនុលោមតាមស្តង់ដារជាតិ និងធនធានមនុស្សដែលបានទទួលការហ្វឹកហ្វឺនត្រឹមត្រូវ។ ដើម្បីធានាប្រសិទ្ធភាពការអប់រំ អាជ្ញាធរមីនបានសហការជាមួយអង្គការ NPA ធ្វើការវាយតម្លៃសមត្ថភាពប្រតិបត្តិករ រួមមាន CMAC នគរបាលជាតិ អង្គការ MAG អង្គការ HALO Trust និងអង្គការ CSHD ក្នុងការផ្តល់ការអប់រំយល់ដឹងអំពីមីនចំនួន ១លើក ក្នុងឆ្នាំ២០២០ ដោយផ្តោតសំខាន់ទៅលើ៖ ១-ការពង្រឹងគុណវុឌ្ឍិរបស់ក្រុមការងារជំនាញ ២-វិធីសាស្ត្រ ឧបករណ៍ សម្ភារ និងអភិក្រមនៃការអប់រំ ៣-អភិក្រមនៃការគ្រប់គ្រងគុណភាពផ្ទៃក្នុង ៤-ការតាមដាននិងវាយតម្លៃលើចំណេះដឹងអ្នកដែលបានចូលរួមទទួលសារអប់រំ ៥-ការធ្វើរបាយការណ៍ ៦-ការបញ្ជ្រាបយេនឌ័រដោយផ្តោតលើសមាសភាពសមាជិកក្រុម និង ៧-ស្តង់ដារប្រតិបត្តិការ (SOP)។

ការវាយតម្លៃបានផ្តល់អនុសាសន៍មួយចំនួនដូចតទៅ៖ ១-ការផ្តល់សារអប់រំគួរផ្តោតទៅលើតំបន់ដែលមានហានិភ័យខ្ពស់ ២-ជំរុញការអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព ដើម្បីពង្រឹងការអប់រំយល់ដឹងអំពីមីន ៣-ចំនួនអ្នកចូលរួមក្នុងវគ្គអប់រំនីមួយៗ មិនគួរលើសពី ៣០នាក់ ហើយក្នុង១វគ្គមិនគួរមានរយៈពេលលើសពី២ម៉ោងឡើយ ៤-ការចែករំលែកបទពិសោធន៍ក្នុងការផ្តល់សារអប់រំរវាងប្រតិបត្តិករ តាមរយៈសិក្ខាសាលាមានសារៈសំខាន់ក្នុងការពង្រីកនិងពង្រឹងចំណេះដឹង ៥-កិច្ចប្រជុំក្រុមការងារបច្ចេកទេសការអប់រំយល់ដឹងអំពីមីន (TRG-EORE) គួរតែរៀបចំចំនួន២ដងយ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីពិភាក្សាអំពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ និង ៦-គួរតែមានការចែករំលែកបទពិសោធន៍ពីបញ្ហាគ្រោះថ្នាក់ពីសហគមន៍មួយទៅសហគមន៍មួយទៀត ដើម្បីរកដំណោះស្រាយលើបញ្ហាប្រឈម។



*សកម្មភាពមន្ត្រីនគរបាលជាតិ ចុះផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. និងច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ*

ផ្អែកលើលទ្ធផលវាយតម្លៃសមត្ថភាពខាងលើ អាជ្ញាធរមីនបានសហការជាមួយអង្គការ NPA រៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព ព្រមទាំងបានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកអប់រំយល់ដឹង

អំពីមីន ដើម្បីផ្សព្វផ្សាយអំពីលទ្ធផលនៃការវាយតម្លៃ និងផែនការអភិវឌ្ឍន៍សមត្ថភាពផងដែរ។ ដើម្បីជានាការអប់រំយល់ដឹងអំពីមីនឱ្យចំគោលដៅ អាជ្ញាធរមីនបានរៀបចំកិច្ចប្រជុំជារៀងរាល់ឆ្នាំជាមួយភាគីពាក់ព័ន្ធ ដើម្បីកំណត់ភូមិអាទិភាពដែលមានហានិភ័យខ្ពស់ ព្រមទាំងសម្របសម្រួលសេវាអប់រំយល់ដឹងអំពីមីន នៅតំបន់ថ្មីៗដែលមានហានិភ័យ។

ក្នុងគោលបំណងធានានិរន្តរភាពក្នុងការអប់រំយល់ដឹងអំពីមីន អាជ្ញាធរមីនបានរៀបចំកិច្ចប្រជុំជាមួយ ក.យ.ក. ចំនួន៣លើក និងបានដាក់បញ្ចូលខ្លឹមសារនៃការអប់រំនេះទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិតាមកម្រិតថ្នាក់និងមុខវិជ្ជា រួមមាន សៀវភៅមុខវិជ្ជាភាសាខ្មែរថ្នាក់ទី២ ចំណងជើងមេរៀន "រាជធានីភ្នំពេញ" សៀវភៅមុខវិជ្ជាភាសាខ្មែរថ្នាក់ទី៣ ចំណងជើងមេរៀន"ស្លាកសញ្ញាសុវត្ថិភាព" សៀវភៅមុខវិជ្ជាវិទ្យាសាស្ត្រ-សិក្សាសង្គមថ្នាក់ទី៣ ចំណងជើងមេរៀន"ការរក្សាសុវត្ថិភាពនៅក្នុងតំបន់មានមីន" សៀវភៅមុខវិជ្ជាសិក្សាសង្គមថ្នាក់ទី៥ ចំណងជើងមេរៀន "ការចៀសវាងទង្វើដែលនាំឱ្យមានគ្រោះថ្នាក់ និងសៀវភៅមុខវិជ្ជាសិក្សាសង្គមថ្នាក់ទី៨ ចំណងជើងមេរៀន "សុវត្ថិភាពក្នុងសហគមន៍" ។



សកម្មភាពសិស្សានុសិស្សនៅស្រុកសំឡូត ខេត្តបាត់ដំបង កំពុងទទួលការអប់រំយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស.

ទន្ទឹមនោះក.យ.ក.បានរៀបចំឯកសារជំនួយស្មារតីក្នុងការរៀន និងបង្រៀន ដើម្បីគាំទ្រការអប់រំយល់ដឹងអំពីមីនរួមមាន សៀវភៅអប់រំស្តីពី វិធីបង្ការ វិធីសង្គ្រោះជនរងគ្រោះថ្នាក់ឬរបួសផ្សេងៗ ចំណងជើងមេរៀន "គ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ" សៀវភៅកម្មវិធីបញ្ជ្រាបខ្លឹមសារមីនថ្នាក់ទី១-២ សៀវភៅកម្មវិធីបញ្ជ្រាបខ្លឹមសារមីនថ្នាក់ទី៥-៦ សៀវភៅកម្មវិធីអប់រំកុមារអំពីគ្រោះថ្នាក់មីនថ្នាក់ទី១-៦ (សៀវភៅសម្រាប់គ្រូ) សៀវភៅរឿង "សុខាជាក្មេងពូកែ" ផ្ទាំងរូបភាពរឿងឥតចំណងជើង ផ្ទាំងរូបភាពអក្ខរក្រម កម្រងបទចម្រៀងសម្រាប់អប់រំបញ្ហាមីន សៀវភៅជំនួយមិត្តអប់រំមិត្ត និងឯកសារណែនាំអំពី "ការអនុវត្តសកម្មភាពមិត្តអប់រំមិត្ត" ។

ដោយឡែកនៅឆ្នាំ២០១៨ អាជ្ញាធរមីន បានរៀបចំកិច្ចប្រជុំជាមួយ ក.យ.ក. ចំនួន៣លើក និងបានកែសម្រួលខ្លឹមសារនិងមេរៀនខ្លះដែលពាក់ព័ន្ធនឹងការអប់រំយល់ដឹងអំពីមីនក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ ប៉ុន្តែមិនទាន់បានប្រើប្រាស់ជាផ្លូវការតាមសាលារៀននៅឡើយ ដោយក្នុងនោះមាន៖

- មុខវិជ្ជាសិក្សាសង្គមថ្នាក់ទី៣ ជំពូកទី៤ មេរៀនទី៣ "សុវត្ថិភាពនៅក្នុងតំបន់មានមីននិងគ្រាប់មិនទាន់ផ្ទុះ" ដែលមានចំណងជើងរង ១-"អត្ថន័យនៃផ្លាកសញ្ញាមីន ២-"សុវត្ថិភាពក្នុងតំបន់មានគ្រាប់មីន" ៣-"ការចៀសវាងលេងឬដុំគ្រាប់មិនទាន់ផ្ទុះ"

- មុខវិជ្ជា សីលធម៌ ពលរដ្ឋវិជ្ជាថ្នាក់ទី៨ ជំពូកទី២ មេរៀនទី១ "សុត្ថិភាពជាតិផ្ទុះក្នុងសហគមន៍" ដែលមានចំណងជើងរង ១-"សុវត្ថិភាពទូទៅក្នុងសហគមមន៍ ២-"សញ្ញាណស្ដីពីអាវុធជាតិផ្ទុះ" ៣-"ប្រភេទអាវុធជាតិផ្ទុះ" ៤-"ច្បាប់ពាក់ព័ន្ធ និងការប្រើប្រាស់អាវុធជាតិផ្ទុះ ៥-"ផលប៉ះពាល់ និងវិធីបង្ការទប់ស្កាត់អាវុធជាតិផ្ទុះ ៦-"ការចូលរួមទទួលខុសត្រូវសុវត្ថិភាពក្នុងសហគមន៍"
- មុខវិជ្ជាភូមិវិទ្យាថ្នាក់ទី១២៖ ជំពូក៤ មេរៀនទី៦ "បញ្ហាមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅកម្ពុជា" ដែលមានចំណងជើងរង ១-"មូលហេតុនៃការប្រើប្រាស់មីន" ២-"តំបន់ដែលមានមីនប្រឆាំងមនុស្ស" ៣-"ផលប៉ះពាល់ដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ" ៤-"លទ្ធផលនៃការដោះមីន" ។

ទន្ទឹមនឹងនេះ អាជ្ញាធរមីនបានជួយពង្រឹងនិងជំរុញឱ្យមានការបង្កើត "ក្លឹបមិត្តអប់រំមិត្ត" បន្ថែមនៅតាមសាលារៀននៅតាមខេត្តគោលដៅ ដើម្បីងាយស្រួលក្នុងការផ្សព្វផ្សាយនៅតាមសហគមន៍ និងតាមខ្នងផ្ទះ តាមរយៈការសម្ដែងរឿងអប់រំខ្លីៗ ការបង្ហាញនិងពន្យល់ខ្លឹមសារនៃផ្ទាំងរូបភាព ព្រមទាំងការសួរនិងឆ្លើយសំណួរផងដែរ។

ការផ្ដល់ការអប់រំដោយបណ្ដាញតាមសហគមន៍ គឺជាវិធីសាស្ត្រសំខាន់សម្រាប់និរន្តរភាពការងារក៏ដូចជា ការបន្តពង្រឹងគុណភាពក្នុងការអប់រំយល់ដឹងអំពីមីននៅក្នុងសហគមន៍។ ក្នុងឆ្នាំ២០២០ តាមរយៈថវិកាគាំទ្រពីគម្រោង UNICEF អាជ្ញាធរមីនបានជ្រើសរើសទីប្រឹក្សាបច្ចេកទេសសម្រាប់អនុវត្តការវាយតម្លៃដើម្បីកំណត់សមត្ថភាពផ្នែកអប់រំយល់ដឹងអំពីមីន និងពង្រីកការអប់រំយល់ដឹងអំពីមីននៅតាមសហគមន៍។ ជាមួយគ្នានេះ អាជ្ញាធរមីនបានរៀបចំបង្កើតនិងផ្ដល់សារអប់រំកាត់បន្ថយគ្រោះថ្នាក់មីន និង ស.ផ.ស.ថ្មីៗ ដល់បណ្ដាញនៅតាមសហគមន៍សម្រាប់ប្រើប្រាស់ ក្នុងនោះមានរៀបចំផលិតជាវីដេអូខ្លីសម្រាប់អប់រំអំពីគ្រោះថ្នាក់មីន និងស.ផ.ស. និងផលិតផ្ទាំងប៉ាណូថ្មី ដែលមានជាច្រើនប្រធានបទ។ ជារៀងរាល់ឆ្នាំ អាជ្ញាធរមីនបានពិភាក្សាត្រួតពិនិត្យ និងអនុម័តលើខ្លឹមសារសារអប់រំ និងវិធីសាស្ត្ររបស់ប្រតិបត្តិករ និងពាក្យស្លោកសារស្ដីពីគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. សម្រាប់ទិវាជាតិយល់ដឹងអំពីមីន២៤កុម្ភៈ។ អាជ្ញាធរមីនបានធ្វើការត្រួតពិនិត្យការផ្ដល់ការអប់រំយល់ដឹងពីគ្រោះថ្នាក់ដោយសារមីន និង ស.ផ.ស. យ៉ាងហោចណាស់ក្នុងមួយត្រីមាសចំនួន១លើកជារៀងរាល់ឆ្នាំ ដើម្បីធានាប្រសិទ្ធភាពនិងប្រសិទ្ធផលការងារ។

ជាងនេះទៀត អាជ្ញាធរមីនបានពង្រឹងផ្នែកអប់រំយល់ដឹងអំពីមីន តាមរយៈគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងបានសម្របសម្រួលក្នុងការផ្ដល់ជាថវិកាជរដ្ឋាភិបាលដល់ CMAC សម្រាប់ការបណ្ដុះបណ្ដាលមន្ត្រីនគបាលជាតិ និងអាជ្ញាធរមូលដ្ឋាន ចំនួន **២២វគ្គ** ដោយមានអ្នកចូលរួមចំនួន **១.០៣០នាក់** សម្រាប់រយៈពេល៣ឆ្នាំ ។ ជាមួយគ្នានេះ ក្នុងរយៈពេល ៣ឆ្នាំអាជ្ញាធរមីនសហការជាមួយអង្គការ UNICEF បានសម្របសម្រួល និងរៀបចំកិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីបញ្ជ្រាបការអប់រំយល់ដឹងអំពីមីន

ចំនួន ៨លើក នៅខេត្តឧត្តរមានជ័យ ពោធិ៍សាត់ ព្រៃវែង រតនគីរី បាត់ដំបង និងត្បូងឃ្មុំ។ ការងារការអប់រំយល់ដឹងអំពីមីន ជាគោលដៅទី១ នៃគោលបំណងទី៤ ក្នុងផែនការយុទសាស្រ្តជាតិសកម្មភាពមីន ២០១៨-២០២៥ ហើយជារួមការងារនេះសម្រេចបានតាមផែនការ។

### ៦.២ ការផ្តល់ការគាំទ្រដល់ជនរងគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោលដើម្បីទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ និងអប់រំផ្លូវចិត្តឱ្យបានគ្រប់គ្រាន់ ដោយសមស្របទៅនឹងយេនឌ័រ និងការស្តារលទ្ធភាពពលកម្មកាយសម្បទា

ដើម្បីគាំទ្រដល់ជនរងគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស.ផ្ទាល់ និងប្រយោល ឱ្យទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ ការអប់រំផ្លូវចិត្តដោយសមស្របទៅនឹងយេនឌ័រ និងការស្តារលទ្ធភាពពលកម្មកាយសម្បទា ការរៀបចំចងក្រងឯកសារដែលពាក់ព័ន្ធនឹងជនរងគ្រោះ គឺជាការងារអាទិភាពបំផុត។ អាជ្ញាធរមីនបានចងក្រងឯកសារករណីសិក្សាចំនួន ៤លើក ស្តីពីជនរងគ្រោះថ្នាក់ដែលទទួលបានសេវាគាំទ្រនានាដែលបានបែងចែកតាមភេទ និងអាយុ ហើយបានផ្តល់ឯកសារទាំងនោះជូនក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានាសម្រាប់យកទៅប្រើប្រាស់ក្នុងន័យជួយគាំទ្រដល់ការងារជួយជនរងគ្រោះ។

អាជ្ញាធរមីន បានផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពការងារជួយសង្គ្រោះជនរងគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ជូនរដ្ឋភាគីអនុសញ្ញាអូតាវ៉ាជារៀងរាល់ឆ្នាំ និងបានចូលរួមអនុវត្តគោលនយោបាយថ្នាក់ជាតិ ដើម្បីធានាកិច្ចការពារសិទ្ធិ និងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ជនរងគ្រោះ។ លើសពីនេះ អាជ្ញាធរមីនបានសម្របសម្រួលជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ មូលនិធិជនពិការ និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា (PWD-F&PRC) និងអង្គការពាក់ព័ន្ធការងារក្នុងវិស័យពិការភាព ដើម្បីផ្តល់ជំនួយសង្គ្រោះបន្ទាន់នានាដល់ជនរងគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស ឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា។ អាជ្ញាធរមីនក៏បានចូលរួមជួយពង្រឹងយន្តការសម្របសម្រួលថ្នាក់ជាតិស្តីពីពិការភាពដើម្បីធានាបានថាតម្រូវការ និងសិទ្ធិរបស់ជនរងគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ផ្ទាល់ និងប្រយោល ត្រូវបានដោះស្រាយឱ្យបានសមស្រប តាមរយៈការសិក្សាស្តីពីគុណភាពជីវិតដែលបានអនុវត្តពីឆ្នាំ២០១៨ ដល់ ឆ្នាំ ២០១៩ ដោយមានជនរងគ្រោះចំនួន**៧.២៧៣នាក់** ចូលរួមផ្តល់កិច្ចសម្ភាសន៍។ ដោយឡែក នៅឆ្នាំ២០២០ ការសិក្សានេះ ត្រូវបានខកខានដោយសារតែជម្ងឺរាតត្បាតកូវីដ-១៩។ តាមផែនការ អាជ្ញាធរមីនគ្រោងសម្ភាសន៍ជនរងគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ចំនួន **២៤.០០០នាក់** តែដោយកង្វះខាតថវិកា និងជម្ងឺរាតត្បាតកូវីដ-១៩ យើងមិនអាចសម្រេចបានតាមការគ្រោងទុកនោះឡើយ។



*សកម្មភាពបុគ្គលិកមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាកំពុងបំពាក់ជើងសប្បនិមិត្តជូនជនពិការដោយសារមីន និងស.ផ.ស.។*

តាមរយៈយន្តការសម្របសម្រួលថ្នាក់ជាតិស្តីពីពិការភាព អាជ្ញាធរមីនក៏បានពង្រឹង និងពង្រីកបណ្តាញអ្នកស្ម័គ្រចិត្តជនពិការ ដើម្បីជួយសម្របសម្រួលក្នុងការផ្តល់សេវាកម្មជូនជនរងគ្រោះថ្នាក់ដោយសារមីន និង ស.ផ.ស. ដែលរស់នៅតំបន់ដាច់ស្រយាលជួបការលំបាក ឱ្យបានទាន់ពេលវេលា សមស្របតាមតម្រូវការ និងសិទ្ធិរបស់ពួកគាត់។



*បណ្តាញស្ម័គ្រចិត្តជនពិការខេត្តស្វាយរៀងកំពុងចុះស្រង់ទិន្នន័យជនពិការដោយសារមីន និងស.ផ.ស. នៅតាមសហគមន៍។*

អាជ្ញាធរមីនបានសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីធ្វើការវាយតម្លៃអំពីសេវាគាំទ្រដល់ជនរងគ្រោះថ្នាក់ដោយមីននិងស.ផ.ស. ផ្ទាល់ និងប្រយោលចំនួន ២ លើក ព្រមទាំងបានរៀបចំតារាងបញ្ជីសេវាកម្មជួយគាំទ្រដល់ជនរងគ្រោះ សម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០។ ជាមួយគ្នានេះ ក្នុងរយៈពេល៣ឆ្នាំ បានរៀបចំវេទិកាដើម្បីពិភាក្សាអំពីតម្រូវការរបស់ជនមានពិការភាពនៅតាមខេត្ត/ស្រុកគោលដៅបានចំនួន ៤លើកនៅក្នុងខេត្តបាត់ដំបង ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមចំនួន **៤៥៥នាក់។** ក្នុងនោះផងដែរ តាមរយៈថវិកាឧបត្ថម្ភគាំទ្រដោយមូលនិធិលោក Sir Bobby Charlton (The Sir Bobby Charlton Foundation) អាជ្ញាធរមីនក៏បានរៀបចំជាពិធីសំណេះសំណាលសាកសួរសុខទុក្ខ និងចែកគ្រឿងឧបភោគបរិភោគដល់ជនរងគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. និងជនមានពិការភាពដែលមានជីវភាពក្រីក្រចំនួន ៦លើក នៅក្នុងខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តប៉ៃលិន និងខេត្តស្វាយរៀង ដែលមានជនរងគ្រោះសរុបចំនួន **១.៣៥៨នាក់**។

ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ជនរងគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. អាជ្ញាធរមីនក៏បានសហការជាមួយភាគីពាក់ព័ន្ធរៀបចំកិច្ចប្រជុំចំនួន ៤លើក ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដើម្បីធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ រួមទាំងគោលនយោបាយជាតិស្តីពីការជម្រុញឱ្យជនមានពិការភាពបានចូលបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋ និងវិស័យឯកជន។ ការងារនេះមិនបានអនុវត្តនៅក្នុងឆ្នាំ២០២០ នោះទេ ដោយសារតែបញ្ហាវិបត្តិជំងឺកូវីដ-១៩ ហើយការងារនេះជាគោលដៅទី២ គោលបំណងទី៤ នៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនឆ្នាំ២០១៨-២០២៥។

### ៦.៣ ការលើកកម្ពស់សមត្ថភាពប្រកបរបរចិញ្ចឹមជីវិតរបស់ជនរងគ្រោះថ្នាក់ដោយសារមីន និងស.ផ.ស. ព្រមទាំងជនរងគ្រោះដោយប្រយោល ដើម្បីជម្រុញឱ្យមានការចូលរួមយ៉ាងពេញលេញរបស់ពួកគាត់នៅក្នុងសង្គម

ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ អាជ្ញាធរមីនបានផ្តល់ការគាំទ្រដល់ជនរងគ្រោះថ្នាក់ដោយសារមីននិង ស.ផ.ស. និងក្រុមគ្រួសាររបស់ពួកគាត់ តាមរយៈការលើកកម្ពស់សមត្ថភាពប្រកបរបរចិញ្ចឹមជីវិតដល់ជនរងគ្រោះផ្ទាល់ និងប្រយោលបានចំនួន ៩៨នាក់ ដើម្បីជម្រុញឱ្យមានការចូលរួមយ៉ាងពេញលេញរបស់ពួកគាត់ទៅក្នុងសង្គម ប៉ុន្តែដោយសារតែបញ្ហាវិបត្តិជំងឺកូវីដ-១៩ ការងារនេះមិនបានអនុវត្តនោះទេ ក្នុងឆ្នាំ២០២០ ។ បន្ថែមលើនេះ ក្នុងឆ្នាំ២០១៩ អាជ្ញាធរមីនក៏បានធ្វើការសិក្សាទៅលើជនរងគ្រោះផ្ទាល់ និងប្រយោលក្នុងការប្រកបរបរកសិកម្មនិងមុខរបរខ្នាតតូច ក្នុងអតីតតំបន់ដែលមានគ្រាប់មីន ដោយបានបែងចែកទៅតាមភេទ និងអាយុ បានចំនួន១លើក។ ការងារនេះ ក៏ត្រូវបានកំណត់ក្នុងគោលដៅទី៣ គោលបំណងទី៤ នៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនឆ្នាំ២០១៨-២០២៥។



*ឯកឧត្តមទេសរដ្ឋមន្ត្រី លី ធុជ អនុប្រធានទី១ អាជ្ញាធរមីន អញ្ជើញសួរសុខទុក្ខនិងចែកស្បៀងអាហារជូនជនពិការ ក្នុងខេត្តបន្ទាយមានជ័យ*

# ជំពូកទី៧
# ការរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ

បច្ចុប្បន្ននេះ អាជ្ញាធរមីនបានបន្តអនុវត្តយន្តការសម្របសម្រួលក្នុងការចាត់អាទិភាពនិងរៀបចំផែនការសកម្មភាពមីននៅថ្នាក់ក្រោមជាតិ តាមរយៈគណៈកម្មាធិការសកម្មភាពមីនខេត្ត(គីម៉ាក់) និងក្រុមការងារផែនការសកម្មភាពមីន(ម៉ាពូ) ២៥រាជធានី-ខេត្ត ដើម្បីធានាថា រាល់ផែនការបោសសម្អាតមីននិងស.ផ.ស. ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំ-សង្កាត់ ដែលឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ក្នុងសហគមន៍មូលដ្ឋាន។



*លោកស្រី ឆាយ ភាព បង្ហាញដំណាំដែលគាត់បានដាំនៅលើផ្ទៃដីដែលបានបោសសម្អាតមីនរួច ក្រោមគម្រោងបោសសម្អាតមីនដើម្បីលទ្ធផលដំណាក់កាលទី៣ ស្ថិតក្នុងស្រុកសំឡូត ខេត្តបាត់ដំបង*

ជារៀងរាល់ឆ្នាំ អាជ្ញាធរមីនរៀបចំសេចក្តីណែនាំថ្នាក់ជាតិស្តីពីការតម្រង់ទិសធនធានសកម្មភាពមីនដល់ឃុំ-សង្កាត់ ដើម្បីប្រើប្រាស់ជាត្រីវិស័យសម្រាប់តម្រង់ទិសប្រភពធនធានបោសសម្អាតមីន និងស.ផ.ស. ឱ្យចំគោលដៅក្នុងតំបន់រងផលប៉ះពាល់ខ្លាំង និងឆ្លើយតបតាមតម្រូវការសហគមន៍មូលដ្ឋាន។ សេចក្តីណែនាំថ្នាក់ជាតិនេះក៏ជាឯកសារគោលសម្រាប់រៀបចំនិងកសាងផែនការសកម្មភាពមីនប្រចាំឆ្នាំ ស្របតាមកម្មវិធីវិនិយោគ៣ឆ្នាំរំកិលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

| គោលបំណង | គោលដៅ | ការអនុវត្ត |
|---|---|---|
| ៥. ចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ | ៥.១ គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍមូលដ្ឋាននៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ពីមីន គ្រាប់បែកចង្កោម និងស.ផ.ស. ផ្សេងទៀត | សម្រេចបាន |
| | ៥.២ គាំទ្រអាទិភាពនៃការអភិវឌ្ឍថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ហៀបនឹងសម្រេចបាន |

## ៧.១ គាំទ្រដល់អាទិភាពនៃការអភិវឌ្ឍមូលដ្ឋាននៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ពីមីន គ្រាប់បែកចង្កោម និងស.ផ.ស. ផ្សេងទៀត

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តសេចក្តីណែនាំ ស្តីពីការរៀបចំផែនការ និងចាត់អាទិភាព អាជ្ញាធរមីនបានរៀបចំសិក្ខាសាលាចំនួនមួយលើក នៅក្នុងឆ្នាំ២០១៩ និងធ្វើការបណ្តុះបណ្តាលដល់មន្ត្រីម៉ាពូ អាជ្ញា

ធរមូលដ្ឋាន បុគ្គលិកប្រតិបត្តិករចំនួន ២៤៦នាក់ និងបានធ្វើការត្រួតពិនិត្យលើការអនុវត្តគោលការណ៍នេះ បានចំនួន ២៩លើក។

### ៧.២ គាំទ្រអាទិភាពនៃការអភិវឌ្ឍថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

ប្រទេសកម្ពុជាបានកំណត់សកម្មភាពមីនជាគោលដៅមួយ ក្នុងចំណោមគោលដៅអភិវឌ្ឍន៍កម្ពុជា ប្រកបដោយចីរភាព (CSDGs) របស់ខ្លួន ពោលគឺគោលដៅទី១៨ (CSDG 18)។ លើសពីនេះទៅទៀត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ បានគូសបញ្ជាក់ថា ការធ្វើផែនការនិងការចាត់អាទិភាពប្រកបដោយប្រសិទ្ធភាព មានសារៈសំខាន់សម្រាប់ធានាការប្រើប្រាស់ធនធានដែលមានកម្រិត ប្រកបដោយប្រសិទ្ធផល។ ប្រការនេះបានជំរុញលើកទឹកចិត្តឱ្យអាជ្ញាធរមីន បន្តធ្វើការកែលម្អលើដំណើរការធ្វើផែនការនិងការចាត់អាទិភាពនាពេលបច្ចុប្បន្ន ដែលត្រូវបានបញ្ចូលទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់។

សម្រាប់រយៈពេល៣ឆ្នាំ ២០១៨ដល់២០២០ ផ្ទៃដីប្រមាណ៨៧.៧៥ភាគរយ នៃផ្ទៃដីសរុបដែលបានបោសសម្អាតរួច ត្រូវបានប្រើប្រាស់សម្រាប់វិស័យកសិកម្មដែលមានអ្នកទទួលផលសរុបចំនួនពីរលាននាក់ ដែលនេះជាសមិទ្ធផលនៃការអនុវត្តគោលការណ៍ណែនាំស្តីពីការធ្វើផែនការ និងចាត់អាទិភាពប្រកបដោយប្រសិទ្ធភាព និងភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជាលើវិស័យសកម្មភាពមីន។







កិច្ចពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធក្នុងវិស័យសកម្មភាពមីន និងវិស័យពាក់ព័ន្ធផ្សេងទៀតនៅគ្រប់កម្រិត គឺជាសកម្មភាពមួយដ៏សំខាន់ក្នុងការបង្កើតឱ្យមានភាពប្រទាក់ក្រឡាជាវិជ្ជមាននិងកិច្ចសហការរវាងវិស័យផ្សេងៗ។ ដូច្នេះ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍លើវិស័យមីន (ក.ប.ម.) ក្នុងឆ្នាំ២០០៤ សម្រាប់ជាយន្តការសម្របសម្រួលកិច្ចប្រឹក្សាយោបល់ក្នុងភាពជាដៃគូ ដែលមានការចូលរួមពីតំណាងក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីគាំទ្រយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល។

គោលបំណងចម្បងនៃក្រុមការងារ ក.ប.ម. គឺគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលកិច្ចពិភាក្សាកម្រិតបច្ចេកទេស កៀរគរនិងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ គោលបំណងជាក់លាក់របស់ក្រុមការងារ ក.ប.ម.៖

- លើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចពិគ្រោះយោបល់ក្នុងភាពជាដៃគូកម្រិតបច្ចេកទេសសម្រាប់សម្របសម្រួល និងកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ
- ជានាការតម្រឹមហិរញ្ញប្បទានសហប្រត្តិបត្តិការ ជាមួយនឹងតម្រូវការអាទិភាពរបស់វិស័យមីន
- តាមដានវឌ្ឍនភាពសកម្មភាពការងារដែលបានកំណត់រួមគ្នា និងក្នុងសូចនាករតាមដានរួមគ្នា
- បំពេញបន្ថែមឱ្យយន្តការភាពជាដៃគូដទៃទៀត ដូចជាយន្តការភាពជាដៃគូថ្នាក់ក្រោមជាតិ និងកិច្ចពិគ្រោះយោបល់ពហុភាគីកម្រិតវិស័យ។

ដើម្បីពិភាក្សាអំពីបញ្ហាគោលនយោបាយនានា ក្នុងគោលបំណងធ្វើឱ្យការងារសម្របសម្រួលជាទូទៅមានភាពកាន់តែប្រសើរឡើង លើកកម្ពស់ការតម្រង់ទិសឱ្យស៊ីសង្វាក់គ្នា និងធ្វើសុខដុមនីយកម្មនៃជំនួយសម្រាប់វិស័យសកម្មភាពមីន ក្រុមការងារ ក.ប.ម. ដែលមានអនុប្រធានទី១ អាជ្ញាធរមីន ជាប្រធាន បានជំរុញឱ្យមានកិច្ចប្រជុំយ៉ាងហោច ២ដងក្នុងមួយឆ្នាំ។ សម្រាប់រយៈពេល ៣ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ កិច្ចប្រជុំ ក.ប.ម. ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

- ទោះបីក្នុងឆ្នាំ២០១៨ កិច្ចប្រជុំក្នុងក្របខណ្ឌក.ប.ម. មិនត្រូវបានរៀបចំ ប៉ុន្តែអាជ្ញាធរមីនបានរៀបចំសន្និបាតជាតិវិស័យសកម្មភាពមីន ដែលបានប្រព្រឹត្តទៅរយៈពេលពីរថ្ងៃ គឺថ្ងៃទី១៦-១៧ ខែឧសភា ឆ្នាំ២០១៨ នៅវិមាន សន្តិភាព ក្រោមប្រធានបទ "ឆ្ពោះទៅរកកម្ពុជាមួយដែលគ្មានមីន ឆ្នាំ២០២៥" ដែលមានអ្នកចូលរួមសរុបប្រមាណ ៨០០នាក់ មកពីក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងស្ថានទូតថ្នាក់ដឹកនាំនិងមន្ត្រីអាជ្ញាធរមីន ប្រតិបត្តិករជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរថ្នាក់ក្រោមជាតិ ជនរងគ្រោះ អ្នកទទួលផល អង្គការនិងភ្នាក់ងារពាក់ព័ន្ធវិស័យសកម្មភាពមីន។ វេទិការនេះ គឺជាការប្រមូលផ្តុំ និងជំនួបនៃអ្នកជំនាញសំខាន់ៗ ពោរពេញដោយបទពិសោធន៍ និងការតាំងចិត្តខ្ពស់។
- ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩ អាជ្ញាធរមីនបានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍លើវិស័យមីន ក្នុងគោលបំណងចែករំលែកនូវព័ត៌មានមួយចំនួនស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ព្រមទាំងពិភាក្សាពីការកៀរគរធនធានហិរញ្ញវត្ថុ និងផ្តល់ជាវេទិកាសំណួរ-ចម្លើយផងដែរ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីតំណាងស្ថានទូតនៃ

បណ្តាប្រទេសផ្តល់ជំនួយ ប្រទេសក្នុងតំបន់អាស៊ាន តំណាងដៃគូអភិវឌ្ឍន៍ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងតំណាងប្រតិបត្តិករជាតិនិងអន្តរជាតិផងដែរ។

- ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍លើវិស័យមីន បានរៀបចំឡើងដោយអាជ្ញាធរមីន នៅសណ្ឋាគារ Garden City នៅរាជធានីភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីតំណាងស្ថានទូតនៃបណ្តាប្រទេសផ្តល់ជំនួយ ប្រទេសក្នុងតំបន់អាស៊ាន តំណាងដៃគូអភិវឌ្ឍន៍ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងតំណាងប្រតិបត្តិករជាតិនិងអន្តរជាតិផងដែរ ដើម្បីផ្សព្វផ្សាយលទ្ធផលនៃកិច្ចប្រជុំពិនិត្យឡើងវិញលើកទី៤ នៃអនុសញ្ញាអូតាវ៉ា និងផ្តល់ជាវេទិកាពិភាក្សាអំពីការកៀរគរធនធាន ក្នុងគោលបំណងឈានទៅសម្រេចបាននូវផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥ ព្រមទាំងផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពការងារវិស័យមីន បញ្ហាប្រឈម និងដំណោះស្រាយ។
- នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ អាជ្ញាធរមីនបានរៀបចំកិច្ចប្រជុំ ក.ប.ម. ជាលក្ខណៈចង្អៀតនៅសាលប្រជុំអាជ្ញាធរមីន ក្នុងគោលបំណងផ្សព្វផ្សាយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ដែលបានកែសម្រួលសមាសភាពសមាជិកក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍វិស័យមីន និងធ្វើបច្ចុប្បន្នភាពលើការងារសម្រេចបានក្នុងឆ្នាំ២០១៩ និងលើកទិសដៅសម្រាប់ឆ្នាំ២០២០ ព្រមទាំងបញ្ហាប្រឈម ដើម្បីសហការដោះស្រាយ និងឈានទៅសម្រេចឱ្យបានតាមផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥។ ក្រុមការងារបច្ចេកទេសចម្រុះនេះមានសមាសភាពមកពីអាជ្ញាធរមីន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកិច្ចការនារី បញ្ជាការដ្ឋានកងទ័ពជើងគោក អគ្គស្នងការដ្ឋាននគបាលជាតិ អាជ្ញាធរអាវុធគីមី មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា កាកបាទក្រហមកម្ពុជា គណៈកម្មាធិការព្រំដែន និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ជាមួយគ្នានេះ ក៏បានរៀបចំសិក្ខាសាលាប្រចាំឆ្នាំនៅថ្នាក់ខេត្ត ដើម្បីផ្សព្វផ្សាយអំពីវឌ្ឍនភាពការងារវិស័យមីន និងសិក្សាអំពីតម្រូវការអភិវឌ្ឍន៍របស់សហគមន៍ដែលងាយរងគ្រោះដោយសារមីននិងស.ផ.ស. នាពេលកន្លងមកផងដែរ។

# ជំពូកទី៨

# ការជំរុញនិសព្វាវុធការក្នុងតំបន់ និងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពមីន

ក្នុងឆាកអន្តរជាតិ កម្ពុជាជាប្រទេសមួយដែលមានការទទួលខុសត្រូវនិងមានការប្ដេជ្ញាចិត្តខ្ពស់ចំពោះវិស័យសកម្មភាពមីនមនុស្សធម៌ និងជារដ្ឋភាគីនៃអនុសញ្ញាអូតាវ៉ា និងរួមទាំងពិធីសារផ្សេងៗនៃអនុសញ្ញាសព្វាវុធធម្មតាមួយចំនួន(CCW)។ ជាមួយគ្នានេះ កម្ពុជាក៏បានចូលរួមអនុវត្តសកម្មភាពជាច្រើន ស្របតាមគោលការណ៍នៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោមផងដែរ។ ដូចដែលបានលើកឡើងខាងលើ កម្ពុជាបានប្ដេជ្ញាបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការអនុវត្តទៅតាមអនុសញ្ញានានាដោយសុឆន្ទៈ ទោះបីកម្ពុជាមិនទាន់ក្លាយជាប្រទេសហត្ថលេខីក៏ដោយ។ ចំពោះការជំរុញការងារនិសព្វាវុធការក្នុងតំបន់និងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពមីនដែលជាគោលបំណងទី៦ នៃផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន យើងបានសម្រេចនូវគោលដៅទី១ ស្តីពីការជំរុញការអនុវត្តកាតព្វកិច្ចនៃ អ.ហ.ផ.ម. និងគោលដៅទី៤ ស្តីពីការគាំទ្រដល់ប្រតិបត្តិការបោសសម្អាតមីន ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ។ ចំណែកគោលដៅចំនួន៣ទៀត គឺគោលដៅទី២ គោលដៅទី៣ និងគោលដៅទី៥ កម្ពុជាហៀបនឹងសម្រេចបាន។

| គោលបំណង | គោលដៅ | ការអនុវត្ត |
|---|---|---|
| ៦. ជំរុញនិសព្វាវុធការក្នុងតំបន់ និងអន្តរជាតិ និងកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពមីន | ៦.១ ជំរុញការអនុវត្តកាតព្វកិច្ចនៃ អ.ហ.ផ.ម. | សម្រេចបាន |
| | ៦.២ ជំរុញការអនុវត្តកាតព្វកិច្ចក្នុងអនុសញ្ញាធម្មតាមួចំនួន (CCW) និងគាំទ្រដល់វឌ្ឍនភាពឆ្ពោះទៅរកការចូលរួមក្នុងពិធីសារទី៥ | ហៀបនឹងសម្រេចបាន |
| | ៦.៣ គាំទ្រដល់ការចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម (CCM) ត្រឹមឆ្នាំ២០២០ | ហៀបនឹងសម្រេចបាន |
| | ៦.៤ គាំទ្រដល់ប្រតិបត្តិការបោសសម្អាតមីន ក្នុងក្របខណ្ឌនៃប្រតិបត្តិការរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ | សម្រេចបាន |
| | ៦.៥ លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិសកម្មភាពមីន រាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង | ហៀបនឹងសម្រេចបាន |

## ៨.១ ការជំរុញការអនុវត្តកាតព្វកិច្ច នៃអ.ហ.ផ.ម.

កម្មវិធីសកម្មភាពមីនមនុស្សធម៌នៅកម្ពុជា បានចាប់ផ្ដើមឡើងនៅឆ្នាំ១៩៩២ ហើយនៅឆ្នាំ ២០០០ កម្ពុជាបានក្លាយជារដ្ឋភាគីនៃអនុសញ្ញា អ.ហ.ផ.ម.។ មាត្រា៥ នៃអនុសញ្ញានេះចែងអំពី

កាតព្វកិច្ចរបស់រដ្ឋភាគី ដោយត្រូវបោសសម្អាតផ្ទៃដីដែលមានមីនប្រឆាំងមនុស្សទាំងអស់ ក្នុងរយៈពេលយ៉ាងយូរ ១០ឆ្នាំ (២០០០-២០០៩)។ ដោយសារវិសាលភាព និងភាពស្មុគស្មាញនៃបញ្ហាគ្រាប់មីន និង ស.ផ.ស. និងការធ្លាក់ចុះនៃជំនួយថវិកា កម្ពុជាបានរៀបចំសំណើសុំពន្យារពេលបោសសម្អាតមីនលើកទី១ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៩ និងលើកទី២ ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៥ ហើយសំណើសុំពន្យាពេលលើកទី២នេះបានទទួលការឯកភាពនៅក្នុងកិច្ចប្រជុំពិនិត្យឡើងវិញលើកទី៤ ( Fourth Review Conference ) នៃអនុសញ្ញា អ.ហ.ផ.ម. នៅចុងឆ្នាំ២០១៩ ផងដែរ។

កម្ពុជាក៏បានរៀបចំរបាយការណ៍តម្លាភាពប្រចាំឆ្នាំ (Transparency Report) បានទាន់ពេលវេលាស្របតាមមាត្រា៧ នៃអនុសញ្ញា ដើម្បីរាយការណ៍អំពីលទ្ធផលដែលសម្រេចបានក្នុងកិច្ចប្រតិបត្តិការបោសសម្អាតមីន ការកាត់បន្ថយអត្រាគ្រោះថ្នាក់ កិច្ចសង្គ្រោះជនរងគ្រោះ និងការអប់រំយល់ដឹងអំពីមីន។ ជាមួយគ្នានេះ ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរមីន ត្រូវបានចាត់តាំងជាមន្ត្រីទទួលបន្ទុកសម្របសម្រួលការងារជាមួយប្រតិបត្តិករនិងភាគីពាក់ព័ន្ធ ព្រមទាំងបានធ្វើការជាមួយភ្នាក់ងារគាំទ្រការអនុវត្តប្រចាំទីក្រុងហ្សឺណែវ ( ISU ) និងមជ្ឈមណ្ឌលបោសសម្អាតមីនមនុស្សធម៌ប្រចាំទីក្រុងហ្សឺណែវ( GICHD )ផងដែរ។

ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តក្នុងការជំរុញការអនុវត្តកាតព្វកិច្ចនៃ អ.ហ.ផ.ម. ជារៀងរាល់ឆ្នាំ ថ្នាក់ដឹកនាំអាជ្ញាធរមីន និងតំណាងប្រតិបត្តិករជាតិនិងអន្តរជាតិ បានចូលរួមកិច្ចប្រជុំនាយកកម្មវិធីមីនថ្នាក់ជាតិ និងទីប្រឹក្សានៃអង្គការសហប្រជាជាតិ ( NDM-UN ) និងកិច្ចប្រជុំពាក់កណ្តាលវគ្គ ( Intersessional Meeting ) ព្រមទាំងកិច្ចប្រជុំពេញអង្គនៃអនុសញ្ញាអ.ហ.ផ.ម.។ ជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំអាជ្ញាធរមីនព្រមទាំងតំណាងប្រតិបត្តិករជាតិនិងអន្តរជាតិ បានចូលរួមសន្និសីទត្រួតពិនិត្យឡើងវិញលើកទី៤ នៃអនុសញ្ញាអូតាវ៉ា ( Fourth Review Conference ) នៅទីក្រុងអូស្លូ ប្រទេសន័រវេស ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ រួមទាំងកិច្ចប្រជុំពាក់ព័ន្ធវិស័យមីនកម្រិតតំបន់និងអន្តរជាតិផ្សេងទៀត។

## ៨.២ ការជំរុញការអនុវត្តកាតព្វកិច្ចក្នុងអនុសញ្ញាធម្មតាមួយចំនួន (CCW) និងគាំទ្រដល់វឌ្ឍនភាពឆ្ពោះទៅរកការចូលរួមក្នុងពិធីសារទី៥

កម្ពុជាជារដ្ឋភាគីនៃអនុសញ្ញា CCW ( ពិធីសារទី១ ទី២ ទី៣ និងទី៤ ) ក្នុងក្របខ័ណ្ឌអនុសញ្ញានេះ អាជ្ញាធរមីន បានសម្របសម្រួលជាមួយប្រតិបត្តិករជាតិនិងអន្តរជាតិ រៀបចំនិងបញ្ជូនរបាយការណ៍ស្តីពីការអនុវត្តកាតព្វកិច្ចនៃអនុសញ្ញា CCW ជារៀងរាល់ឆ្នាំ និងបានទាន់ពេលវេលា។ ជាមួយគ្នានេះ ជាក្នុងរយៈពេល៣ឆ្នាំ ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០ កម្ពុជាបានធ្វើការបោសសម្អាតផ្ទៃដីដែលមានគ្រាប់មីន និងស.ផ.ស. សរុបចំនួន ៤២០.៦៩៥.១៤៥ ម៉ែត្រការ៉េ និងកំពុងសិក្សាលទ្ធភាព ចូលរួមក្នុងពិធីសារទី៥ នៃអនុសញ្ញា CCW ផងដែរ។

### ៨.៣ ការគាំទ្រដល់ការចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម (CCM) ត្រឹមឆ្នាំ២០២០

ទោះបីជាកម្ពុជា មិនមែនជារដ្ឋហត្ថលេខីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម (CCM) ក៏កម្ពុជានៅតែអនុវត្តសកម្មភាពស្របទៅនឹងគោលការណ៍នៃអនុសញ្ញានេះ រួមមាន ការស្រាវជ្រាវ ការបោសសម្អាត ការអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់ ការជួយសង្គ្រោះជនរងគ្រោះ និងសកម្មភាពផ្សេងៗទៀតដែលពាក់ព័ន្ធនឹងគ្រាប់បែកចង្កោម ព្រមទាំងបានចូលរួមគ្រប់កិច្ចប្រជុំពាក់ព័ន្ធនឹងអនុសញ្ញានេះ ក្នុងនាមជាអ្នកសង្កេតការណ៍។ កម្ពុជាបានបង្ហាញអំពីគោលជំហរគាំទ្ររបស់ខ្លួនចំពោះអនុសញ្ញានេះ ហើយបានពិនិត្យជាប្រចាំពីលទ្ធភាពនៃការចូលរួមជារដ្ឋហត្ថលេខីនៃអនុសញ្ញានេះ។

លើសពីនេះទៅទៀត ក្នុងការគាំទ្រអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម អាជ្ញាធរមីនបានសហការជាមួយប្រតិបត្តិករនិងភាគីពាក់ព័ន្ធ ធ្វើការពង្រឹងនីតិវិធីនិងគោលការណ៍ប្រតិបត្តិការរំដោះផ្ទៃដីដែលមានគ្រាប់បែកចង្កោម ដោយបង្កើតស្តង់ដារកំចាត់មីនកម្ពុជាជំពូកទី១៦ ព្រមទាំងប្រឹងប្រែងកៀរគរធនធានដើម្បីស្រាវជ្រាវបោសសម្អាត អប់រំផ្សព្វផ្សាយ ជួយជនរងគ្រោះ និងធ្វើសេចក្តីរាយការណ៍ជាប្រចាំពីស្ថានភាពគ្រាប់បែកចង្កោមនៅភាគខាងកើតនៃប្រទេសផងដែរ។

### ៨.៤ គាំទ្រដល់ប្រតិបត្តិការបោសសម្អាតមីន ក្នុងក្របខណ្ឌនៃប្រតិបត្តិការរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ

ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្រាប់កិច្ចសហប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិ (UN Peacekeeping Operations) កងយោធពលខេមរភូមិន្ទ បានចូលរួមយ៉ាងសកម្ម ហើយប្រទេសដែលកងយោធពលខេមរភូមិន្ទបានចូលរួមបំពេញបេសកកម្ម រួមមាន ប្រទេសស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ អាហ្វ្រិកកណ្តាល ម៉ាលី លីបង់ ស៊ីបស៊ីរី និងយេម៉ែន។ ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២០ មានកងកម្លាំងមួកខៀវកម្ពុជាសរុបចំនួន **៦.៥៥៧ នាក់** ក្នុងនោះមានស្ត្រីចំនួន **៣៣៨នាក់** លើជំនាញបោសសម្អាតមីន វិស្វកម្ម សំណង់ផ្តេក-បញ្ឈរ អាវុធហត្ថ មន្ទីរពេទ្យកម្រិត២ វិស្វកម្មព្រលានយន្តហោះ កម្ទេចគ្រឿងផ្ទុះ នាយទាហានសេនាធិការ និងសង្កេតការណ៍យោធា។

ដើម្បីធានាថា   ប្រតិបត្តិការបោសសម្អាតមីនក្នុងក្របខ័ណ្ឌប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ត្រូវបានទទួលស្គាល់ស្របតាមស្តង់ដារសកម្មភាពមីនអន្តរជាតិ (IMAS) សមត្ថភាពក្នុងការអនុវត្តប្រតិបត្តិការសន្តិភាព   និងការបោសសម្អាតមីនត្រូវបានពង្រឹងជាបន្តបន្ទាប់។ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ មន្ត្រីកងយោធពលខេមរភូមិន្ទចំនួន៦ក្រុម (២ក្រុមក្នុង១ឆ្នាំ) ត្រូវបានហ្វឹកហ្វឺន និងទទួលស្គាល់ក្នុងការអនុវត្តប្រតិបត្តិការរក្សាសន្តិភាព និងបោសសម្អាតមីនក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ។



*សកម្មភាពបោសសម្អាតមីនរបស់ RCAF/NPMEC ដែលកំពុងបំពេញបេសកកម្ម នៅប្រទេសលីបង់*

ដោយឡែក សម្រាប់ឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ កងទ័ពមួកខៀវកម្ពុជាចំនួន ១៥ក្រុម ដែលត្រូវបានទទួលស្គាល់ក្នុងប្រតិបត្តិការបោសសម្អាតមីននិងកម្ទេចគ្រឿងផ្ទុះ ត្រូវបានចាត់តាំងឱ្យទៅចូលរួមបំពេញបេសកកម្មរក្សាសន្តិភាពក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិ   នៅប្រទេសស៊ូដង់   ស៊ូដង់ខាងត្បូង អាហ្វ្រិកកណ្តាល ម៉ាលី និងលីបង់ ដោយមានកងកម្លាំងមួកខៀវកំពុងឈរជើងចំនួន ៧៨៧នាក់ ក្នុងនោះមានស្ត្រី ៦៥នាក់។ កាលពីខែកញ្ញា ឆ្នាំ២០១៩ អង្គការសហប្រជាជាតិបានចាត់ចំណាត់ថ្នាក់ប្រទេសកម្ពុជាជាប្រទេសបរិច្ចាគកម្លាំងសរុបលំដាប់លេខ ២៨ និងជាប្រទេសបរិច្ចាគកម្លាំងស្ត្រីលំដាប់លេខ២០ ក្នុងចំណោម ១២០ប្រទេស ដែលបានបរិច្ចាគកម្លាំងចូលរួមបេសកកម្ម និងលំដាប់ថ្នាក់លេខ២ ក្នុងចំណោមប្រទេសស្ថិតក្នុងតំបន់អាស៊ាន ដែលបានបញ្ជូនយុទ្ធនារីទៅកាន់តំបន់បេសកកម្ម។

## ៨.៥ ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិសកម្មភាពមីន រាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង

កម្ពុជាបានចូលរួមចែករំលែកបទពិសោធន៍តាមរយៈសិក្ខាសាលាថ្នាក់ជាតិ តំបន់ និងអន្តរជាតិជាមួយបណ្តាប្រទេសពាក់ព័ន្ធសកម្មភាពមីន   និងបានចូលរួមយ៉ាងសកម្មក្នុងការកសាងសមត្ថភាពក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការត្បូងត្បូង   សំដៅចែករំលែកនូវបទពិសោធន៍ទៅវិញទៅមកតាមរយៈទស្សនកិច្ចសិក្សាជាមួយបណ្តាប្រទេសដែលមានបញ្ហាមីននិងស.ផ.ស. ក្នុងជំនាញការគ្រប់គ្រងវិស័យសកម្មភាពមីនថ្នាក់ជាតិ ការស្រាវជ្រាវ ការធ្វើផែនការ និងការចាត់អាទិភាព ការគ្រប់គ្រងហានិភ័យស.ផ.ស.រយៈពេលវែង និងការគ្រប់គ្រងទិន្នន័យជាដើម។

ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការត្បូង-ត្បូង គាំទ្រដោយភ្នាក់ងារ JICA នៃប្រទេសជប៉ុន CMAC បានរៀបចំវគ្គហ្វឹកហ្វឺន និងចែករំលែកបទពិសោធន៍ ចំនួន៩វគ្គ លើប្រធានបទមួយចំនួនដូចជា ការគ្រប់គ្រងសកម្មភាពមីន ការធ្វើផែនការនិងចាត់អាទិភាព ការអនុវត្តរំដោះផ្ទៃដី ការគ្រប់គ្រងធនធានមនុស្ស ព្រមទាំងប្រតិបត្តការកំទេចគ្រឿងផ្ទុះ ដែលមានអ្នកចូលរួមសរុបចំនួន២០១នាក់ ក្នុងនោះមានស្ត្រីចំនួន១១នាក់ មកពីប្រទេសអ៊ីរ៉ាក់ កូឡុំប៊ី និងឡាវ។



*គណៈប្រតិភូប្រទេសវៀតណាម និងឡាវ មកសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍ការងារវិស័យសកម្មភាពមីននៅព្រះរាជាណាចក្រកម្ពុជា*

ចំពោះការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យមីន កម្ពុជានៅមិនទាន់បានអនុវត្តបានពេញលេញជាលក្ខណៈប្រព័ន្ធនៅឡើយ។ ជាក់ស្តែង ការបង្កើតឱ្យមានជាស្ថាប័នថ្នាក់ជាតិគ្រប់គ្រងសមត្ថភាពបោសសម្អាតមីន សម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិ នៅមិនទាន់សម្រេចបាននៅឡើយ។ ទន្ទឹមនឹងនេះ មានសកម្មភាពសំខាន់ៗមួយចំនួនទៀត ក៏នៅមិនទាន់សម្រេចបាននៅឡើយ រួមមាន៖ ១-ការកំណត់សមត្ថភាពជំនាញចាំបាច់ក្នុងវិស័យមីនសម្រាប់កិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិ ២-ការវាយតម្លៃសមត្ថភាពជាតិក្នុងការឆ្លើយតបចំពោះតម្រូវការនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ៣-ការបង្កើតយន្តការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអន្តរជាតិ និង ៤-ការរៀបចំជាស្តង់ដារប្រព័ន្ធរួមដើម្បីពង្រឹងសមត្ថភាពជំនាញ។

ជាមួយគ្នានេះ កម្ពុជាបានគាំទ្រដល់រដ្ឋផ្សេងៗ ដែលរងផលប៉ះពាល់ដោយសារមីននិងស.ផ.ស. តាមរយៈប្រតិបត្តិការបោសសម្អាតមីន។ បន្ថែមលើនេះ កម្ពុជាក៏បានចែករំលែកបទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបានពីការអនុវត្តក្នុងសកម្មភាពមីន តាមរយៈយន្តការសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិនៃមជ្ឈមណ្ឌលសកម្មភាពមីនអាស៊ាន (ARMAC) និងយន្តការផ្សេងៗទៀត ព្រមទាំងបានបញ្ជូនមន្ត្រីជំនាញរបស់កម្ពុជាទៅចូលរួមធ្វើជាវាគ្មិន និងធ្វើបទបង្ហាញក្នុងវេទិកាអន្តរជាតិផងដែរ។

មជ្ឈមណ្ឌល ARMAC ត្រូវបានបង្កើតឡើងដើម្បីជួយគាំទ្រដល់ប្រទេសជាសមាជិកអាស៊ានក្នុងការដោះស្រាយបញ្ហាដែលកើតឡើងដោយសារផលប៉ះពាល់ដោយសារមីននិងស.ផ.ស. ដោយផ្តោតសំខាន់លើការងារអាទិភាពចំនួន ៣ រួមមាន៖ ១-ការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ២-ការសម្របសម្រួលក្នុងកិច្ចស្តារនីតិសម្បទានិងវេជ្ជសាស្ត្រដល់ជនរងគ្រោះដោយសារមីននិងស.ផ.ស. និង ៣-ការជួយក្នុងកិច្ចការស្រាវជ្រាវនិងការចែករំលែកចំណេះដឹង។

តាមរយៈការគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ នៅឆ្នាំ២០១៩ មជ្ឈមណ្ឌល ARMAC បានអនុវត្តគម្រោងចំនួន៧ បានយ៉ាងជោគជ័យ គម្រោងទាំងនោះរួមមានការរៀបចំសិក្ខាសាលា និងការបណ្តុះបណ្តាលថ្នាក់តំបន់ក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន ដើម្បីចែករំលែកនិងបង្កើនសមត្ថភាពក្នុងផ្នែកសកម្មភាពមីន ដោយមានការចូលរួមពីតំណាងស្ថាប័នថ្នាក់តំបន់និងអន្តរជាតិ។

នៅក្នុងខែមេសា ឆ្នាំ២០១៩ មជ្ឈមណ្ឌល ARMAC បានរៀបចំទិវាអន្តរជាតិយល់ដឹងអំពីមីន ដោយបានសហការជាមួយរាជរដ្ឋាភិបាលន័រវេស រាជរដ្ឋាភិបាលថៃ រដ្ឋាភិបាលអៀរឡង់ គម្រោងបោសសម្អាតមីនដើម្បីលទ្ធផល (CFR) មជ្ឈមណ្ឌលជាតិ RCAF/NPMEC បណ្តាញសាកលវិទ្យាល័យអាស៊ី (AUN) និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាយព្រាប។

នៅក្នុងខែឧសភា ឆ្នាំ២០១៩ មជ្ឈមណ្ឌល ARMAC បានអនុវត្តគម្រោងលើកកម្ពស់ការអប់រំយល់ដឹងអំពីមីន ក្នុងប្រទេសសមាជិកអាស៊ាន (Enhance Awareness Program on the Danger of Mine/ERW Among Asian Member States) ដែលគាំទ្រថវិកាដោយមូលនិធិសមាហរណកម្មជប៉ុន-អាស៊ាន (Japan-Asian Integrated Funds) ដើម្បីកាត់បន្ថយគ្រោះថ្នាក់ក្នុងប្រទេសរងផលប៉ះពាល់និងចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងតំបន់។

ជាងនេះទៀត មជ្ឈមណ្ឌល ARMAC បានសហការជាមួយ GICHD និងរដ្ឋាភិបាលអៀរឡង់ រៀបចំវគ្គហ្វឹកហ្វឺនចំនួន៥ថ្ងៃ ស្តីពីប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការបោសសម្អាតមីន។ ជាមួយគ្នានេះ ARMAC បានសហការជាមួយមជ្ឈមណ្ឌលសកម្មភាពមីនប្រទេសថៃ (TMAC), GICHD, រដ្ឋាភិបាលអៀរឡង់ និងគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម បានរៀបចំវគ្គហ្វឹកហ្វឺនស្តីពីការគ្រប់គ្រងហានិភ័យនៃសកម្មភាពមីន ដែលបានប្រព្រឹត្តទៅនៅខេត្តនុនថាប៊ូរី ប្រទេសថៃ។



*សកម្មភាពគណៈប្រតិភូប្រទេសភូមាទស្សនកិច្ចសិក្សានៅចម្ការមីនដែលបោសសម្អាតដោយអង្គការ MAG នៅក្នុងខេត្តបាត់ដំបង។*

នៅឆ្នាំ២០១៩ មជ្ឈមណ្ឌល ARMAC បានសហការជាមួយរដ្ឋាភិបាលឡាវ រៀបចំសិក្ខាសាលាថ្នាក់តំបន់ស្តីពីសមភាពយេនឌ័រនិងលើកកម្ពស់ស្ត្រី នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដោយមានការគាំទ្រពីរដ្ឋាភិបាលកាណាដា និងគម្រោងបោសសម្អាតមីនដើម្បីលទ្ធផលនៃប្រទេសកម្ពុជា និងការគាំទ្របច្ចេកទេសពី GICHD។

# ជំពូកទី៩

# ការបង្កើតសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥

ការបង្កើតសមត្ថភាពជាតិប្រកបដោយនិរន្តរភាព គឺជាកិច្ចការងារសំខាន់ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥។ ដើម្បីសម្រេចបាននូវគោលបំណងនេះ យើងបានកំណត់គោលដៅចំនួន៤ ក្នុងនោះមាន៖ ១-ការពង្រឹងសមត្ថភាពជាតិ ដើម្បីគ្រប់គ្រង និងអនុវត្តកម្មវិធីសកម្មភាពមីនប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល ២-ការថែរក្សាកែលម្អ ការចែករំលែកចំណេះដឹងស្តីពីសកម្មភាពមីនក្នុងវិស័យនេះដល់វិស័យផ្សេងទៀត ៣-ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំងយុទ្ធសាស្ត្រនិងសមត្ថភាព ៤-ការពង្រឹងនិងថែរក្សាសមត្ថភាពជាតិប្រកបដោយនិរន្តភាពដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥។ ជាទូទៅ សកម្មភាពជាយុទ្ធសាស្ត្រក្នុងការសម្រេចបាននូវគោលដៅនៃគោលបំណងទី៧នេះមិនទាន់បានសម្រេចនៅឡើយ ដោយសារសកម្មភាពមួយចំនួនធំនៅមិនទាន់មានតម្រូវការអនុវត្តនៅឡើយ។

| គោលបំណង | គោលដៅ | ការអនុវត្ត |
|---|---|---|
| ៧. បង្កើតសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥ | ៧.១ ពង្រឹងសមត្ថភាពជាតិដើម្បីគ្រប់គ្រង និងអនុវត្តកម្មវិធីសកម្មភាពមីនប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល | ហៀបនឹងសម្រេចបាន |
| | ៧.២ ថែរក្សា កែលម្អ និងចែករំលែកចំណេះដឹងអំពីសកម្មភាពមីនក្នុងវិស័យនេះដល់វិស័យផ្សេងទៀត | មិនទាន់សម្រេចបាន |
| | ៧.៣ ធ្វើការពិនិត្យមើលឡើងវិញត្រឹមឆ្នាំ២០២០ នូវក្របខណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំងយុទ្ធសាស្ត្រ និងសមត្ថភាព ដែលចាំបាច់ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ | មិនទាន់សម្រេចបាន |
| | ៧.៤ ពង្រឹង និងថែរក្សាសមត្ថភាពជាតិប្រកបដោយនិរន្តភាពដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥ ឱ្យមានប្រសិទ្ធភាព (ចាប់ផ្តើមឆ្នាំ២០២០) | មិនទាន់មានតម្រូវការក្នុងការអនុវត្ត |

## ៩.១. ពង្រឹងសមត្ថភាពជាតិដើម្បីគ្រប់គ្រង និងអនុវត្តកម្មវិធីសកម្មភាពមីន ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល

ការពង្រឹងសមត្ថភាពជាតិ គឺជាកិច្ចការសំខាន់ក្នុងការគ្រប់គ្រង និងអនុវត្តកម្មវិធីសកម្មភាពមីន ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល ក្នុងការដោះស្រាយបញ្ហាគ្រាប់មីននិងស.ផ.ស.សម្រាប់រយៈពេលវែង។

ជាមួយគ្នានោះ អាជ្ញាធរមីនបានធ្វើការវាយតម្លៃសេចក្តីត្រូវការផ្នែកអភិវឌ្ឍន៍សមត្ថភាពជាតិ និងរៀបចំវាយតម្លៃលើរចនាសម្ព័ន្ធការអភិវឌ្ឍសមត្ថភាពដែលមានស្រាប់ក្នុងកម្រិតក្របខ័ណ្ឌអាជ្ញាធរមីន។ ដោយមានការគាំទ្រថវិកា និងបច្ចេកទេសពីអង្គការ NPA ក្រុមការងារបានបង្កើតផែនការអភិវឌ្ឍន៍សមត្ថភាពក្នុងការពង្រឹង និងថែរក្សាឱ្យមាននិរន្តរភាពនូវសមត្ថភាពរបស់អាជ្ញាធរថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងអាណត្តិការងារក្នុងនោះរួមមាន៖ ១-ប្រព័ន្ធគ្រប់គ្រងគុណភាព នីតិវិធី និងការអនុវត្ត ២-ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យានិងទិន្នន័យ ៣-ការធ្វើផែនការនិងចាត់អាទិភាព នីតិវិធី និងការអនុវត្ត ៤-ការរៀបចំផែនការយុទ្ធសាស្ត្រ នីតិវិធី និងការអនុវត្ត ៥-សមភាពយេនឌ័រនិងការបញ្ជ្រាបយេនឌ័រ និង ៦-ការគ្រប់គ្រងចំណេះដឹងនិងជំនាញក្នុងវិស័យមីន។ ជាទូទៅ សកម្មភាពជាយុទ្ធសាស្ត្រក្នុងគោលដៅនៃការពង្រឹងសមត្ថភាពជាតិ ដើម្បីគ្រប់គ្រងនិងអនុវត្តកម្មវិធីសកម្មភាពមីនប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល បានសម្រេចមួយចំនួនធំ ប៉ុន្តែមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលអាចនិយាយបានថា យើងហៀបនឹងសម្រេចបាននូវគោលដៅនេះ។

## ៩.២ ថែរក្សា កែលម្អ និងចែករំលែកចំណេះដឹងអំពីសកម្មភាពមីន នៅក្នុងវិស័យនេះទៅដល់វិស័យផ្សេងទៀត

វិស័យមីននៅកម្ពុជា មានអាយុកាលប្រមាណ២៨ឆ្នាំមកហើយ គិតចាប់តាំងពីឆ្នាំ១៩៩២ មកដល់ ២០២០។ ប្រសិនបើពិនិត្យលើជំនាញ ចំណេះដឹង និងឧត្តមានុវត្ត ក្នុងការគ្រប់គ្រងនិងអនុវត្តសកម្មភាពមីន វិស័យនេះអាចចែករំលែកបទពិសោធន៍ដ៏ជោគជ័យរបស់ខ្លួនទៅវិស័យផ្សេងៗទៀតដូចជា ការរៀបចំផែនការយុទ្ធសាស្ត្រជាតិ ការរៀបចំស្តង់ដារជាតិ ការធ្វើផែនការ និងចាត់អាទិភាព ការស្រាវជ្រាវ និងការគ្រប់គ្រងព័ត៌មាននិងទិន្នន័យ ការរៀបចំយន្តការសម្របសម្រួល ការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងការហ្វឹកហ្វឺនជាដើម។ អាជ្ញាធរមីន គ្រោងបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងចំណេះដឹងសម្រាប់វិស័យមីនឱ្យមានប្រសិទ្ធភាព ដើម្បីរក្សាទុកទាញយកប្រើប្រាស់ ផ្ទេរ និងអភិវឌ្ឍចំណេះដឹង ប៉ុន្តែសម្រាប់រយៈពេល៣ឆ្នាំ ពីឆ្នាំ២០១៨ដល់ឆ្នាំ ២០២០ យើងបានត្រឹមបង្កើតយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងចំណេះដឹង និងផែនការសកម្មភាពសម្រាប់ស្ថាប័នអាជ្ញាធរមីនតែប៉ុណ្ណោះ ដោយសារការខ្វះខាតធនធាន និងការរាតត្បាតនៃជំងឺកូវីដ-១៩។ ចំពោះការបង្កើតមជ្ឈមណ្ឌលធនធាន និងប្រព័ន្ធគ្រប់គ្រងចំណេះដឹងវិស័យមីន គឺនៅមិនទាន់សម្រេចបាននៅឡើយ។ ជារួមសម្រាប់គោលលដៅទី២ នៃគោលបំណងទី៧ កម្ពុជានៅមិនទាន់អាចសម្រេចបានពេញលេញនៅឡើយទេ។

### ៩.៣ ធ្វើការពិនិត្យមើលឡើងវិញត្រឹមឆ្នាំ២០២០ នូវក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងប្រតិបត្តិការ ព្រមទាំង យុទ្ធសាស្ត្រ និងសមត្ថភាព ដែលចាំបាច់ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសេសសល់

រចនាសម្ព័ន្ធនៃវិស័យសកម្មភាពមីននៅកម្ពុជា ត្រូវបានធ្វើការបែងចែកដាច់ពីគ្នារវាងមុខងារគោលនយោបាយនិងនិយ័តកម្ម ការធ្វើផែនការនិងចាត់អាទិភាព ការផ្តល់សេវាកម្មបោសសម្អាតមីន និងប្រតិបត្តិការឆ្លើយតបជាអន្តរជាតិ។ ការបែងចែកបែបនេះ ត្រូវបានចាត់ទុកថា ស្របទៅតាមឧត្តមានុវត្តនានាដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ ប៉ុន្តែតទៅមុខទៀត រចនាសម្ព័ន្ធនេះ អាចនឹងមានការផ្លាស់ប្តូរ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបញ្ហាគ្រាប់មីននិងស.ផ.ស. ដែលនៅសេសសល់។

នៅក្នុងឆ្នាំ២០២០ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ យើងពុំទាន់បានធ្វើការវាយតម្លៃអំពីក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌប្រតិបត្តិការ ព្រមទាំងសមត្ថភាពសម្រាប់ដោះស្រាយការគំរាមកំហែងដែលនៅសល់ ក៏ដូចជាការកំណត់អំពីការអភិវឌ្ឍសមត្ថភាព និងធនធានដែលចាំបាច់នានានៅឡើយ ។

### ៩.៤ ពង្រឹង និងថែរក្សាសមត្ថភាពជាតិប្រកបដោយនិរន្តភាពដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥ ឱ្យមានប្រសិទ្ធភាព (ចាប់ផ្តើមឆ្នាំ២០២០)

បន្ទាប់ពីការពិភាក្សាកម្រិតបច្ចេកទេសនិងកម្រិតនយោបាយ ទៅលើការពង្រឹងនិងថែរក្សាសមត្ថភាពជាតិប្រកបដោយនិរន្តភាព ដើម្បីដោះស្រាយការគំរាមកំហែងដែលនៅសល់ក្រោយឆ្នាំ២០២៥ អ្នកជំនាញក្នុងវិស័យមីនបានឯកភាពរួមគ្នា និងយល់ឃើញថា ការងារនេះមិនទាន់មានតម្រូវការចាំបាច់ក្នុងការអនុវត្តនៅឡើយ ហើយគ្រោងនឹងអនុវត្តនៅឆ្នាំ២០២២ ឬឆ្នាំ២០២៣។

# ជំពូកទី១០

# ការធានារាល់សកម្មភាពមីនទាំងអស់ត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាពដែលមានភាពល្អប្រសើរ ការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ការយកចិត្តទុកដាក់ខ្ពស់ អំពីយេនឌ័រ និងការការពារបរិស្ថាន

ក្នុងការអនុវត្តការងារជាក់ស្តែង ការដោះស្រាយបញ្ហាមីននិងស.ផ.ស. មិនមែនមានត្រឹមតែការបោសសម្អាតប៉ុណ្ណោះទេ ប៉ុន្តែមានសកម្មភាពជាច្រើនទៀតដែលវិស័យនេះត្រូវអនុវត្ត ដូចជាការបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងគុណភាព ការបញ្ជ្រាបយេនឌ័រ ការកាត់បន្ថយផលប៉ះពាល់នៃការបោសសម្អាតមីនទៅលើបរិស្ថាន ការស្រាវជ្រាវ និងការអភិវឌ្ឍវិធីសាស្ត្របច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិត និងការគ្រប់គ្រងព័ត៌មានវិស័យនេះប្រកបដោយប្រសិទ្ធភាពជាដើម។

| គោលបំណង | គោលដៅ | ការអនុវត្ត |
|---|---|---|
| ៨. ធានារាល់សកម្មភាពមីនទាំងអស់ត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាពដែលមានភាពល្អប្រសើរ ការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ការយកចិត្តទុកដាក់ខ្ពស់ អំពីយេនឌ័រ និងការការពារបរិស្ថាន | ៨.១ ពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាព | សម្រេចបាន |
| | ៨.២ ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិសម្រាប់សកម្មភាពមីន | មិនទាន់សម្រេចបាន |
| | ៨.៣ ជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពមីន | សម្រេចបាន |
| | ៨.៤ បញ្ជ្រាបកិច្ចការការពារបរិស្ថានក្នុងសកម្មភាពមីន | មិនទាន់សម្រេចបាន |

## ១០.១ ពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាព


*ក្រុមត្រួតពិនិត្យអាជ្ញាធរមីនពិនិត្យ និងសាកល្បងលើសម្ភារបោសសម្អាតមីនរបស់ CMAC*

អាជ្ញាធរមីន មានតួនាទីសំខាន់ក្នុងការចុះត្រួតពិនិត្យកិច្ចប្រតិបត្តិការបោសសម្អាតមីន និងស.ផ.ស. របស់ប្រតិបត្តិករដែលទទួលបានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណផ្លូវការពីអាជ្ញាធរមីន។ ដើម្បីអនុវត្តការងារត្រួតពិនិត្យឱ្យបានជោគជ័យ ក្រុមត្រួតពិនិត្យអាជ្ញាធរមីន ទាំង៨ក្រុមដែលឈរជើងនៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន ខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តស្ទឹងត្រែង បានចុះត្រួតពិនិត្យប្រតិបត្តិការបោសសម្អាតមីន និងស.ផ.ស. របស់ប្រតិបត្តិករ ដើម្បីធានាការអនុវត្តស្របតាមស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជា។ បន្ថែមលើនេះ ក្រុមត្រួតពិនិត្យក៏បានពិនិត្យផ្ទៃដី

ដែលបានបោសសម្អាតរួច ដើម្បីធានាថាដីទាំងនោះមានសុវត្ថិភាព មុនពេលប្រគល់ជូនប្រជាពលរដ្ឋប្រើប្រាស់។

សកម្មភាពដែលត្រូវបានត្រួតពិនិត្យគុណភាព រួមមាន ការស្រាវជ្រាវ ការបោសសម្អាតមីនដោយដៃ ការប្រើគ្រឿងចក្រជាជំនួយ ការប្រើសត្វជាជំនួយ ការអប់រំយល់ដឹងអំពីមីន ប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះ និងការរក្សាទុកគ្រឿងផ្ទុះ។ ជាលទ្ធផល ៩០% នៃចំនួនដងនៃការចុះត្រួតពិនិត្យ ត្រូវបានរកឃើញថាបានអនុវត្តត្រឹមត្រូវស្របតាមស្តង់ដារជាតិ។

| **ការចុះត្រួតពិនិត្យការងាររបស់ក្រុមការងារគ្រប់គ្រងគុណភាពអាជ្ញាធរមីន** | | | | | | |
|---|---|---|---|---|---|---|
| **ប្រតិបត្តិករ** | **ឆ្នាំ២០១៨** | | **ឆ្នាំ២០១៩** | | **ឆ្នាំ២០២០** | |
| | ចំនួន (ដង) | ចំនួន (ចម្ការមីន) | ចំនួន (ដង) | ចំនួន (ចម្ការមីន) | ចំនួន (ដង) | ចំនួន (ចម្ការមីន) |
| CMAC | ៥៦៧ | ៥៦៤ | ៧៩៦ | ៧៧០ | ៩០១ | ៨៧៨ |
| NPMEC | ០ | ០ | ៣ | ៣ | ៣ | ៣ |
| HALO Trust | ៥៤២ | ៥១៨ | ៤៦៥ | ៤៦១ | ៥០៦ | ៤៨០ |
| MAG | ២៣៣ | ១៩៩ | ៣២៨ | ៣០១ | ៣១៣ | ២៨៨ |
| CSHD | ២៣ | ២៧ | ៣៦ | ៧ | ៣៨ | ១១ |
| NPA | ៣៤ | ២៩ | ៥៤ | ៥១ | ៤៦ | ៤៥ |
| សរុប | **១.៣៩៩** | **១.៣១៧** | **១.៦៨២** | **១.៥៩៣** | **១.៨០៧** | **១.៧០៥** |

ជាមួយគ្នានេះ អាជ្ញាធរមីនបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ក្នុងនោះមានប្រតិបត្តិករជាតិនិងអន្តរជាតិ និងដៃគូពាក់ព័ន្ធ ដូចជាអង្គការ NPA និង UNDP ហើយបានបង្កើតស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីការគ្រប់គ្រងគុណភាព និងបានធ្វើការផ្សព្វផ្សាយក្នុងគោលបំណងពង្រឹងសុវត្ថិភាព និងគុណភាពការបោសសម្អាតមីននិងស.ផ.ស.។

## ១០.២ ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិសម្រាប់សកម្មភាពមីន

ការគ្រប់គ្រងព័ត៌មានបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការរៀបចំផែនការ និងចាត់អាទិភាពការអនុវត្ត ការត្រួតពិនិត្យនិងវាយតម្លៃនិងការធ្វើរបាយការណ៍ក្នុងវិស័យសកម្មភាពមីន។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យវិស័យសកម្មភាពមីនថ្នាក់ជាតិហៅកាត់ថា IMSMA ត្រូវបានដាក់ឱ្យដំណើរការដោយអាជ្ញាធរមីន និងដោយមានការគាំទ្រថវិកានិងបច្ចេកទេសពី NPA និង UNDP។

# CURRENT DATA FLOW FOR MINE ACTION




អង្គភាពទិន្នន័យទទួលខុសត្រូវក្នុងការប្រមូល រក្សាទុក វិភាគ និងផ្សព្វផ្សាយទិន្នន័យដែលគាំទ្រដល់ការធ្វើផែនការ និងការកំណត់អាទិភាពនៃសកម្មភាពបោសសម្អាតមីន និងស.ផ.ស.ទាំងអស់នៅកម្ពុជា។

បច្ចុប្បន្ន ទិន្នន័យដែលត្រូវបានបញ្ចូលក្នុងប្រព័ន្ធ IMSMAng រួមមាន៖

| | |
|---|---|
| ១ | ទិន្នន័យស្រាវជ្រាវមូលដ្ឋាន ( Baseline Survey ) |
| ២ | ទិន្នន័យរំដោះផ្ទៃដីមីន/គ្រាប់ ( Land Release ) |
| ៣ | ទិន្នន័យគ្រោះថ្នាក់មីន/គ្រាប់ ( Mine/ERW Accident ) |
| ៤ | ទិន្នន័យជនរងគ្រោះមីន/គ្រាប់ ( Mine/ERW Victim ) |
| ៥ | ទិន្នន័យអប់រំគ្រោះថ្នាក់ដោយសារមីន/គ្រាប់ ( MRE ) |
| ៦ | ទិន្នន័យត្រួតពិនិត្យការប្រើប្រាស់ដី ក្រោយបោសសម្អាតរួច ( PCM ) |

| | |
|---|---|
| ៧ | ទិន្នន័យកំទេចគ្រាប់ (EOD) |
| ៨ | ទិន្នន័យគុណភាពនៃជីវិត (Quality of Life Survey) |
| ៩ | ទិន្នន័យតាមដាន និងសង្គ្រោះជនពិការដោយសារមីន |
| ១០ | ទិន្នន័យបញ្ជីភូមិសាស្ត្រ(Gazetteer) |
| ១១ | ទិន្នន័យការស្រាវជ្រាវគ្រាប់បែកចង្កោមពិត (CMRS) |
| ១២ | ទិន្នន័យត្រួតពិនិត្យសារមន្ទីរមីន/គ្រាប់យុទ្ធភ័ណ្ឌ (Landmines Museum Monitoring) |
| ១៣ | ទិន្នន័យតម្លៃការគ្រប់គ្រងគុណភាពជំរុំស្នាក់នៅអ្នកដោះមីន(Accommodation Quality Assessment) |
| ១៤ | ទិន្នន័យវាយតម្លៃការគ្រប់គ្រងគុណភាពកិច្ចប្រតិបត្តិការសត្វហិតមីន/គ្រាប់(Animal Detection System Quality Assurance Assessment) |
| ១៥ | ទិន្នន័យវាយតម្លៃការគ្រប់គ្រងគុណភាពលើការទុកដាក់គ្រឿងផ្ទុះ (Explosive Storage Quality Assurance Assessment) |
| ១៦ | ទិន្នន័យវាយតម្លៃការគ្រប់គ្រងគុណភាពកិច្ចប្រតិបត្តិការបោសសម្អាតមីន/គ្រាប់(Manual Clearance Quality Assurance Assessment) |
| ១៧ | ទិន្នន័យវាយតម្លៃការគ្រប់គ្រងគុណភាពកិច្ចប្រតិបត្តិការគ្រឿងចក្រ (Mechanical Clearance Quality Assurance Assessment) |
| ១៨ | ទិន្នន័យវាយតម្លៃការគ្រប់គ្រងគុណភាពការសង្គ្រោះបឋម (Medical Evacuation Quality Assurance Assessment) |
| ១៩ | ទិន្នន័យវាយតម្លៃការគ្រប់គ្រងគុណភាពលើការស្រាវជ្រាវមូលដ្ឋាន (BLS/NTS Quality Assurance Assessment) |
| ២០ | ទិន្នន័យរបាយការណ៍ត្រួតពិនិត្យគុណភាពពហុកោណថ្មី (Quality Control New BLS) |
| ២១ | ទិន្នន័យរបាយការណ៍ត្រួតពិនិត្យគុណភាព (Quality Control Sampling) |

នៅឆ្នាំ២០២០ អាជ្ញាធរមីនបានសហការជាមួយដៃគូ ធ្វើការវាយតម្លៃសមត្ថភាព ហើយបានបង្កើតផែនការសកម្មភាពអភិវឌ្ឍសមត្ថភាព ដើម្បីគ្រប់គ្រងប្រព័ន្ធព័ត៌មានឱ្យកាន់តែមានប្រសិទ្ធភាព និងនិរន្តរភាព។ ផែនការនេះ ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនហើយជាលទ្ធផលស្តង់ដារសកម្មភាពមីនកម្ពុជាស្តីពីកាគ្រប់គ្រងប្រព័ន្ធព័ត៌មានត្រូវបានបង្កើតឡើង។ ជាមួយគ្នានេះ អាជ្ញាធរមីនក៏បានកំណត់សមត្ថភាពនិងតម្រូវការធនធាន ដើម្បីធ្វើឱ្យ



*សកម្មភាពមន្ត្រីត្រួតពិនិត្យគុណភាពអាជ្ញាធរមីនកំពុងស្រង់ទិន្នន័យ ដើម្បីបញ្ជូនមកអង្គភាពទិន្នន័យ*

ប្រសើរឡើងក្នុងការគ្រប់គ្រងព័ត៌មាន ព្រមទាំងបានធ្វើការសាកល្បងនិងកែលម្អកម្មវិធីសុសវែរនិងហាដវែរកុំព្យូទ័រថ្មីៗ សម្រាប់ប្រព័ន្ធទិន្នន័យថ្នាក់ជាតិផងដែរ។

### ១០.៣ ជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពមីន

ជាការឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមមាន គោលដៅទី៥ស្តីពីសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប គោលដៅទី១០ ស្តីពីការកាត់បន្ថយវិសមភាពក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា និងគោលដៅទី១៨ ស្តីពីការបញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីននិងស.ផ.ស.និងជំរុញការសង្គ្រោះជនរងគ្រោះរាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកយុទ្ធសាស្ត្រលើកកម្ពស់សមភាពយេនឌ័រ និងការលើកកម្ពស់ឱ្យមានការចូលរួមពេញលេញពី ស្ត្រី បុរស កុមារី កុមារា និងជនមានពិការភាពជាកិច្ចការចាំបាច់ ដែលតម្រូវឱ្យឆ្លើយតបក្នុងកម្មវិធីសកម្មភាពបោសសម្អាតមីននៅ កម្ពុជា។ ការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យមីនក៏ចូលរួមចំណែកក្នុងការសម្រេចនូវលទ្ធផល ដែលបានកំណត់ក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDAF) ដែលបានចែងថា «ត្រឹមឆ្នាំ២០២៣ ប្រជាជនកម្ពុជាទាំងបុរស ស្ត្រី និងក្រុមងាយរងគ្រោះនឹងទទួលបានផលប្រយោជន៍ពីការពង្រីកឱកាស និងនវានុវត្តន៍បច្ចេកវិទ្យាសម្រាប់ការងារសមរម្យ និងចូលរួមក្នុងវិស័យសេដ្ឋកិច្ចប្រកបដោយចីរភាព»។



*ក្រុមបោសសម្អាតមីនស្ត្រី របស់ RCAF/NPMEC ក្រោមឆ័ត្រអង្គការសហប្រជាជាតិ បំពេញបេសកកម្មនៅប្រទេសលីបង់*

ដើម្បីធានាឱ្យមានការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន រាជរដ្ឋាភិបាលបានកំណត់គោលដៅ និងសូចនាករជាក់លាក់ ក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ពោលគឺក្នុងគោលដៅទី៣ នៃគោលបំណងទី៨។ អាជ្ញាធរមីនមានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលសកម្មភាពមីន និងជំរុញឱ្យប្រតិបត្តិករ ភីម៉ាក់/ម៉ាពូ និងភាគីពាក់ព័ន្ធវិស័យមីនទាំងអស់ គិតគូរអំពីសមភាពយេនឌ័រក្នុងសសរស្តម្ភសំខាន់ៗរបស់វិស័យមីន មានដូចជា ការស្រាវជ្រាវនិងបោសសម្អាតមីននិងគ្រាប់បែកចង្កោម ការងារអប់រំយល់ដឹងអំពីមីន កិច្ចសង្គ្រោះជនរងគ្រោះ និងការស្វែងរកការគាំទ្រមតិ។

ទន្ទឹមនឹងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ក្នុងឆ្នាំ២០១៨ អាជ្ញាធរមីនបានដឹកនាំសម្របសម្រួលក្នុងការរៀបចំផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន (GMAP) ២០១៨-២០២២ និងគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ដោយមានការគាំទ្របច្ចេកទេស និងថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ រួមមាន UNDP អង្គការ NPA ព្រមទាំងមានការចូលរួមពីគ្រប់

ប្រតិបត្តិករបោសម្អាតមីនជាតិ-អន្តរជាតិ ម៉ាពូ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យអនុវត្ត។ ឯកសារទាំងពីរនេះជាឯកសារតម្រង់ទិស និងជាឧបករណ៍សម្រាប់ត្រួតពិនិត្យតាមដាននិងវាយតម្លៃ ការអនុវត្តការបញ្ជ្រាបយេនឌ័ររបស់ប្រតិបត្តិករ ម៉ាពូ និងភាគីពាក់ព័ន្ធ សំដៅឆ្លើយតបទៅនឹងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ឱ្យទទួលបានជោគជ័យ ធ្វើយ៉ាងណាឱ្យការបញ្ជ្រាបយេនឌ័រក្នុងវិស័យមីននៅកម្ពុជា ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់។

បន្ថែមលើការយកចិត្តទុកដាក់ខាងលើ អាជ្ញាធរមីនបានចាត់តាំងឱ្យមានក្រុមការងារបច្ចេកទេសផ្នែកបញ្ជ្រាបយេនឌ័រក្នុងវិស័យមីន (TRG-Gender) ដែលជាយន្តការមួយដើម្បីតាមដានវឌ្ឍនភាពនិងលទ្ធផលដែលសម្រេចបាន និងបានសហការពិភាក្សាដោះស្រាយបញ្ហាប្រឈមនានា ក្នុងការងារបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីន ដែលប្រតិបត្តិករ ម៉ាពូ និងភាគីពាក់ព័ន្ធបាននិងកំពុងអនុវត្ត។ ក្រុមការងារនេះមានសមាសភាពមកពីអាជ្ញាធរមីន តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រតិបត្តិករជាតិ-អន្តរជាតិ ដែលនឹងត្រូវជួបប្រជុំគ្នាយ៉ាងហោចណាស់ ១ឆ្នាំម្តង។

តាមរយៈកិច្ចខិតខំប្រឹងប្រែងសម្រាប់វិស័យមីន ចំពោះលទ្ធផលដែលសម្រេចបានសម្រាប់រយៈពេល ៣ឆ្នាំ ចាប់ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០ ចំនួនស្ត្រីបម្រើការងារក្នុងវិស័យមីនមានការកើនឡើងប្រមាណ ១១% បើទោះបីជាមានការធ្លាក់ចុះបន្តិចបន្តួចនៅក្នុងឆ្នាំ២០១៩ យ៉ាងណាក្តី។ ជាក់ស្តែងចំនួនស្ត្រីគិតជាភាគរយនៃចំនួនបុគ្គលិកបម្រើការងារសរុបក្នុងវិស័យមីនបានកើនឡើងពី២២,៤៦%ក្នុងឆ្នាំ២០១៨ ដល់ ២៣,១៧% ក្នុងឆ្នាំ២០១៩ និងបានបន្តកើនឡើងដល់២៣,៧៥%ក្នុងឆ្នាំ២០២០។ ជាមួយគ្នានេះ ចំនួនស្ត្រីក្នុងតួនាទីជាអ្នកសម្រេចចិត្ត និងជាថ្នាក់ដឹកនាំក្នុងវិស័យមីនទាំងនៅក្នុងអាជ្ញាធរមីន ម៉ាពូ និងប្រតិបត្តិករបានកើនពី ៣១នាក់ ក្នុងឆ្នាំ២០១៨ ដល់ ៤១នាក់ ក្នុងឆ្នាំ២០២០។


*សកម្មភាពហ្វឹកហ្វឺនសុនខក្រុមបោសសម្អាតគ្រាប់បែកចង្កោមរបស់អង្គការ NPA នៅក្នុងខេត្តរតនគីរី។*

**ទិន្នន័យចំនួនបុគ្គលិកស្ត្រីបម្រើការងារនៅក្នុងវិស័យមីន**

| ឆ្នាំ | ចំនួនបុគ្គលិកស្ត្រី (នាក់) | កំណើនចំនួនបុគ្គលិកស្ត្រី (%) | ភាគរយចំនួនស្ត្រីនៃចំនួនបុគ្គលិកសរុប | ចំនួនបុគ្គលិកស្ត្រីមានតំណែងជាអ្នកដឹកនាំ (នាក់) |
|---|---|---|---|---|
| ២០១៨ | ៨៤៩ | - | ២២,៤៦ % | ៣១ |
| ២០១៩ | ៨៤៣ | ធ្លាក់ចុះ ១% | ២៣,១៧% | ៣៣ |
| ២០២០ | ៩៤២ | កើនឡើង១២% | ២៣,៧៥% | ៤១ |




ជាងនេះទៅទៀត អាជ្ញាធរមីន ម៉ាពូ ប្រតិបត្តិករជាតិ-អន្តរជាតិ និងភាគីពាក់ព័ន្ធទាំងអស់ទទួលបាននូវការបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្នុងការអនុវត្ត GMAP ក៏ដូចជាការផ្សព្វផ្សាយពង្រឹងការងារបញ្ជ្រាបយេនឌ័រទៅដល់ថ្នាក់មូលដ្ឋាន និងប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីសារៈសំខាន់និងអត្ថប្រយោជន៍នៃការចូលរួមដោយស្មើភាពគ្នារបស់ស្រ្តី បុរស កុមារី កុមារា និងជនពិការនៅក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពមីន។ ការពង្រឹងសមត្ថភាពនេះ រួមមានការបណ្តុះបណ្តាលផ្ទៃក្នុង និងការដាក់បញ្ចូលទិដ្ឋភាពយេនឌ័រ ក្នុងគោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ការបែងចែកភេទ-អាយុ និងពិការភាព (SADD) ក្នុងទម្រង់របាយការណ៍ប្រព័ន្ធទិន្នន័យថ្នាក់ជាតិចំនួន២៥ ការចុះសិក្សាស្វែងយល់ជួបផ្ទាល់ជាមួយប្រតិបត្តិករ អ្នកដោះមីនជាស្រ្តីនៅតាមទីវាល ម៉ាពូតាមបណ្តាខេត្តគោលដៅ ដើម្បីស្វែងរកចំណុចវិជ្ជមាន-អវិជ្ជមានពីការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីន និងការចូលរួមវគ្គផ្សេងៗពាក់ព័ន្ធនឹងយេនឌ័រ តាមការអញ្ជើញរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធព្រមទាំងការបញ្ជូនមន្រ្តីទៅចូលរួមវគ្គសិក្សាបង្កើនសមត្ថភាពខ្លីៗនៅក្រៅប្រទេស ក្រោមជំនួយគាំទ្រពីប្រទេសជាដៃគូ។ ជាមួយនឹងបទពិសោធន៍ដែលទទួលបានពីកិច្ចខិតខំប្រឹងប្រែង និងបរិបទល្អរបស់ប្រទេសក្នុងការអនុវត្តការងារបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីន អាជ្ញាធរមីន និងប្រតិបត្តិករជាតិបាន



*សកម្មភាពបណ្តុះបណ្តាលពង្រឹងសមត្ថភាពរបស់ក្រុមការងារយេនឌ័រអាជ្ញាធរមីន។*

ចូលរួមសិក្ខាសាលាថ្នាក់តំបន់ចំនួន០១លើកនៅប្រទេសឡាវ ដើម្បីចែករំលែកនូវបទពិសោធន៍ដល់បណ្ដាប្រទេសអាស៊ានមួយចំនួន។

ទោះបីជាមានការអនុវត្តសកម្មភាពដូចបានរៀបរាប់ខាងលើ ក៏ការងារបញ្ញាបយេនឌ័រនៅមានបញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងសមត្ថភាព និងចំណេះដឹងផ្នែកយេនឌ័រ ដែលទាមទារឱ្យមានការខិតខំប្រឹងប្រែងក្នុងការពង្រឹងឱ្យបានទូលំទូលាយ ទាំងជំនួយបច្ចេទេស និងការចូលរួមចែករំលែកបទពិសោធន៍ជាក់ស្ដែង ពីគ្រប់ភាគីពាក់ព័ន្ធ។ ជាមួយគ្នានេះ ក្រុមការងារបានរៀបចំផែនការសកម្មភាពក្នុងការអនុវត្តការងារនៅក្នុងឆ្នាំ២០២០ ព្រមទាំងបានព្យាយាមស្វែងរកដំណោះស្រាយដើម្បីពង្រឹងប្រសិទ្ធភាពការងារក៏ដូចជាខិតខំពង្រឹងសមត្ថភាពបន្ថែមតាមរយៈការចូលរួមវគ្គបណ្ដុះបណ្ដាលផ្សេងៗទាំងក្នុង និងក្រៅប្រទេស។

### ១០.៤ បញ្ជ្រាបកិច្ចការការពារបរិស្ថានក្នុងសកម្មភាពមីន

កិច្ចការពារបរិស្ថាន គឺជាការងារដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ពីគ្រប់វិស័យ។ អាជ្ញាធរមីនបានសហការជាមួយប្រតិបត្តិករ ក្រសួងបរិស្ថាន និងដៃគូផ្សេងទៀតដូចជាអង្គការ NPA និង UNDP ដើម្បីរៀបចំស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជាស្តីពី "ការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន" ដោយផ្អែកលើស្តង់ដារសកម្មភាពកំចាត់មីនអន្តរជាតិស្តីពីបរិស្ថាន។ ក្នុងដំណើរការរៀបចំស្តង់ដារនេះ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយប្រតិបត្តិករ និងភាគីពាក់ព័ន្ធ ចំនួន ២លើក ត្រូវបានរៀបចំឡើង ដើម្បីពិនិត្យលើខ្លឹមសារបច្ចេកទេសនៃសេចក្ដីព្រាងស្តង់ដារ។ ជារួមការរៀបចំស្តង់ដារនេះមិនទាន់បញ្ចប់រួចរាល់នៅឡើយ ដែលទាមទារឱ្យមានការពិភាក្សាបន្ថែមទៀត។

### ១០.៥ ប្រព័ន្ធត្រួតពិនិត្យការអនុវត្តសកម្មភាពមីន(PMS)

ប្រព័ន្ធត្រួតពិនិត្យការអនុវត្តសកម្មភាពមីន មិនទាន់ត្រូវបានបង្កើតគ្រប់ជ្រុងជ្រោយនៅឡើយ ជាក់ស្តែង អាជ្ញាធរមីនចាំបាច់ត្រូវពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូលសម្រាប់បង្កើតប្រព័ន្ធត្រួតពិនិត្យ និងត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្កើតទម្រង់ប្រមូលទិន្នន័យ ការបង្កើនសមត្ថភាពក្នុងការអនុវត្ត និងការរៀបចំវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីម៉ាពូ និងភាគីពាក់ព័ន្ធអំពីវិធីសាស្ត្រប្រមូលទិន្នន័យ ដើម្បីឈានទៅដាក់ឱ្យប្រើប្រាស់សាកល្បងប្រព័ន្ធត្រួតពិនិត្យនេះ។



*អង្គភាពទិន្នន័យអាជ្ញាធរមីនផ្តល់វគ្គបណ្តុះបណ្តាលដល់អង្គភាពផែនការសកម្មភាពមីន២៥រាជធានី-ខេត្ត*

# ជំពូកទី១១

# បញ្ហាប្រឈម និងតម្រូវការ

រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានទទួលស្គាល់វឌ្ឍនភាពនៃវិស័យសកម្មភាពមីនដែលសម្រេចបានកន្លងមក ក្នុងការដោះស្រាយបញ្ហាមីន និងស.ផ.ស. ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ប៉ុន្តែដោយវិសាលភាពនៃការគំរាមកំហែងដោយសារមីន និងស.ផ.ស. នៅមានទំហំធំ ហើយនៅតែជាឧបសគ្គចម្បងដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ចំណែកធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រសកម្មភាពមីន នៅមានការកម្រិត ដូច្នេះសកម្មភាពមួយចំនួនក្នុងផែនការ មិនទាន់អាចសម្រេចបាននៅឡើយ និងទាមទារឱ្យបន្តដោះស្រាយក្នុងផែនការបន្ទាប់។

## ១១.១ ការគាំទ្រខាងផ្នែកសម្ភារដល់កងទ័ពជើងគោក និងបោសសម្អាតមីនតាមព្រំដែន

ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្មអន្តរជាតិ កម្ពុជាបានបង្កើតតំបន់សេដ្ឋកិច្ចពិសេសមួយចំនួននៅតាមតំបន់បណ្តោយព្រំដែនជាមួយប្រទេសជិតខាង ដែលនាំឱ្យមានកំណើនប្រជាជន និងការពង្រីកសហគមន៍នៅក្នុងតំបន់នោះ។ ដោយហេតុថា តំបន់ដែលមានមីនភាគច្រើនស្ថិតនៅតាមបណ្តោយព្រំដែនភាគពាយ័ព្យ គួបផ្សំនឹងកំណើនប្រជាជន និងសកម្មភាពអភិវឌ្ឍន៍ នាំឱ្យមានហានិភ័យខ្ពស់ នៅក្នុងតំបន់នោះ ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ អាជ្ញាធរមីននឹងបន្តស្វែងរកជំនួយ ដើម្បីបំពាក់សម្ភារ និងផ្តល់ការហ្វឹកហ្វឺនដល់កងយោធពលខេមរភូមិន្ទចំនួន ២.០០០នាក់ ឱ្យចូលរួមបោសសម្អាតមីនតាមតំបន់ព្រំដែន។ ក្នុងរយៈពេល០៣ឆ្នាំ ២០១៨-២០២០ កងយោធពលខេមរភូមិន្ទចំនួនប្រមាណ៥០០នាក់ បានទទួលការហ្វឹកហ្វឺនពីមជ្ឈមណ្ឌល CMAC ដែលនេះជាវឌ្ឍនភាពមួយគួរឱ្យកត់សម្គាល់ ប៉ុន្តែការងារនេះមិនទាន់សម្រេចបានទៅតាមផែនការនៅឡើយ។

## ១១.២ ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងអាជ្ញាធរមីន និងក្រសួងពាក់ព័ន្ធ

អាជ្ញាធរមីននឹងជួបជាលក្ខណៈទ្វេភាគី ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងបរិស្ថាន ដើម្បីពិភាក្សាពីការបោសសម្អាតចម្ការមីន និងស.ផ.ស. នៅក្នុងតំបន់ដែលគ្រប់គ្រងដោយបណ្តាក្រសួងទាំងនោះ ក្នុងគោលបំណងប្រែក្លាយកម្ពុជាជាប្រទេសដែលគ្មានមីនត្រឹមឆ្នាំ២០២៥។

## ១១.៣ ការកៀរគរនិងតម្រូវការធនធាន

ដើម្បីសម្រេចបានតាមគោលបំណងកម្ពុជាគ្មានមីនត្រឹមឆ្នាំ២០២៥ វិស័យមីនកម្ពុជាត្រូវការថវិកាប្រមាណ ៥២លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ប៉ុន្តែជាក់ស្តែងពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ វិស័យនេះ

ទទួលបានថវិកាប្រមាណ ៣០លានដុល្លារអាមេរិក តែប៉ុណ្ណោះក្នុងមួយឆ្នាំ ឬប្រមាណ៦០% នៃតម្រូវការថវិកាប្រចាំឆ្នាំ។ ដើម្បីសម្រេចនូវគោលបំណងត្រឹមឆ្នាំ២០២៥ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ វិស័យមីនត្រូវការថវិកាចំនួន**៦៦,៦៥លានដុល្លារអាមេរិក** ក្នុងមួយឆ្នាំៗ ដែលក្នុងនោះ **៤៥លានដុល្លារអាមេរិក** ដើម្បីរំដោះផ្ទៃដីដែលមានមីន **១៥លានដុល្លារអាមេរិក** សម្រាប់រំដោះផ្ទៃដីដែលមានគ្រាប់បែកចង្កោម និង 0,**៦៥លានដុល្លារអាមេរិក** សម្រាប់ដោះស្រាយបញ្ហាស.ផ.ស.ផ្សេងទៀត និង **៦លានដុល្លារអាមេរិក** សម្រាប់កិច្ចការគ្រប់គ្រង សម្របសម្រួលនិងត្រួតពិនិត្យទូទាំងវិស័យ។

ហេតុនេះ អាជ្ញាធរមីននឹងបង្កើនកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដែលមានស្រាប់ដៃគូអភិវឌ្ឍន៍ថ្មីៗ វិស័យឯកជន និងសមាគមន៍នានា ដើម្បីកៀរគរធនធានតាមផែនការពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។ ជាមួយគ្នានេះ យើងនឹងបន្តពិភាក្សាជំរុញការបន្ថែមថវិកាចូលរួមរបស់រាជ-រដ្ឋាភិបាលទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។

# ជំពូកទី១២

# សេចក្តីសន្និដ្ឋាន

សមិទ្ធផលដែលសម្រេចបានពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ គឺជាផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា សហគមន៍អន្តរជាតិ គំនិតច្នៃប្រឌិតបច្ចេកទេសរបស់ប្រតិបត្តិករជាតិនិងអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត។ ទោះជាវិស័យមីនទទួលបានលទ្ធផលដ៏ធំធេងកន្លងមកយ៉ាងណាក្តី ក៏មីន និងស.ផ.ស.នៅតែជាឧបសគ្គចម្បងចំពោះការអភិវឌ្ឍនៅកម្ពុជា។ រាជរដ្ឋាភិបាលមានបំណងប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០។ ហេតុនេះ រាជរដ្ឋាភិបាលនឹងបង្កើនកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាមីននិងស.ផ.ស. ព្រោះថាបញ្ហាមីន និងស.ផ.ស. មានទំនាក់ទំនងយ៉ាងជិតស្និតនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនៅកម្ពុជា។

ភាពមិនប្រាកដប្រជាបច្ចុប្បន្នដែលបណ្តាលមកពីជំងឺរាតត្បាតកូវីត-១៩ បញ្ហាសេដ្ឋកិច្ច និងនយោបាយសកលបានជះឥទ្ធិពលជាអវិជ្ជមានដល់ការផ្តល់ថវិកាពីអន្តរជាតិដល់វិស័យមីននៅកម្ពុជា។ ស្ថិតក្នុងស្ថានភាពបែបនេះ កម្ពុជាចាំបាច់ត្រូវមានវិធានការជាក់លាក់និងមានប្រសិទ្ធភាព ដើម្បីកៀរគរធនធានពីគ្រប់មជ្ឈដ្ឋានទាំងដៃគូអភិវឌ្ឍន៍ដែលមានស្រាប់ ដៃគូអភិវឌ្ឍន៍ថ្មីៗ និងវិស័យឯកជន។

រាជរដ្ឋាភិបាលប្តេជ្ញាបន្តប្រែក្លាយកម្ពុជា ឱ្យក្លាយជាប្រទេសគ្មានមីននៅត្រឹមឆ្នាំ២០២៥ និងលើកទឹកចិត្តឱ្យសហគមន៍អន្តរជាតិបន្តគាំទ្រធនធាន ទាំងធនធានបច្ចេកទេស ធនធានមនុស្ស សម្ភារបរិក្ខារ និងថវិកា ដើម្បីគាំទ្រផែនការបោសសំអាតមីននិងគ្រាប់បែកចង្កោម ការកំទេចស.ផ.ស. ការអប់រំយល់ដឹងអំពីមីន ការជួយគាំទ្រដល់ជនរងគ្រោះ និងការបញ្ជូនកម្លាំងកងយោធពលខេមរភូមិន្ទចូលរួមបោសសម្អាតមីនមនុស្សធម៌ ដើម្បីកម្ពុជាអាចសម្រេចបាននូវគោលបំណងដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន។

**ឧបសម្ព័ន្ធ ក**

## ស្តង់ដាចាត់ថ្នាក់ប្រភេទដី

| ចំណាត់ថ្នាក់ | ចំណាត់ថ្នាក់បន្ទាប់ | | សេចក្តីលំអិត អំពី ចំណាត់ថ្នាក់បន្ទាប់ | កំណត់សំគាល់ |
|---|---|---|---|---|
| **A (តំបន់មានមីន)** ដីមានភស្តុតាងថាមានមីន | A1 | ដីមានដង់ស៊ីតេមីនប្រឆាំងមនុស្សច្រើន | ដីមានដាក់មីន ជាលក្ខណៈយុទ្ធសាស្ត្រ ដាក់ការពារដោយមានទ្រង់ទ្រាយច្បាស់លាស់ ដូចជាខ្សែក្រវ៉ាត់មីន តាមបណ្តោយផ្លូវ តាមព្រំដែន តាមមូលដ្ឋានទ័ព និង តាមហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | ការពង្រាយកំលាំងបោសសំអាតមីន មនុស្សធម៌ គួរផ្តោត លើដី A1-A3 ដើម្បីឆ្លើយតបនឹងអាទិភាពរបស់សហគមន៍ ។ គ្រប់ពហុកោណគួរធ្វើការអង្កេតបន្ថែមដើម្បីបាន ដឹងបរិវេណដីមានមីន មុនពេលពង្រាយកំលាំង ដោះមីន ។ ការពង្រាយកំលាំង ដោះមីនលើដី A4 គួរកំរិត ចំពោះដី ដែលមានការកំណត់ជាក់លាក់ សំរាប់កិច្ចអភិវឌ្ឍន៍ |
| | A2 | ដីមានមីនប្រឆាំងមនុស្សនិងមីនប្រឆាំងរថក្រោះដាក់លាយចំរុះគ្នា | | |
| | A2.1 | ដីមានដង់ស៊ីតេមីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះ ដាក់លាយចំរុះគ្នាច្រើន | | |
| | A2.2 | ដីមានមីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះ នៅរាយប៉ាយ | ដីមិនបានប្រើប្រាស់បង្ករបង្កើនផល ដោយមានមីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះតិចតួច ហើយយើងមិនអាចកំណត់ទីកន្លែងដាក់មីនបាន | |
| | A3 | ដីមានមីនប្រឆាំងរថក្រោះ | ដងផ្លូវកំពុងប្រើប្រាស់ ឬ បោះបង់ចោល ដែលមានមីនប្រឆាំងរថក្រោះ | |
| | A4 | ដីមានមីនប្រឆាំងមនុស្ស នៅរាយប៉ាយ ដែលមិនអាចកំណត់ ទីតាំងមីនបាន | ដីមិនបានប្រើប្រាស់បង្ករបង្កើនផល ដោយមានមីនប្រឆាំងមនុស្សតិចតួច ហើយយើងមិនអាចកំណត់ ទីកន្លែងដាក់មីនបាន | |
| **B (ដីមាននៅសល់ការគំរាមកំហែងតិចតួច)** ដីមានភស្តុតាងបញ្ជាក់ថា មានគ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម ឬមិនអាចកំណត់បានថាមានមីន | B1 | ដីមានគ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) (តែពុំមានមីន) | តំបន់អតីតសមរភូមិដែលមាន គ្រាប់សំណល់ជាតិផ្ទុះពីសង្គ្រាម ។ តំបន់ប្រភេទនេះមានលក្ខណៈសមស្របសំរាប់ការបោសសំអាតគ្រាប់ (Battle Area Clearance) | តំបន់អតីតសមរភូមិដែលមានគ្រាប់ សំណល់ជាតិផ្ទុះពីសង្គ្រាម ។ តំបន់ប្រភេទនេះមានលក្ខណៈសមស្រប សំរាប់ការបោសសំអាតគ្រាប់ (Battle Area Clearance)<br><br>ការពង្រាយកំលាំងបោសសំអាតមីន លើដីប្រភេទ B ធ្វើតែចំពោះដីដែល ឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ប៉ុណ្ណោះ |
| | B1.1 | ដីមានគ្រាប់ទំលាក់ពីយន្តហោះ | មានទិន្នន័យគ្រាប់ដែលបានទំលាក់ ឬមានភស្តុតាងគ្រាប់ទំលាក់ពីយន្តហោះ | |
| | B1.2 | ដីមានគ្រាប់ចង្កោម | មានទិន្នន័យពីការទំលាក់គ្រាប់ ឬមានភស្តុតាងថាតំបន់មួយមានគ្រាប់ចង្កោម | |
| | B1.3 | តំបន់ទីតាំងសមរភូមិ | តំបន់ទាំងឡាយដែលមានភស្តុតាងបញ្ជាក់ថាធ្លាប់មានការប្រយុទ្ធ | |
| | B1.4 | ដីដែលមានគំនរគ្រាប់/គ្រាប់កប់ | តំបន់ទាំងឡាយដែលនៅមានគ្រាប់កប់ ឬមានគំនរគ្រាប់ | |
| | B1.5 | ទីតាំងយោធាដែលបានបោះបង់ | តំបន់ទាំងឡាយដែលអាចមានការសង្ស័យកំរិតខ្ពស់ថាមានគ្រាប់រំសេវ | |
| | B2 | ដីមិនអាចកំណត់បានថា មានការគំរាមកំហែងដោយសារមីន | ដីធ្លាប់សង្ស័យថាមានមីន តែត្រូវបានប្រជាពលរដ្ឋទន្ទ្រានយកមកប្រើប្រាស់ ។ ប្រសិនបើពុំមានគ្រោះថ្នាក់ ឬ ពុំជួបប្រទះឃើញមីនរយៈពេល ៣ឆ្នាំ ដីប្រភេទនេះត្រូវចាត់ថ្នាក់ ជាដីប្រភេទ C1 | |
| **C (ដីបញ្ចប់ការគំរាមកំហែង)** ដីពុំមានភស្តុតាងបញ្ជាក់ថា មានការគំរាមកំហែង | C1 | ដីត្រូវបានទន្ទ្រានយកមក ប្រើប្រាស់ | ដីធ្លាប់សង្ស័យថាមានមីនតែត្រូវបានប្រជាពលរដ្ឋទន្ទ្រានយកមកប្រើប្រាស់ដោយពុំមានគ្រោះថ្នាក់ ឬពុំមានប្រទះឃើញមីនរយៈពេល៣ឆ្នាំ ដូចមានចែងក្នុងនយោបាយកាត់បន្ថយផ្ទៃដីចំការមីន | មិនគួរពង្រាយកំលាំងបោសសំអាតមីនមនុស្សធម៌ លើដីប្រភេទនេះទេ |
| | C2 | ដីត្រូវបានកាត់បន្ថយ ដោយការស្រាវជ្រាវមូលដ្ឋាន ឬការស្រាវជ្រាវបច្ចេកទេស | ដីមានមីន ឬ ធ្លាប់សង្ស័យថាមានមីនតែត្រូវបានឆែកមើលតាមវិធីស្រាវជ្រាវណាមួយ ដែលបញ្ជាក់ថា ពុំមានភស្តុតាង ថានៅមានសេសសល់ការគំរាមកំហែងទៀត | |
| | C3 | ដីបានបោសសំអាតមីនរួច | ដីបានបោសសំអាតមីនរួច ដោយប្រតិបត្តិករដែលទទួលបានអាជ្ញាប័ណ្ណ ពីអាជ្ញាធរមីន ហើយបានអនុវត្តន៍តាមស្តង់ដាជាតិបោសសំអាតមីន (CMAS) | |
| | C4 | ដីពុំមានមីន | ដីពុំមានការបញ្ជាក់ពីប្រជាពលរដ្ឋមូលដ្ឋាន ឬ ការស្រាវជ្រាវណាមួយថាមានមីនគំរាមកំហែងទេ | |

# ឧបសម្ព័ន្ធ ខ៖ សមិទ្ធផលនៃការអនុវត្តផែនការសកម្មភាព ៣ឆ្នាំ (២០១៨-២០២០)

| សកម្មភាព | | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | ហានិភ័យ/ការសន្មត | ផែនការ និងលទ្ធផល | សរុប | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|
| គោលបំណងទី១ | រំដោះតំបន់ដែលដឹងថាមានមីនទាំងអស់ នៅត្រឹមឆ្នាំ២០២៥ | | | | | | | | |
| គោលដៅទី១ | បញ្ចប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានថ្នាក់ជាតិនៅតាមស្រុកដែលនៅសល់ត្រឹមឆ្នាំ២០២០ | | | • កង្វះការចូលរួមរបស់ភាគីពាក់ព័ន្ធ<br>• តំបន់រងគ្រោះមួយចំនួន មិនអាចចូលទៅបាន<br>• អ្នកផ្តល់ព័ត៌មានមិនវត្តមាន<br>• ការបញ្ជូនទិន្នន័យពីប្រតិបត្តិករមានការយឺតយ៉ាវ<br>• មានទិន្នន័យអំពីស្រុកទាំង | | | | | |
| យុទ្ធសាស្ត្រទី១ | រៀបចំផែនការសម្រាប់ស្រាវជ្រាវចម្ការមីនមូលដ្ឋានលើស្រុកនៅសល់ ដែលមាន មីន និងស.ផ.ស. | | | | | | | | |
| សកម្មភាពទី១ | បង្កើតតារាងចំនួនស្រុកដែលនៅសល់សម្រាប់ធ្វើការស្រាវជ្រាវចម្ការមីនមូលដ្ឋាន | តារាងចំនួនស្រុកដែលនៅសល់ សម្រាប់ធ្វើកាស្រាវជ្រាវចម្ការមីនមូលដ្ឋាន | តារាងព័ត៌មានអំពីភូមិ/ឃុំ/សម្រាប់ការស្រាវជ្រាវចម្ការមីនមូលដ្ឋានដែលបានទទួលការអនុម័ត | | ទិសដៅ | ១ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ច្បាប់ | ១ | | |
| សកម្មភាពទី២ | បង្កើតផែនការសកម្មភាព ស្រាវជ្រាវចម្ការមីនមូលដ្ឋាន | ផែនការសកម្មភាពសម្រាប់ធ្វើការស្រាវជ្រាវមូលដ្ឋាន | ផែនការសកម្មភាពការងារស្រាវជ្រាវចម្ការមីនមូលដ្ឋានដែលបានអនុម័ត | | ទិសដៅ | ១ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ច្បាប់ | ១ | | |
| យុទ្ធសាស្ត្រទី២ | កៀរគរធនធានសម្រាប់គាំទ្រការស្រាវជ្រាវចម្ការមីនមូលដ្ឋាន | | | | | | | | |
| សកម្មភាពទី១ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។ | ចំនួនកិច្ចប្រជុំពិគ្រោះយោបល់ | លិខិតអញ្ជើញ និងបញ្ជីសមាសភពចូលរួម | | ទិសដៅ | ៦ដង | ២ | ២ | ២ |
| | | | | | លទ្ធផល | ៥ដង | ១ | ២ | ២ |
| សកម្មភាពទី២ | រៀបចំយុទ្ធសាស្ត្រកៀរគរធនធានសម្រាប់ធ្វើការស្រាវជ្រាវចម្ការមីនមូលដ្ឋាន | យុទ្ធសាស្ត្រកៀរគរធនធានត្រូវបានបង្កើត | យុទ្ធសាស្ត្រកៀរគរធនធានដែលត្រូវបានអនុម័ត ផ្នែកមួយនៃផែនការយុទ្ធសាស្ត្រកៀគធនធានរួមក្នុងវិស័យសកម្មភាពមីន | | ទិសដៅ | ១ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ច្បាប់ | ០ | ១ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សកម្មភាពទី៣ | ធ្វើសកម្មភាពកៀរគរធនធានសម្រាប់ធ្វើការស្រាវជ្រាវចម្ការមីនមូលដ្ឋាន | ថវិកាសម្រាប់ធ្វើការស្រាវជ្រាវចម្ការមីនមូលដ្ឋានដែលកៀរគរបាន | អនុស្សរណៈយោគយល់ឬកិច្ចសន្យា | នោះអាចរៀបជាតារាងបាន<br>• សមត្ថភាពគ្រប់គ្រាន់របស់ ប្រព័ន្ធពត៌មាន (IMSMA) | ទិសដៅ | ៦០០.០០០ ដុល្លារ | ៤០០.០០០ ដុល្លារ | ២០០.០០០ ដុល្លារ | |
| | | | | | លទ្ធផល | ១.២៧៨.២៦៨ ដុល្លារ | ៣១៤.៨១៩ | ៤៩៦.៥០៤ | ៤៦៦.៩៤៥ |
| យុទ្ធសាស្ត្រទី៣ | ធ្វើការស្រាវជ្រាវចំម្ការមីនមូលដ្ឋាន នៅគ្រប់ស្រុកទាំងអស់ ដែលនៅសល់ត្រឹមឆ្នាំ ២០២០ | | | | | | | | |
| សកម្មភាពទី១ | អនុវត្តសកម្មភាពស្រាវជ្រាវចម្ការមីនមូលដ្ឋាន | ទិន្នន័យអំពីការស្រាវជ្រាវចម្ការមីនមូលដ្ឋាន | • របាយការណ៍ស្រាវជ្រាវចម្ការមីនមូលដ្ឋាន<br>• ទម្រង់វាយតម្លៃគុណភាពការស្រាវជ្រាវចម្ការមីនមូលដ្ឋាន និងការស្រាវជ្រាវមិនបច្ចេកទេស | | ទិសដៅ | ៣៦ស្រុក | ២៤ ស្រុក | ១២ ស្រុក | |
| | | | | | លទ្ធផល | ៧៣ស្រុក | ១២ | ៤៦ | ១៥ |
| គោលដៅទី២ | អនុវត្តការរំដោះផ្ទៃដី តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស លើដីត្រូវបានទន្ទ្រាន យកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងធ្វើការស្រាវជ្រាវឡើងវិញ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យដីដែលមានមីន | | | • ធនធានមិនគ្រប់គ្រាន់ក្នុងការរៀបចំឯកសារទស្សនាទាន និងការសិក្សាករណី<br>• ទស្សនាទានអំពីការស្រាវជ្រាវមិនបច្ចេក ទេសនិងលុបចោល តំបន់សង្ស័យមិនទាន់ត្រូវបានអនុវត្តន៍ទំលំ ទូលាយក្នុង | | | | | |
| យុទ្ធសាស្ត្រទី១ | រៀបចំឯកសារទស្សនទាន និងការសិក្សាវិភាគករណីស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្ទ្រានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | | | | | | | | |
| សកម្មភាពទី១ | ប្រមូល និងផ្ទៀងផ្ទាត់ទិន្នន័យសម្រាប់វិភាគ | ទិន្នន័យត្រូវបានប្រមូល | របាយការណ៍ទិន្នន័យ | | ទិសដៅ | ៣ច្បាប់ | ១ | ១ | ១ |
| | | | | | លទ្ធផល | ៣ច្បាប់ | ១ | ១ | ១ |
| សកម្មភាពទី២ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយប្រតិបត្តិករ ដើម្បីចែករំលែកបទពិសោធន៍ និងប្រមូលធាតុចូល | ចំនួនកិច្ចប្រជុំ | របាយការណ៍កិច្ចប្រជុំ និងបញ្ជីសមាសភាពអ្នកចូលរួម | | ទិសដៅ | ៩ ដង | ៣ | ៣ | ៣ |
| | | | | | លទ្ធផល | ៤ ដង | ១ | ១ | ២ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សកម្មភាពទី៣ | រៀបចំឯកសារទស្សនាទាន និងការសិក្សាវិភាគករណីស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងការលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | ឯកសារទស្សនាទានស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងការលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញបានរៀបចំ<br>• ចំនួនករណីសិក្សាស្តីពីស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និង និងការស្រាវជ្រាវឡើងវិញដែលត្រូវបានអនុវត្ត | ឯកសារទស្សនាទានស្តីពីរស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងការលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញដែលបានអនុម័ត | ចំណោមប្រតិបត្តិករ<br>• មន្ត្រីដែលបានបណ្តុះបណ្តាលរួចជាកចេញទៅរកការងារផ្សេង<br>• គំរូអំពីការស្រាវជ្រាវមិនបច្ចេកទេសនិងលុបចោលតំបន់សង្ស័យមានមីនសមស្របអាចអនុវត្តន៍បានទូទាំងប្រទេស<br>• មានការគាំទ្រគំរូនេះពីភាគីពាក់ពន្ធ័នានា | ទិសដៅ | ១ ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ ច្បាប់ | ១ | | |
| យុទ្ធសាស្ត្រទី២ | **លើកកម្ពស់និងពង្រីកការអនុវត្តគំនិតផ្តួចផ្តើមស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ** | | | | | | | | |
| សកម្មភាពទី១ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ ស្តីពីការអនុវត្តលើការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងការលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | ចំនួនសិក្ខាសាលា | របាយការណ៍សិក្ខាសាលា | | ទិសដៅ | ៣ ដង | ១ | ១ | ១ |
| | | | | | លទ្ធផល | ៣ ដង | ១ | ១ | ១ |
| សកម្មភាពទី២ | រៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការស្រាវជ្រាវ | ចំនួនសិក្ខាសាលា | របាយការណ៍សិក្ខាសាលា | | ទិសដៅ | ៣ ដង | ១ | ១ | ១ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | មិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងការលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | | | | លទ្ធផល | ៣ ដង | ១ | ១ | ១ |
| **យុទ្ធសាស្ត្រទី៣** | **ពង្រឹងសមត្ថភាពក្នុងការអនុវត្តការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ** | | | | | | | | |
| សកម្មភាពទី១ | គៀរគរធនធានសម្រាប់ពង្រឹកសមត្ថភាពនៃអនុវត្តការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងការលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | មានធនធានសម្រាប់ពង្រឹកការងារអនុវត្តការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងការលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | • ផែនការសកម្មភាពនិងថវិកាត្រូវបានអនុវត្ត<br>• អនុសាធារណៈយោគយល់ និងកិច្ចសន្យា | | ទិសដៅ | ១.៦ លានដុល្លារ | ០.៥ លានដុល្លារ | ០.៥ លានដុល្លារ | ០.៦ លានដុល្លារ |
| | | | | | លទ្ធផល | ១.៣៣៨.១៧៣ ដុល្លារ | ៤០៥.១៦៧ | ៤៧៨.២០១ | ៤៥៤.៨០៥ |
| សកម្មភាពទី២ | អនុវត្តការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងការលុបចោលតំបន់សង្ស័យ និងការស្រាវជ្រាវឡើងវិញ | ចំនួនពហុកោណចម្ការមីនដែលបានចុះពិនិត្យឡើងវិញ | របាយការណ៍ស្តីពីការស្រាវជ្រាវមិនបច្ចេកទេសលើដីត្រូវបានទន្រ្ទានយកមកប្រើប្រាស់ និងការលុបចោលតំបន់សង្ស័យ និងកាពិនិត្យឡើងវិញ | | ទិសដៅ | ១២.០០០ ពហុកោណ | ៣.៧៥០ | ៣.៧៥០ | ៤.៥០០ |
| | | | | | លទ្ធផល | ៣.៥៥៨ ពហុកោណ | ២.៥៨២ | ៧៥០ | ៦៨១ |
| **គោលដៅទី៣** | **រំដោះភូមិអាទិភាពដែលដឹងថាមានមីន នៅត្រឹមឆ្នាំ២០២១ និងភូមិដែលនៅសល់នៅត្រឹមឆ្នាំ២០២៥** | | | • កង្វះការចូលរួមពេញលេញរបស់ភាគីពាក់ព័ន្ធ | | | | | |
| **យុទ្ធសាស្ត្រទី១** | **កសាងផែនការប្រតិបត្តិការរយៈពេល០៣ឆ្នាំ ដោយមានការពិនិត្យប្រចាំឆ្នាំ ដោយផ្អែកលើដំណើរការការចាត់អាទិភាព** | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សកម្មភាពទី១ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ដើម្បីរៀបចំផែនការសកម្មភាពវិស័យមីនរយៈពេល០៣ឆ្នាំ | ចំនួនកិច្ចប្រជុំពិគ្រោះយោបល់ | • បញ្ជីសមាសភាពអ្នកចូលរួម<br>• របាយការណ៍ប្រជុំ | •ធនធានសម្រាប់ការងារដោះមីនមិនគ្រប់គ្រាន់<br>•តំបន់មានមីនមួយចំនួនមិនអាចចូលទៅដល់បាន<br>•គោលការណ៍រៀបចំផែនការ និងចាត់អាទិភាពបានកែសម្រួលរួច<br>•ឧបករណ៍ដោះមីនមានគ្រប់គ្រាន់<br>•ប្រតិបត្តិករប្រតិបត្តិតាម ស្តង់ដាសកម្មភាពមីនកម្ពុជា | ទិសដៅ | ២ ដង | ២ | | |
| | | | | | លទ្ធផល | ៣ ដង | ១ | ១ | ១ |
| សកម្មភាពទី២ | រៀបចំផែនការសកម្មភាពរយៈពេល៣ឆ្នាំ | ផែនការសកម្មភាពរយៈពេល ៣ឆ្នាំ ត្រូវបានបង្កើត | ផែនការសកម្មភាពរយៈពេល០៣ឆ្នាំ ត្រូវបានអនុម័ត | | ទិសដៅ | ១ ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ ច្បាប់ | ១ | | |
| សកម្មភាពទី៣ | ពិនិត្យការអនុវត្តការងារប្រចាំឆ្នាំ | ចំនួនការពិនិត្យប្រចាំឆ្នាំ | ចំនួនរបាយការណ៍ | | ទិសដៅ | ៣ ច្បាប់ | ១ | ១ | ១ |
| | | | | | លទ្ធផល | ៣ ច្បាប់ | ១ | ១ | ១ |
| **យុទ្ធសាស្ត្រទី២** | **ដាក់ពង្រាយធនធានបោសសម្អាតមីននៅតាមភូមិអាទិភាព ដោយគិតគូរអំពីអាទិភាពរបស់មូលដ្ឋាន ត្រឹមឆ្នាំ២០២១ និងភូមិដែលមានមីន នៅសល់ទាំងអស់ត្រឹមឆ្នាំ២០២៥** | | | | [redacted] | | | | |
| សកម្មភាពទី១ | ចាត់អាទិភាពភូមិដែលមានមីន សម្រាប់ពង្រាយកម្លាំង និងធនធានសម្រាប់ការបោសសម្អាតមីន | រៀបចំបញ្ជីឈ្មោះភូមិអាទិភាព | អនុម័តបញ្ជីឈ្មោះភូមិអាទិភាព | | ទិសដៅ | ១ ច្បាប់ | ១ | ១ | ១ |
| | | | | | លទ្ធផល | ១ ច្បាប់ | ១ | ១ | ១ |
| សកម្មភាពទី២ | កៀរគរធនធានសម្រាប់ការបោសសម្អាតមីន | ធនធានបោសសម្អាតមីនត្រូវបានរៀបចំ | អនុស្សារណៈយោគយល់ និងកិច្ចសន្យា | | ទិសដៅ | ៧២,៧៥ លានដុល្លារ | ២៤,២៥ | ២៤,២៥ | ២៤,២៥ |
| | | | | | លទ្ធផល | ៥៥,៤១ លានដុល្លារ | ១៨,៥០ | ១៧,០០ | ២០,០០ |
| សកម្មភាពទី៣ | ពង្រាយកម្លាំង និងធនធានសម្រាប់ការបោសសម្អាតមីន លើភូមិអាទិភាពដែលមានមីន | ទំហំផ្ទៃដីដែលបានបោសសម្អាត | របាយការណ៍ទំហំផ្ទៃដីដែលបាន បោសសម្អាត | | ទិសដៅ | ៣២៨,៨០គម២ | ១០៩,៦០ | ១០៩,៦០ | ១០៩,៦០ |
| | | | | | លទ្ធផល | ២៨០,៣៥គម២ | ៩៤,២០ | ៩១,៣៧ | ៩៤,៧៩ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| យុទ្ធសាស្ត្រទី៣ | ពង្រឹងការអនុលោមតាមប្រព័ន្ធគ្រប់គ្រងគុណភាពនៅក្នុងសកម្មភាពបោសសម្អាតមីន | | | | [redacted] | | | | |
| សកម្មភាពទី១ | បន្តអនុវត្តការត្រួតពិនិត្យគុណភាពដើម្បីធានាអនុលោមភាពប្រព័ន្ធគ្រប់គ្រងគុណភាពនៅក្នុងសកម្មភាពបោសសម្អាតមីន | ចំនួនដងការត្រួតពិនិត្យ | • របាយការណ៍ត្រួតពិនិត្យគុណភាព (QA/QC ) • របាយការណ៍គ្រោះថ្នាក់ | | ទិសដៅ | ៣.៩០០ដង | ១.៣០០ | ១.៣០០ | ១.៣០០ |
| | | | | | លទ្ធផល | ៤.៨៨៨ ដង | ១.៣៩៩ | ១.៦៨២ | ១.៨០៧ |
| គោលដៅទី៤ | ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធប្រតិបត្តិការ និងសមត្ថភាពដែលមានស្រាប់ | | | • ការអនុវត្តគោលការណ៍រៀបចំផែនការនិងចាត់អាទិភាពរបស់ម៉ាពូ មិនទាន់មានសង្គត់ភាព • កង្វះធនធានក្នុងការអនុវត្តបច្ចេកវិជ្ជាថ្មី • យន្តការម៉ាពូមានស្រាប់ • គោលការណ៍រៀបចំផែនការនិង | [redacted] | | | | |
| យុទ្ធសាស្ត្រទី១ | ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធធ្វើផែនការ និងចាត់អាទិភាព | | | | | | | | |
| សកម្មភាពទី១ | ពិនិត្យឡើងវិញគោលការណ៍ណែនាំស្តីពីការរៀបចំផែនការ និងចាត់អាទិភាព | គោលការណ៍ណែនាំស្តីពីការរៀបចំផែនការ និងចាត់អាទិភាពដែលបានកែសម្រួល | គោលការណ៍ណែនាំស្តីពីការរៀបចំផែនការនិងចាត់អាទិភាពដែលបានអនុម័ត | | ទិសដៅ | ១ ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ ច្បាប់ | ១ | | |
| សកម្មភាពទី២ | រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីម៉ាពូ និងប្រតិបត្តិករស្តីពីការកែសម្រួលគោលការណ៍ណែនាំស្តីពីការរៀបចំផែនការ និងចាត់អាទិភាព | ចំនួនវគ្គបណ្តុះបណ្តាល | របាយការណ៍វគ្គបណ្តុះបណ្តាល | | ទិសដៅ | ៩ វគ្គ | ៣ | ៣ | ៣ |
| | | | | | លទ្ធផល | ៩ វគ្គ | ២ | ៥ | ២ |
| យុទ្ធសាស្ត្រទី២ | ពិនិត្យឡើងវិញ និងកែលម្អវិធីសាស្ត្រកាត់បន្ថយផ្ទៃដី | | | | [redacted] | | | | |
| សកម្មភាពទី១ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដើម្បីពិនិត្យមើលស្តង់ដារសកម្មភាពមីនឡើងវិញ | ធាតុចូលដែលបានមកពីកិច្ចប្រជុំ | • របាយការណ៍កិច្ចប្រជុំ • បញ្ជីឈ្មោះសមាសភាព | | ទិសដៅ | ៦ដង | ២ | ២ | ២ |
| | | | | | លទ្ធផល | ៥ ដង | ២ | ២ | ១ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សកម្មភាពទី២ | ពិនិត្យឡើងវិញនូវស្តង់ដារសកម្មភាពកម្ចាត់មីនកម្ពុជាស្តីពីការកាត់បន្ថយផ្ទៃដីដែលមានស្រាប់ (ជំពូក១៥) | ស្តង់ដារសកម្មភាពកម្ចាត់មីនកម្ពុជាស្តីពីការកាត់បន្ថយផ្ទៃដី (ជំពូក១៥)ដែលបានពិនិត្យឡើងវិញនូវ | ស្តង់ដារសកម្មភាពកម្ចាត់មីនកម្ពុជាស្តីពីកាត់បន្ថយផ្ទៃដី(ជំពូក១៥) ដែលបានពិនិត្យឡើងវិញនិងទទួលការអនុម័ត | ចាត់អាទិភាពបានកែសម្រួលរួចឆ្លើយតបនឹងតម្រូវការ និងសុវត្ថិភាពមនុស្ស<br>• ប្រតិបត្តិករប្រតិបត្តិតាមស្តង់ដាសកម្មភាពមីនកម្ពុជា<br>• មានបច្ចេកវិជ្ជាថ្មីដែលបានបង្កើតសម្រាប់សកម្មភាពមីន | ទិសដៅ | ១ ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ ច្បាប់ | ១ | | |
| សកម្មភាពទី៣ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តង់ដារសកម្មភាពកម្ចាត់មីនកម្ពុជាស្តីពីការកាត់បន្ថយផ្ទៃដីដែលមានស្រាប់ (ជំពូក១៥) ដែលបានកែសម្រួល | ចំនួនសិក្ខាសាលាដែលបានរៀបចំ | របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយ | | ទិសដៅ | ៦ វគ្គ | ២ | ២ | ២ |
| | | | | | លទ្ធផល | ៦ វគ្គ | ២ | ២ | ២ |
| **យុទ្ធសាស្ត្រទី៣** | **ធ្វើពិពិធកម្មការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យសកម្មភាពមីន** | | | | | | | | |
| សកម្មភាពទី១ | វាយតម្លៃសមត្ថភាពផ្នែកស្រាវជ្រាវនិងអភិវឌ្ឍក្នុងវិស័យសកម្មភាពមីន ដើម្បីកំណត់បច្ចេកវិទ្យាដែលកំពុងអនុវត្ត និងបច្ចេកវិទ្យាថ្មីដែលមានសក្តានុពល | ការវាយតម្លៃសមត្ថភាពផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងវិស័យ សកម្មភាពមីន ដើម្បីកំណត់បច្ចេកវិជ្ជាដែលកំពុងអនុវត្ត និងបច្ចេកវិទ្យាថ្មីដែលមានសក្តានុពល ត្រូវបានរៀបចំឡើង | របាយការណ៍វង្វាយតម្លៃសមត្ថភាពផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងវិស័យសកម្មភាពមីន ដើម្បីកំណត់បច្ចេកវិទ្យាដែលកំពុងអនុវត្ត និងបច្ចេកវិទ្យាថ្មីដែលមានសក្តានុពល។ | | ទិសដៅ | ៣ ដង | ១ | ១ | ១ |
| | | | | | លទ្ធផល | ០ដង | ០ | ០ | ០ |
| សកម្មភាពទី២ | រៀបចំសិក្ខាសាលាដើម្បីបង្ហាញអំពីបច្ចេកវិទ្យាថ្មីៗសម្រាប់វិស័យមីន | ចំនួនសិក្ខាសាលា ដែលបានរៀបចំ | របាយការណ៍សិក្ខាសាលា | | ទិសដៅ | ៣ វគ្គ | ១ | ១ | ១ |
| | | | | | លទ្ធផល | ៣វគ្គ | ១ | ១ | ១ |
| សកម្មភាពទី៣ | កៀរគរធនធានសម្រាប់ធ្វើការស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យមីន | • បង្កើតបានធនធាន<br>• បច្ចេកវិទ្យាថ្មីៗ ត្រូវបានបង្ហាញ | • របាយការណ៍ការសាកល្បងបច្ចេកវិទ្យាថ្មីៗ<br>• អនុស្សារណៈយោគយល់ ឬកិច្ចសន្យា | | ទិសដៅ | ៣ ច្បាប់ | ១ | ១ | ១ |
| | | | | | លទ្ធផល | ៣ច្បាប់ | ១ | ១ | ១ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| គោលបំណងទី២ | វិដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹម ឆ្នាំ២០២៥ | | | | | | | | |
| គោលដៅទី១ | រៀបចំផែនការ និងចាត់អាទិភាពតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម | | | • កង្វះការចូលរួមពេញលេញរបស់ប្រតិបត្តិករ និងមាពូ<br>• មានយន្តការម៉ាពូស្រាប់<br>• មានគោលការណ៍ណែនាំស្តីពីការធ្វើផែនការ និងការចាត់អាទិភាពគ្រាប់បែកចង្កោម | [redacted] | | | | |
| យុទ្ធសាស្ត្រទី១ | ពិនិត្យឡើងវិញ លើគោលការណ៍ណែនាំស្តីពីការធ្វើផែនការ និងការចាត់អាទិភាពនាពេលបច្ចុប្បន្ន សម្រាប់អនុវត្តនៅតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម | | | | | | | | |
| សកម្មភាពទី១ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ | ចំនួនកិច្ចប្រជុំពិគ្រោះយោបល់ | • របាយការណ៍<br>• បញ្ជីសមាសភាពអ្នកចូលរួម | | ទិសដៅ | ៥ប្រជុំ | ៣ | ២ | |
| | | | | | លទ្ធផល | ៤ ប្រជុំ | ៤ | ០ | |
| សកម្មភាពទី២ | បង្កើតគោលការណ៍ណែនាំស្តីពីការធ្វើផែនការនិងការចាត់អាទិភាពបោសសម្អាតតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោម | គោលការណ៍ណែនាំស្តីពីការធ្វើផែនការនិងការចាត់អាទិភាពបោសសម្អាតតំបន់ដែលដឹងថាមានគ្រាប់បែកចង្កោមត្រូវបានបង្កើត | គោលការណ៍ណែនាំស្តីពីការធ្វើផែនការនិងការចាត់អាទិភាពបោសសម្អាតតំបន់មានគ្រាប់បែកចង្កោមត្រូវបានអនុម័ត | | ទិសដៅ | ១ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ច្បាប់ | ១ | | |
| យុទ្ធសាស្ត្រទី២ | រៀបចំផែនការនិងធ្វើការចាត់អាទិភាពតំបន់ដែលមានគ្រាប់បែកចង្កោម | | | | [redacted] | | | | |
| សកម្មភាពទី១ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាមួយភាគីពាក់ព័ន្ធ ដើម្បីកំណត់ឃុំអាទិភាពសម្រាប់បោសសម្អាតគ្រាប់បែកចង្កោម | ចំនួនកិច្ចប្រជុំពិគ្រោះយោបល់ដែលបានរៀបចំឡើង | តារាងចាត់អាទិភាពតំបន់ដែលមានគ្រាប់បែកចង្កោមត្រូវបោសសម្អាត | | ទិសដៅ | ៥ ដង | ៣ | ២ | |
| | | | | | លទ្ធផល | ៣ ដង | ១ | ១ | ១ |
| គោលដៅទី២ | ធ្វើការស្រាវជ្រាវ និងវិដោះផ្ទៃដីដែលត្រូវបានបញ្ជាក់ថាមានគ្រាប់បែកចង្កោម | | | • កង្វះការចូលរួមពេញលេញរបស់ប្រតិបត្តិករ និងម៉ាពូ | [redacted] | | | | |
| យុទ្ធសាស្ត្រទី១ | រៀបចំស្តង់ដារជាតិស្តីពីការធ្វើការស្រាវជ្រាវអំពីគ្រាប់បែកចង្កោម និងកាត់បន្ថយផ្ទៃដី | | | | | | | | |
| សកម្មភាពទី១ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគី | ស្តង់ដារជាតិជំពូកទី១៦ ស្តីពីការធ្វើការស្រាវជ្រាវ និង | ស្តង់ដារជាតិជំពូកទី១៦ ស្តីពីការធ្វើការស្រាវជ្រាវ | | ទិសដៅ | ១ ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ ច្បាប់ | ១ | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ពាក់ព័ន្ធដើម្បីរៀបចំស្តង់ដារជាតិស្តីពីការធ្វើការស្រាវជ្រាវនិងរំដោះផ្ទៃដីដែលមានគ្រាប់បែកចង្កោមជំពូក១៦ | កាត់បន្ថយផ្ទៃដីដែលមានគ្រាប់បែកចង្កោមត្រូវបានរៀបចំ | អំពីគ្រាប់បែកចង្កោមនិងរំដោះផ្ទៃដីត្រូវបានអនុម័ត | • ការចាកចេញពីការងាររបស់មន្ត្រីមាពូនិងប្រតិបត្តិករ<br>• តំបន់មានគ្រាប់បែកចង្កោមមួយចំនួនមិនអាចចូលទៅបាន<br>• មានស្តង់ដាសកម្មភាពមីនកម្ពុជាស្តីពីគ្រាប់បែកចង្កោម<br>• មានគោលការណ៍ណែនាំស្តីពីការធ្វើផែនការនិងការចាត់អាទិភាពគ្រាប់បែកចង្កោម<br>ភាគីពាក់ព័ន្ធមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការបោសសម្អាតគ្រាប់បែកចង្កោម | | | | | |
| **យុទ្ធសាស្ត្រទី២** | **បង្កើនសមត្ថភាពក្នុងការស្រាវជ្រាវ និងការបោសសម្អាត** | | | | | | | | |
| សកម្មភាពទី១ | វាយតម្លៃសមត្ថភាពក្រុមការងារស្រាវជ្រាវនិងបោសសម្អាតគ្រាប់បែកចង្កោម | ការវាយតម្លៃសមត្ថភាពក្រុមការងារស្រាវជ្រាវនិងបោសសម្អាតគ្រាប់បែកចង្កោមត្រូវបានអនុវត្ត | របាយការណ៍វាយតម្លៃសមត្ថភាពក្រុមការងារស្រាវជ្រាវនិងបោសសម្អាតគ្រាប់បែកចង្កោម | | ទិសដៅ | ១ ច្បាប់ | ១ | | |
| | | | | | លទ្ធផល | ១ច្បាប់ | ១ | | |
| សកម្មភាពទី២ | ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមការងារស្រាវជ្រាវ និងបោសសម្អាតគ្រាប់បែកចង្កោម | ចំនួនវគ្គបណ្តុះបណ្តាលលើផ្នែកការស្រាវជ្រាវគ្រាប់បែកចង្កោម និងបោសសម្អាតមីនត្រូវបានរៀបចំ | របាយការណ៍វគ្គបណ្តុះបណ្តាល | | ទិសដៅ | ៣ វគ្គ | ១ | ១ | ១ |
| | | | | | លទ្ធផល | ៣ វគ្គ | ១ | ១ | ១ |
| សកម្មភាពទី៣ | បង្កើតក្រុមការងារស្រាវជ្រាវ និងបោសសម្អាតគ្រាប់បែកចង្កោមដែលមានសមត្ថភាព | • ចំនួនក្រុមការងារស្រាវជ្រាវ និងបោសសម្អាតគ្រាប់បែកចង្កោមប្រកបដោយសមត្ថភាព<br>• ផែនការប្រតិបត្តិការ | បញ្ជីក្រុមការងារស្រាវជ្រាវនិងសម្អាតគ្រាប់បែកចង្កោម ដែលទទួលបានអាជ្ញាប័ណ្ណ | | ទិសដៅ | ២១ ក្រុម | ២១ | | |
| | | | | | លទ្ធផល | ០ | ០ | | |
| **យុទ្ធសាស្ត្រទី៣** | **ធ្វើការស្រាវជ្រាវអំពីគ្រាប់បែកចង្កោម** | | | | | | | | |
| សកម្មភាពទី១ | កៀរគរធនធានសម្រាប់ការស្រាវជ្រាវ និងបោសសម្អាតគ្រាប់បែកចង្កោម | ធនធានកើនឡើងសម្រាប់ការស្រាវជ្រាវ និងបោសសម្អាតគ្រាប់បែកចង្កោម | អនុស្សារណៈយោគយល់និងកិច្ចសន្យា | | ទិសដៅ | ៤៥.៣ លានដុល្លារ | ១៥.១ | ១៥.១ | ១៥.១ |
| | | | | | លទ្ធផល | ១០,៩១ លានដុល្លារ | ៣,០៥ | ៣,៥៦ | ៤,២៩ |
| សកម្មភាពទី២ | អនុវត្តការស្រាវជ្រាវគ្រាប់បែកចង្កោម | ទំហំផ្ទៃដីដែលសង្ស័យ មានគ្រាប់បែកចង្កោម ដែលត្រូវបានរំដោះតាមការស្រាវជ្រាវ | ទិន្នន័យថ្នាក់ជាតិ | | ទិសដៅ | ៥៥,៨គម$^{២}$ | ១៨,៦ | ១៨,៦ | ១៨,៦ |
| | | | | | លទ្ធផល | ១៨.១២គម$^{២}$ | ៩,០៩ | ៤,២៤ | ៦,៤៩ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| យុទ្ធសាស្ត្រទី៤ | រំដោះផ្ទៃដីដែលមានគ្រាប់បែកចង្កោមជាអាទិភាព | | | | [redacted] | | | | |
| | | | | | ទិសដៅ | ១៣០,២ គម$^2$ | ៤៣,៤ | ៤៣,៤ | ៤៣,៤ |
| សកម្មភាពទី១ | រំដោះផ្ទៃដីអាទិភាពដែលរងផលប៉ះពាល់ដោយសារគ្រាប់បែកចង្កោម | ទំហំផ្ទៃដីអាទិភាពដែលរងផលប៉ះពាល់ដោយសារគ្រាប់បែកចង្កោមត្រូវបានបោសសម្អាត | ទិន្នន័យថ្នាក់ជាតិ | | លទ្ធផល | ៧៩,៦៨គម$^2$ | ២៩,៦៨ | ២៥,៤២ | ២៥,១៨ |
| គោលបំណងទី៣ | ដោះស្រាយការគំរាមកំហែងពីសំណល់ជាតិផ្ទុះពីសង្គ្រាម( ស.ផ.ស. ) | | | | | | | | |
| គោលដៅទី១ | ស្រាវជ្រាវ និងរំដោះផ្ទៃដីដែលដឹងថាមាន ស.ផ.ស. | | | •កង្វះធនធានក្នុងការកាត់បន្ថយផ្ទៃដីដែលមានសំណល់ជាតិផ្ទុះពីសង្គ្រាម<br>•ស្តង់ដារសកម្មភាពមីនកម្ពុជាស្តីពីការស្រាវជ្រាវ និងកាត់បន្ថយផ្ទៃដីមាន ស.ផ.ស. ត្រូវរៀបចំ | [redacted] | | | | |
| យុទ្ធសាស្ត្រទី១ | ពិនិត្យឡើងវិញលើស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីការកាត់បន្ថយផ្ទៃដីដែលមាន ស.ផ.ស. | | | | | | | | |
| | | | | | | | | | |
| សកម្មភាពទី១ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីប្រមូលធាតុចូល សម្រាប់ពិនិត្យឡើងវិញលើស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីការស្រាវជ្រាវ និងការកាត់បន្ថយផ្ទៃដីដែលមានស.ផ.ស. | ស្តង់ដារសកម្មភាពកំចាត់មីនកម្ពុជាជំពូក៧ និងជំពូក១៤ ស្តីពីការ ស្រាវជ្រាវមូលដ្ឋានត្រូវបានពិនិត្យឡើងវិញ | របាយការណ៍កិច្ចប្រជុំ | | ទិសដៅ | n/a | មិនមានតម្រូវការរៀបចំ | | |
| | | | | | លទ្ធផល | n/a | n/a | | |
| យុទ្ធសាស្ត្រទី២ | កំណត់អត្តសញ្ញាណ និងរំដោះផ្ទៃដីដែលដឹងថាមានស.ផ.ស. | | | | [redacted] | | | | |
| សកម្មភាពទី ១ | រំដោះផ្ទៃដីដែលបានកំណត់ថាជាផ្ទៃដីដែលមាន ស.ផ.ស. | ទំហំផ្ទៃដី ស.ផ.ស. ដែលបានបោសសម្អាត | • របាយការណ៍បោសសម្អាត ស.ផ.ស.<br>• បំណែកស.ផ.ស. ដែលបានរកឃើញ | | ទិសដៅ | មិនទាន់ធ្វើក្នុងរយៈពេល០៣ឆ្នាំនេះ ទេ លើកលែងតែតំបន់ B1.2 និងតំបន់ដែលមានតម្រូវការអភិវឌ្ឍន៍ដែលមានការជីកកកាយខ្លាំង | | | | |
| | | | | | លទ្ធផល | n/a | | | |
| គោលដៅទី២ | ផ្តល់ការឆ្លើយតបអោយទាន់ពេលវេលាចំពោះសំណើរសុំជំនួយអន្តរាគមន៍ផ្នែកប្រតិបត្តិការកំទេចគ្រឿងផ្ទុះពីសហគមន៍ ឬអាជ្ញាធរ | | | • កង្វះការគាំទ្រពីប្រទេសម្ចាស់ | [redacted] | | | | |
| យុទ្ធសាស្ត្រទី១ | ពិនិត្យឡើងវិញ និងពង្រឹងសមត្ថភាពបច្ចុប្បន្ន ផ្នែកប្រតិបត្តិការកំទេចគ្រឿងផ្ទុះ | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សកម្មភាពទី១ | សិក្សាសមត្ថភាពបច្ចុប្បន្នផ្នែកប្រតិបត្តិការកំទេចគ្រឿងផ្ទុះ | របាយការណ៍សិក្សាពីសមត្ថភាពបច្ចុប្បន្ន ផ្នែកប្រតិបត្តិការកំទេចគ្រឿងផ្ទុះ | របាយការណ៍សិក្សាពីសមត្ថភាព | ជំនួយក្នុងការកាត់បន្ថយផ្ទៃដីដែលមានសំណល់ជាតិផ្ទុះពីសង្គ្រាម | ទិសដៅ | ១ ច្បាប់ | | | ១ |
| | | | | | លទ្ធផល | ១ ច្បាប់ | | | ១ |
| សកម្មភាពទី២ | វាយតម្លៃប្រសិទ្ធិភាពនិងប្រសិទ្ធិផលក្នុងការឆ្លើយតបសំណើសុំកំទេចគ្រឿងផ្ទុះ | របាយការណ៍វាយតម្លៃត្រូវបានរៀបចំ | របាយការណ៍វាយតម្លៃ | | ទិសដៅ | ១ ច្បាប់ | | | ១ |
| | | | | | លទ្ធផល | ១ ច្បាប់ | | | ១ |
